ក្រសួងអប់រំ យុវជន និង កីឡា

សៀវភៅកិច្ចការផ្ទះ

ភាសាខ្មែរ ៨

សម្រាប់សិស្ស



ស្របតាមកម្មវិធីសិក្សា

សុខ ហ៊ីរ៉ែណា

អារម្ភកថា

សៀវភៅកិច្ចការផ្ទះមុខវិជ្ជាភាសាខ្មែរ ថ្នាក់ទី៨នេះ នាងខ្ញុំបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងមាតិកាដែលបានរៀបចំឡើងមានលក្ខណៈសមស្របតាមកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៨ រួមមានចំនួន១០មេរៀន លំអិតដោយចំណុចសំខាន់ៗជាច្រើនទៀត។

ខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះ នឹងជួយប្អូនៗឱ្យបានដឹងកាន់តែអំពីខ្លឹមសារសំខាន់នៃមេរៀនគោលនីមួយៗ រួមទាំងបំណិនក្នុងការអាន ការស្តាប់ ការនិយាយ ការសរសេរ និងលើវេយ្យាករណ៍ក្នុងភាសាខ្មែរ។ គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះគឺមានទម្រង់ដូចៗគ្នាទាំងអស់ដូចជាការកំណត់វត្ថុបំណងនៃមេរៀន ពង្រឹងសមត្ថភាពក្នុងការអនុវត្តលំហាត់ និងស្វែងយល់នូវខ្លឹមសារមេរៀននីមួយៗ។

នាងខ្ញុំសង្ឃឹមថា សៀវភៅកិច្ចការផ្ទះ ភាសាខ្មែរថ្នាក់ទី៨ នឹងបានរួមចំណែកជួយប្អូនៗក្នុងការសិក្សាលើមុខវិជ្ជាភាសាខ្មែរ។ ទន្ទឹមគ្នានោះដែរ នាងខ្ញុំសូមខន្តីអភ័យទោសរាល់កំហុសខុសឆ្គងនានា និងរីករាយទទួលយករាល់មតិកែរិះគន់លម្អពីសំណាក់ លោកគ្រូ អ្នកគ្រូគ្រប់មជ្ឈដ្ឋានទាំងអស់ ។

ថ្ងៃសុក្រ១កើត ខែបុស្ស ឆ្នាំខាលចត្វាស័ក ពុទ្ធសករាជ២៥៦៦

ភ្នំពេញ,ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២

អារម្ភកថា

មេរៀនទី១ អោនឆ្ពាគ ១

មេរៀនទី២ ភាពស្មោះត្រង់ ២៨

មេរៀនទី៣ អធ្យាស្រ័យ ៥៩

មេរៀនទី៤ ៖ មិត្តភាព ៨២

មេរៀនទី៥៖ ការគោរពខ្លួនឯង ១០២

មេរៀនទី៦៖ ការគោរពច្បាប់ ១២៧

មេរៀនទី៧៖ ការទទួលខុសត្រូវ ១៤៥

មេរៀនទី៨៖ ការប្រឹងប្រែង ១៦៦

មេរៀនទី៩៖ សេចក្តីថ្លៃថ្នូរ ១៨៨

មេរៀនទី១០៖ ឧត្តមភាព ២១១

ᨾᨾ មេរៀនទី១ ᨾᨾ

🕯 បំណិន ៖ ពិតកថា

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១. ដូចម្តេចដែលហៅថាពិតកថា?

ក. ជាអត្ថបទបង្ហាញពីរឿងរ៉ាវពិត លាយឡំប្រឌិត

ខ. ជាអត្ថបទសរសេរតាមការស្រមើស្រមៃ

គ. ជាអត្ថបទបង្ហាញតែប្រវត្តិសាស្ត្រពិត

ឃ. ជាអត្ថបទបង្ហាញពីរឿងរ៉ាវពិត ឥតបំភ្លៃ

២. តើពិតកថាចែកជាប្រភេទអ្វីខ្លះ?

ក. ទេវកថា ឧស្សាហកថា ស្វ័យជីវប្រវត្តិ ជីវប្រវត្តិ

ខ. ជីវប្រវត្តិ ព្រេងកថា ឧស្សាហកថា បទសាកល្បង

គ. និទានកថា ប្រវត្តិសាស្ត្រ កំណត់ហេតុ របាយការណ៍

ឃ. ជីវប្រវត្តិ ស្វ័យជីវប្រវត្តិ បទសាកល្បង ប្រវត្តិសាស្ត្រ កំណត់ហេតុ របាយការណ៍ និងព្រឹត្តិការណ៍ជាក់ស្តែង

៣. តើពិតកថា(ជីវប្រវត្តិ)បង្ហាញអំពីអ្វីខ្លះ?

ក. ស្ថានភាពជីវិតពិតរបស់បុគ្គល និងស្នាដៃ

ខ. កាលបរិច្ឆេទពិតទាក់ទងនឹងការរស់នៅ

គ. ប្រវត្តិការងារ និងស្ថានភាពគ្រួសារពិត

ឃ. ស្ថានភាពជីវិត គ្រួសារ កាលបរិច្ឆេទ ស្នាដៃ ការរស់នៅ និងប្រវត្តិការងារសុទ្ធតែពិត

៤. តើក្នុងចំណោមអត្ថបទខាងក្រោម អត្ថបទណាមួយជាពិតកថា?

ក. រឿងដើមកំណើតរន្ទះ ខ. ជីវប្រវត្តិឧកញ៉ាសន្ធរម៉ុក

គ. រឿងភ្នំប្រុសភ្នំស្រី ឃ. អ្នកតាឃ្លាំងមឿង

៥. តើអត្ថបទដែលនរណាម្នាក់ចងក្រងពីជីវប្រវត្តិពិតបុគ្គលម្នាក់ទៀតហៅថាអ្វី?

ក. ស្ម័យជីវប្រវត្តិកថា ខ. ប្រវត្តិសាស្ត្រ

គ. កំណត់ហេតុ ឃ. ជីវប្រវត្តិកថា

៦. តើអត្ថបទមួយណា ជាពិតកថា(ជីវប្រវត្តិកថា)?

ក. ជីវប្រវត្តិឧកញ៉ាសន្ធរវោហារម៉ុក ខ. រឿងមាយើង

គ. ប្រវត្តិសាស្ត្រខ្មែរ ឃ. ជីវប្រវត្តិផ្ទាល់ខ្លួន

៧. តើអត្ថបទសម្តេចព្រះសង្ឃរាជ ជួន ណាត ជាប្រភេទអត្ថបទអ្វី?

ក. អត្ថបទរឿង ខ. អត្ថបទល្ខោន

គ. អត្ថបទប្រឌិតកថា ឃ. អត្ថបទពិតកថា

៨. តើអត្ថបទដែលនរណាម្នាក់ចងក្រងពីជីវប្រវត្តិពិតបុគ្គលម្នាក់ទៀត ហៅថាអ្វី?

ក. ស្ម័យជីវប្រវត្តិកថា ខ. ប្រវត្តិសាស្ត្រ

គ. កំណត់ហេតុ ឃ. ជីវប្រវត្តិកថា

៩. ក្នុងចំណោមអត្ថបទខាងក្រោម តើអត្ថបទមួយណាមិនមែនជាពិតកថា?

ក. វប្បធម៌អារ្យធម៌ខ្មែរ ខ. ប្រវត្តិសាស្ត្រខ្មែរ-សៀម

គ. រឿងភ្នំប្រុសភ្នំស្រី ឃ. ជីវប្រវត្តិអ្នកនិពន្ធខ្មែរ

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ រួចបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ ស្ម័យជីវប្រវត្តិ ពិតកថា ប្រវត្តិសាស្ត្រ ជីវប្រវត្តិកថា រោយការណ៍ បទសាកល្បង កំណត់ហេតុ

ពិតកថាជាប្រភេទអត្ថបទបង្ហាញពីរឿងរ៉ាវពិត ដែលមានច្រើនប្រភេទដូចជា ជីវប្រវត្តិកថា ស្វ័យជីវប្រវត្តិកថា បទសាកល្បង (ឧស្សាហកថា) ប្រវត្តិសាស្ត្រ កំណត់ហេតុ របាយការណ៍ និងព្រឹត្តិការណ៍ជាក់ស្តែងជាដើម។

.....នីមួយៗមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទនីមួយ ដែលជាទូទៅយើងច្រើនជួបក្នុងជីវភាពរស់នៅជាក់ស្តែងក៏ដូចជាការសិក្សា។ ពិតកថាទាំងនោះមានលក្ខណៈដូចជា .....គឺជាអត្ថបទដែលបុគ្គលណាម្នាក់បានលើកយក ជីវប្រវត្តិពិតរបស់បុគ្គលណាម្នាក់ទៀត ដែលចាត់ទុកថាមានស្នាដៃមកចងក្រងទុកជាឯកសារ ហើយក្នុងនោះបង្ហាញតែរឿងរ៉ាវពិត ជាក់ស្តែងតែប៉ុណ្ណោះ ដោយមិនបំភ្លៃ។ ..... ជាអត្ថបទទាំងឡាយណាដែលបង្ហាញពីជីវប្រវត្តិផ្ទាល់ខ្លួនរបស់បុគ្គលណាម្នាក់ ហើយត្រូវបានសរសេរឡើងដោយបុគ្គលនោះផ្ទាល់។ .....ជាអត្ថបទដែលបង្ហាញពីរឿងរ៉ាវពិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ជាគម្ពីរ ក្បួនច្បាប់សំដែងអំពីពង្សាវតារ ឬអំពីរបាក្សត្រ។

លើសពីនេះ អត្ថបទទាំងឡាយណាដែល កត់ត្រានូវហេតុការណ៍ ដំណើរការប្រជុំ ឬទស្សនកិច្ច ហៅថាកំណត់ហេតុ។ ចំណែកឯ អត្ថបទបូកសរុប សកម្មភាពក្នុងការអនុវត្តការងារជាក់ស្តែង គេច្រើនហៅថា..... ។ .....បទសាកល្បង (ឧស្សាហកថា) គឺជាអត្ថបទដែលបកស្រាយ ប្រធានបទណាមួយ ទាក់ទងនឹងអក្សរសាស្ត្រ នយោបាយ នីតិសាស្ត្រ វិទ្យាសាស្ត្រជាដើម ។ ព្រឹត្តិការជាក់ស្តែង ជាអត្ថបទដែលនិយាយពីព្រឹត្តិការណ៍ចាក់ស្តែង កើតឡើងប្រចាំថ្ងៃ ដូចជា គ្រោះថ្នាក់ចរាចរណ៍ អគ្គីភ័យ។ល។

គ. ចូរផ្គូរផ្គងផ្នែក ក និងផ្នែកខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. ជីវប្រវត្តិព្រះភរិម្យភាសាអ៊ូ	ក. ប្រវត្តិសាស្ត្រ	១ →.....
២. នយោបាយប្រទេសកម្ពុជា	ខ. ស្វ័យជីវប្រវត្តិ	២ →.....
៣. ជីវប្រវត្តិផ្ទាល់ខ្លួន	គ. ជីវប្រវត្តិកថា	៣ → .....
៤. ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍	ឃ. បទសាកល្បង	៤ → .....
៥. ព័ត៌មានប្រចាំថ្ងៃ	ង. របាយការណ៍	៥ → .....

៦. របាយការណ៍នៃការប្រជុំប្រចាំខែ	ច. ព្រឹត្តិការជាក់ស្តែង	៦ →.....
	ឆ. ឧស្សាហកម្មកថា	

ឃ. សំណួរត្រិះរិះ

១. ចូររកចំណងជើងអត្ថបទដែលជាប្រភេទផ្សេងៗនៃពិតកថា ឱ្យបានមួយប្រភេទចំនួន៣អត្ថបទ។

.....

.....

.....

.....

.....

.....

.....

.....

២. តើពិតកថា ខុសពីប្រឌិតកថាយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ ជីវប្រវត្តិសម្តេចព្រះសង្ឃរាជជួនណាត

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១. តើសម្តេចព្រះសង្ឃរាជ ជួន ណាតជាអ្នកណា?

ក. ព្រះអង្គជាស្តេចមួយអង្គ ខ. ព្រះអង្គជាមន្ត្រីម្នាក់

គ. ព្រះអង្គជាអ្នកប្រាជ្ញខ្មែរ ឃ. ព្រះអង្គជាប្រជារាស្ត្រធម្មតាម្នាក់

២. តើសម្តេចព្រះសង្ឃរាជ ជួន ណាត ប្រសូត្រនៅថ្ងៃណា? ខែណា? ឆ្នាំណា? នៅឯណា?

ក. ថ្ងៃទី១១ ខែមីនា ឆ្នាំ ១៨៨៣ នៅ ខេត្តកំពង់ស្ពឺ

ខ. ថ្ងៃទី១១ ខែមីនា ឆ្នាំ ១៨៨៣ នៅ ខេត្តបាត់ដំបង

គ. ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៨៨៣ នៅ ខេត្តតាកែវ

ឃ.ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៨៨៣ នៅ ខេត្តកណ្តាល

៣. តើស្នាព្រះហស្តណាខ្លះរបស់ព្រះអង្គ ដែលមានប្រជាប្រិយភាពជាងគេក្នុងចំណោមអ្នកសិក្សា?

ក. បទភ្លេងជាតិ និងវេយ្យាករណ៍បាលី ខ. វចនានុក្រមខ្មែរ និងបទភ្លេងជាតិ

គ. សាមណេរវិន័យ និងវចនានុក្រមខ្មែរ ឃ. វេយ្យាករណ៍បាលី និងសាមណេរវិន័យ

៤. តើព្រះអង្គមានគុណសម្បត្តិអ្វីខ្លះ ចំពោះភាសាជាតិ?

ក. រួមចំណែកអភិរក្ស និងអភិវឌ្ឍអក្សរសាស្ត្រជាតិ ខ. និពន្ធក្បួនវេយ្យាករណ៍ជាច្រើន

គ. ចងក្រងប្រវត្តិអក្សរសាស្ត្រជាតិ ឃ. បង្កើតគណៈកម្មាធិការភាសាជាតិ

៥. តើអត្ថបទសម្តេចព្រះសង្ឃរាជ ជួន ណាត ជាប្រភេទអត្ថបទអ្វី?

ក. ប្រឌិតកថា ខ. ជីវប្រវត្តិកថា

គ. ស្វ័យជីវប្រវត្តិកថា ឃ. កំណត់ហេតុ

៦. ហេតុអ្វីបានជាអ្នកនិពន្ធចងក្រងជីវប្រវត្តិសម្តេចព្រះសង្ឃរាជជួន ណាត?

ក. ដើម្បីឱ្យអ្នកសិក្សាយកគំរូតាមបុព្វបុរសខ្មែរ

ខ. ដើម្បីកុំឱ្យកូនចៅជំនាន់ក្រោយភ្លេចព្រះអង្គ

គ. ដើម្បីជាការកែកម្សាន្តលេង

ឃ. ព្រោះជាគោលការណ៍របស់អ្នកនិពន្ធ

៧. ហេតុអ្វីបានជាសម្តេចព្រះសង្ឃរាជជួនណាត យកព្រះទ័យទុកដាក់ចំពោះវិស័យអក្សរសាស្ត្រជាតិ?

ក. ពីព្រោះគ្មានអ្នកណាយកចិត្តទុកដាក់លើវិស័យនេះ

ខ. ពីព្រោះវិស័យអក្សរសាស្ត្រជាតិមានភាពដុនដាបខ្លាំង

គ. ពីព្រោះព្រះអង្គសង្ឃឹមថា ព្រះអង្គនឹងទទួលបានកិត្តិនាមល្បីល្បាយ

ឃ. ពីព្រោះព្រះអង្គចង់ឱ្យវិស័យអក្សរសាស្ត្រជាតិរីកចម្រើន និងមានក្បួនច្បាស់លាស់

៨. តើសម្តេចព្រះសង្ឃរាជជួនណាត មានព្រះរាជគោរម្យងារអ្វី?

ក. ព្រះមហាវីរៈជាតិ ខ. សម្តេចព្រះជោតញ្ញាណោ

គ. សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ឃ. ព្រះឧបោសថរតនារាម

៩. អត្ថបទខាងក្រោម ជាស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជជួនណាត លើកលែងតែ៖

ក. បទនគររាជ ខ. សាមណេរវិន័យ

គ. វចនានុក្រមខ្មែរ ភាគ១និងភាគ២ ឃ. គម្ពីរបញ្ញាសជាតក

១០. តើសម្តេចព្រះសង្ឃរាជជួនណាតសុគតនៅឆ្នាំណា?

ក. ២៥ កញ្ញា ១៩៦៩ ខ. ១៥ មិថុនា ១៩៧០

គ. ១១ មីនា ១៨៨៣ ឃ. ០៩ កញ្ញា ១៩៧៩

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ រួចបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ មរតក កំពង់ស្ពឺ ជោគជ្រាណោ ឆ្លុះឆ្លាយ សេចក្តីព្យាយាម បំពេញកិច្ចសិក្សាតែង

សម្តេចសង្ឃរាជជួន ណាត ជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរដ៏ល្បីល្បាញ ដោយព្រះអង្គបានបន្សល់ទុក នូវ..... ជាប្រវត្តិសាស្ត្រដល់កូនខ្មែរនាពេលសព្វថ្ងៃនោះគឺ សៀវភៅវចនានុក្រមភាសាខ្មែរដ៏វិសេសវិសាល។ សម្តេចព្រះសង្ឃរាជ ជួន ណាត ទ្រង់ប្រសូតនៅថ្ងៃអង្គារ ទី១១ ខែ មីនា គ.ស.១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី.....។ សម្តេចមានព្រះជាតិក្នុងត្រកូលកសិករ ដែលមានបុត្រតែពីរនាក់គត់។ លុះសម្តេចមានព្រះជន្មាយុ១៤ឆ្នាំ បានបួសជាសាមណេរ នៅ..... នាវត្តពោធិព្រឹក្ស អស់រយៈកាលពីរឆ្នាំ ទើបចេញអំពីវត្តពោធិព្រឹក្សទៅរៀនឯវត្តឧណ្ណាលោម ក្រុងភ្នំពេញ។ លុះបានព្រះជន្មាយុគម្រប់២១ព្រះវស្សាបានទ្រង់និមន្តត្រឡប់ទៅសូមឧបម្បទាជាភិក្ខុ ក្នុងវត្តពោធិព្រឹក្សដែលជាវត្តដើមវិញ។ សម្តេចទ្រង់ទទួលព្រះនាមប្បញ្ញត្តិថា .....។

សម្តេចព្រះសង្ឃរាជមាន.....ប្រកបដោយថាមពលដ៏ក្លៀវក្លាក្នុងការសិក្សា ទាំងផ្នែកភាសាបាលី ទាំងផ្នែកភាសាឯទៀតៗមានភាសាបារាំងជាដើម។ ការសិក្សារបស់សម្តេចព្រះសង្ឃរាជមានជោគជ័យប្រសើរណាស់។ សម្តេចព្រះសង្ឃរាជ រៀនដោយយកព្រះទ័យទុកដាក់ ខិតខំប្រឹងប្រែង ឥតមានបន្ធូរបន្ថយក្នុងការសិក្សានោះឡើយ។ សម្តេចទ្រង់ទទួលការសិក្សានោះគឺ សិក្សាដោយឆន្ទៈដ៏មានកម្លាំងមែនទែន ពុំមែនសិក្សាវិជ្ជាណាមួយដោយលេងៗទេ។ វិជ្ជាខាងភាសាបាលី ភាសាសំស្ក្រឹត និងភាសាបារាំង សុទ្ធតែវិជ្ជាដែលប្រដាប់ដោយវេយ្យាករណ៍ហ្មត់ចត់ ជ្រាលជ្រៅលំបាករៀន លំបាកយល់ជាទីបំផុត ប៉ុន្តែសម្តេចអាចរៀន អាចយល់ច្បាស់លាស់ ដោយឆាប់រហ័សគួរកោតសរសើរពន់ពេកណាស់។

សម្តេចទ្រង់ចេះដឹងយល់..... ចំពោះវេយ្យាករណ៍គ្រប់ភាសា ដែលសម្តេចបានរៀន មានវេយ្យាករណ៍បាលីសំស្ក្រឹតជាដើម ទាំងអក្សរសាស្ត្ររបស់ជាតិ និងពាក្យពេចន៍ក្នុងផ្នែកវប្បធម៌បុរាណក៏សម្តេចចេះចាំយល់ហេតុផល ជាច្រើនណាស់។ ភាសា

សៀម ភាសាលាវ និងភាសាបារាំង ដែលសម្តេចបានរៀន អាចនិយាយប្រាស្រ័យទាក់ទងនឹងជនជាតិសៀម ជាតិលាវ និងជាតិបារាំងបាន។

ក. ចូរផ្គូរផ្គងផ្នែក ក និងផ្នែកខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១.ចូកចាំង	ក.បព្វជិត ពុទ្ធសាសនិកអ្នកកាន់សីល១០ លោកនេន	១→
២.ព្រះពុទ្ធយោសាចារ្យ	ខ.សម្តេចសង្ឃ	២→
៣.គន្ថធុរៈ	គ.ការស្រឡាញ់រាប់អាន សេចក្តីគោរព ដំណើរអាស្រ័យ	៣→
៤.សាមណេរ	ឃ.ពង្រាប ឬចូកឆាយ ឈូសឆាយឱ្យស្មើ	៤→
៥.ព្រះសង្ឃរាជ	ង.គ្រូអាចារ្យដែលបានបង្ហាត់បង្រៀនសិស្ស	៥→
៦.ប្រាស្រ័យ	ច.ធុរៈផ្នែកខាងគម្ពីរបាលី កិច្ចការរៀនសូត្រខាងបរិយត្តិជាគូនឹងវិប្បនា	៦→
	ឆ.ខ្មីឃ្លាត ប្រឹងប្រែងបំពេញកិច្ចការណាមួយ	

ឃ. សំណួរត្រិះរិះ

១. ហេតុអ្វីបានជាយើងចាំបាច់សិក្សាអំពីជីវប្រវត្តិសម្តេចសង្ឃជូនណាត?

.....

.....

.....

.....

.....

.....

.....

.....

.....

២. តាមយោបល់អ្នក តើសម្តេចសង្ឃជូនណាតជាបុគ្គលបែបណា?

.....

.....

.....

.....

.....

.....

.....

.....

.....

.

⊶ វេយ្យាករណ៍៖ សញ្ញាដំលើ(◌ំ)

លំហាត់

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១.តើពាក្យមួយណាដែលប្រើសញ្ញាដំលើ កត់សូរពាក្យក្លាយបាលីសំស្ក្រឹត?

ក. សំយោគ ខ. ជាំ

គ. ដាំ ឃ. ដំ

២.តើពាក្យមួយណាដែលប្រើសញ្ញាដំលើ ប្រកបជាមួយស្រៈ [អ៊ី]?

ក. ជំ ខ. សំយោគ

គ. មាំ ឃ. កុំ

៣. ក្នុងចំណោមពាក្យខាងក្រោម តើពាក្យមួយណាដែលប្រើសញ្ញាដំលើប្រកបជាមួយស្រៈកប់តូ?

ក. ចំ ខ. សំរិទ្ធ

គ. ចាំ ឃ. មាំ

៤.តើពាក្យមួយណាដែលប្រើសញ្ញាដំលើប្រកបជាមួយស្រៈភ្ជាប់តូ?

ក. ដំ ខ. សំរិទ្ធ

គ. រាំ ឃ. ទុំ

៥. តើសញ្ញាដំលើ មានរូបរាងដូចម្តេច?

ក. (◌ុ◌ំ) ខ. (◌ំ)

គ. (◌ា◌ំ) ឃ. (◌ះ)

៦. ដូចម្តេចដែលហៅថាសញ្ញាដំលើ?

ក. ជាសញ្ញាសម្រាប់ប្រើជំនួសស្រៈ (ុ◌ំ)

ខ. ជាសញ្ញាសម្រាប់ប្រើជាមួយព្យញ្ជនៈពួក អ

គ. ជាសញ្ញាសម្រាប់ប្រើជាមួយព្យញ្ជនៈពួក អ៊

ឃ. ជាសញ្ញាសម្រាប់ប្រើជំនួសព្យញ្ជនៈ "ម" សូរព្យញ្ជនៈ "ម" និង "ង"

៧. តើគេអាចប្រើសញ្ញាដំលើ(◌ំ) ដោយរបៀបណាខ្លះ?

ក. ប្រកបជាមួយស្រៈកប់តួ និងស្រៈភ្ជាប់តួ

ខ. ប្រកបជាមួយស្រៈ ◌ាំ និង ◌ុំ

គ. ប្រកបជាមួយស្រៈ ◌ុ និង ◌ោះ

ឃ. ប្រកបជាមួយស្រៈ ◌ោ និង ◌ាំ

៨.ក្នុងចំណោមពាក្យខាងក្រោម តើពាក្យមួយណាដែលប្រើសញ្ញាដំលើប្រកបជាមួយស្រៈកប់តួ?

ក. ចំ [cɑm]

ខ. សំរិទ្ធ [sɑm rit]

គ. ចាំ [cam]

ឃ. មាំ [moa:m]

៩. ក្នុងចំណោមពាក្យខាងក្រោមតើពាក្យមួយណាដែលប្រើសញ្ញាដំលើប្រកបជាមួយស្រៈភ្ជាប់តួ?

ក. ដំ

ខ. សំរិទ្ធ

គ. រាំ

ឃ. ទុំ

១០. ក្នុងចំណោមពាក្យខាងក្រោមតើពាក្យមួយណាដែលប្រើសញ្ញាដំលើប្រកបជាមួយស្រៈ[អ៊ី]?

ក. ជំ

ខ. សំយោគ

គ. មាំ

ឃ. កុំ

១១. ក្នុងចំណោមពាក្យខាងក្រោមតើពាក្យមួយណាដែលប្រើសញ្ញាដំលើកត់សូរពាក្យក្លាយបាលីសំស្ក្រឹត?

ក. សំយោគ ខ. ជាំ

គ. ដាំ ឃ. ដំ

ខ. ចូរជ្រើសរើសពាក្យខាងក្រោមបំពេញ តាមផ្នែកនីមួយៗ ឱ្យបានត្រឹមត្រូវ

☞ ចាំ ចំ សំភី ជ្រាំ គាំ តាំង សាំង រាំ ភ្នំ ខ្ញុំ ឃ្មុំ សំខ្យា គ្រាំ ច្រាំ ព្រាំ ទម្រាំ តម្រាំ រុំ ខាំ មំសា

ស្រៈកប់តួ	**ឧ. ចំ .....**
ស្រៈភ្ជាប់តួ	**ឧ. ចាំ.....**
ស្រៈអ័រ	**ឧ. រាំ.....**
កត់ពាក្យបាលីសំស្ក្រឹតក្លាយ	**ឧ. មំសា.....**

គ. ចូរផ្គូរផ្គងផ្នែក ក និងផ្នែកខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. សញ្ញាសម្រាប់ប្រើជំនួសព្យញ្ជនៈ"ម" សូរព្យញ្ជនៈ "ម" និង "ង"	ក. ស្រៈកប់តួ	១→ .....
២. ពាក្យ "ខាំ" ប្រើសញ្ញាដំលើប្រកបជាមួយ	ខ.បាលីសំស្ក្រឹត	២→ .....
៣. ពាក្យ "ទំ" ប្រើសញ្ញាដំលើប្រកបជាមួយ	គ. ស្រៈភ្ជាប់តួ	៣→ .....
៤. ពាក្យ "ទាំ" ប្រើសញ្ញាដំលើប្រកបជាមួយ	ឃ. សញ្ញាដំលើ	៤→.....
៥. ពាក្យ "សំយោគ" ប្រើសញ្ញាដំលើកត់សូរ	ង. ស្រៈអ័រ	៥→ .....
	ច. ស្រៈខ្លី អា	

ឃ. សំណួរត្រិះរិះ

១. ចូរអ្នកដកស្រង់ពាក្យក្នុងវគ្គនេះ៖ ដែលមានសញ្ញាដំលើប្រើនៅលើស្រៈប្រកបគឺ៖

-ស្រៈកប់តួនិងស្រៈភ្ជាប់តួ

-អាចប្រកបនឹងស្រៈ [អ៊ី]

- អាចកត់សូរក្នុងពាក្យក្លាយពីបាលីសំស្ក្រឹត ។

[...] ក្នុងឆ្នាំដដែលនោះ សម្តេចបានទទួលការតែងតាំងជាសមាជិកជំនួយនៃក្រុមជំនុំខាងការ ស្រាវជ្រាវជ្រើសរើសពាក្យពេចន៍ក្នុងផ្នែកនៃកវីនិពន្ធខ្មែរបុរាណ ...ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះ ទៅក្នុងវចនានុក្រមខ្មែរ។ ព.ស២៤៧៧ គ.ស១៩៣៣ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំពិនិត្យសៀវភៅ ដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ ព.ស២៤៧៨ គ.ស១៩៣៤ សម្តេចទ្រង់បានទទួលការតែងតាំងជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀប នឹងពាក្យបារាំងសម្រាប់ប្រើក្នុងការងាររាជការ។ ព.ស.២៤៧៩ គ.ស១៩៣៥ សម្តេចទ្រង់បានទទួលការតែងតាំងជា សាស្ត្រាចារ្យបង្រៀនភាសាបាលីសំស្ក្រឹតខ្មែរនិងលាវប្រចាំថ្នាក់ទីបញ្ចប់នៃមធ្យមនៅ វិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ ។[...]

-ស្រៈកប់តួ៖ .....

ស្រៈភ្ជាប់តួ៖.....

-អាចប្រកបនឹងស្រៈ: [អ៊ី]៖ .....

- អាចកត់សូរក្នុងពាក្យក្លាយពីបាលីសំស្ក្រឹត៖ .....

២. ចូរឆ្លងរកពាក្យដែលប្រើសញ្ញាដំលើ(ំ) ប្រកបជាមួយ ស្រៈកប់តួ កត់ពាក្យក្លាយបាលីសំស្ក្រឹត ស្រៈភ្ជាប់តួ ស្រៈអ័រ ឱ្យបាន ៥ពាក្យក្នុងមួយប្រភេទ។

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ ជីវប្រវត្តិឧកញ៉ាសន្ធរខោហារម៉ុក

លំហាត់

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១. តើលោកឧកញ៉ាសន្ធរម៉ុក ជាអ្នកណា?

ក. ជាអ្នកចម្រៀងចាប៉ី ខ. ជាមន្ត្រីម្នាក់

គ. ជាកសិករ ឃ. ជាអ្នកនិពន្ធ

២. តើលោកឧកញ៉ាសន្ធរខោហារម៉ុកមានលក្ខណៈសម្បត្តិបែបណា?

ក. ស្អាត សង្ហា ចូលចិត្តសិក្សារៀនសូត្រ

ខ. រូបរាងអាក្រក់ ព្យាយាម និងមានចំណេះដឹងខ្ពស់

គ. ឧស្សាហ៍ មានចំណេះដឹងខ្ពស់ តែចិត្តអាក្រក់

ឃ. កំព្រា ខិតខំរៀន រមិលគុណ

៣. តើលោកឧកញ៉ាសន្ធរខោហារម៉ុក កើតនៅឆ្នាំណា និងទទួលមរណៈភាពនៅឆ្នាំណា?

ក. កើតឆ្នាំ១៨៥៦ មរណៈភាពឆ្នាំ១៩០៨ ខ. កើតឆ្នាំ១៨៣២ មរណៈភាពឆ្នាំ១៨៩៦

គ. កើតឆ្នាំ១៩០៣ មរណៈភាពឆ្នាំ១៩២៩ ឃ. កើតឆ្នាំ ១៩១៥ មរណៈភាពឆ្នាំ ១៩៧៨

៤. ចំណុចមួយណា មិនមែនជាលក្ខណៈសម្បត្តិលោកឧកញ៉ាសន្ធរខោហារម៉ុក?

ក. មានទេពកោលស្បៃតែងកំណាព្យ ខ. មានសំឡេងពីរោះ

គ. ស្នេហាជាតិ ឃ. មានរូបស្រស់សង្ហា

៥. ហេតុអ្វីបានជាសន្ធរម៉ុកត្រូវរស់នៅវត្តអារាមកាលលោកនៅវ័យកុមារ?

ក. លោកជាកុមារកំព្រា ខ. ជីវភាពគ្រួសារលោកខ្វះខាត

គ. លោកមិនចង់រស់នៅជាមួយគ្រួសារ ឃ. ព្រះគ្រូចៅអធិការសុំលោកយកមកចិញ្ចឹម

៦. តើកត្តាអ្វីដែលនាំឱ្យព្រះបាទនរោត្តមសព្វព្រះទ័យតែងតាំងលោកសន្ធរម៉ុកជាចាងហ្វាងក្រុមព្រះអាល័ក្ស?

ក. លោកមានទេពកោលស្យខាងកាព្យ ខ. លោកពូកែយកព្រះទ័យព្រះរាជា

គ. មានមន្ត្រីចាំជួយជ្រោមជ្រែងលោក ឃ. លោកពូកែច្រៀង

៧. តាមរយៈអត្ថបទនេះ តើស្ថានភាពសង្គមខ្មែរសម័យកាលនោះមានលក្ខណៈបែបណា?

ក. មានសង្គ្រាមឥតឈប់ឈរ សេដ្ឋកិច្ចធ្លាក់ចុះ

ខ. មានសង្គ្រាមញឹកញាប់ ព្រះរាជាយកព្រះទ័យទុកដាក់លើវិស័យអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ

គ. ប្រជាជនរស់នៅសុខសាន្ត មានសេរីភាព

ឃ. ប្រជាជន និងព្រះមហាក្សត្រគ្មានសេរីភាព

៨. តើលោកឧកញ៉ាសន្ធរវោហាម៉ុកបានបន្សល់ទុកស្នាដៃអ្វីខ្លះ

ក. បទពង្សាវតារខ្មែរ និងរឿងទុំទាវ

ខ. រឿងទេវន្ត ព្រះសិង្ហនាថ រៃនិងស្រមោច និងព្រះរាជពង្សាវតារខ្មែរ

គ. រឿងកុលាប៉ៃលិន និង ប្រវត្តិសាស្ត្រខ្មែរ

ឃ. បទនគររាជ និង រឿងសូជាត

៩. តើកត្តាអ្វីដែលរុញច្រានកុមារម៉ុកឱ្យទទួលបានជោគជ័យក្នុងជីវិត?

ក. មានឪពុកជាមន្ត្រីក្នុងព្រះរាជវាំង ខ. ព្រះបាទនរោត្តមស្រឡាញ់

គ. មានស្នាដៃតែងនិពន្ធច្រើន ឃ. ឧស្សាហ៍ ព្យាយាម

១០. បើយោងតាមជីវប្រវត្តិលោកឧកញ៉ាសន្ធរវោហារម៉ុក តើតម្លៃរបស់មនុស្សស្ថិតនៅលើអ្វី?

ក. ពូជពង្សវង្សត្រកូល ខ. រូបសម្បត្តិ

គ. ទ្រព្យសម្បត្តិ ឃ. ចំណេះដឹង

១១. កំណាព្យ "ឆ្កែឆ្កួតបោលឆ្កឹតកន្ទុយឆ្កឹង ពាំឆ្ងឹងមាន់ភ្ញាងទៅស៊ីឆ្កុយ" មានអត្ថន័យសំដៅដល់អ្វី?

ក. រិះគន់មន្ត្រីខ្មែរ ខ. តិះដៀលមនុស្សដែលគ្មានចំណេះដឹង

គ. រិះគន់មន្ត្រីបារាំង ឃ. ខឹងសត្វឆ្កែដែលដណ្តើមចំណី

១២. ហេតុអ្វីបានជាលោកឧកញ៉ាសន្ធរវោហារម៉ុក តែងកំណាព្យតិះដៀលមន្ត្រីបារាំង?

ក. ដោយសារមន្ត្រីបារាំង ដណ្តើមមុខតំណែងលោក

ខ.ដោយសារមន្ត្រីបារាំងតែងធ្វើបាបជិះជាន់មន្ត្រីខ្មែរ

គ. ដោយសារមានគេបង្ខំឱ្យលោកតែង

ឃ. ដោយសារ លោកចង់បង្កើតស្នាដៃថ្មីបន្ថែម

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ រួចបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ ឧស្សាហ៍ ឧកញ៉ា ធ្យូង ព្រះបាទសម្តេចអង្គឌួង អាំព្រា សំណាង អុត សីហនុ

លោកឧកញ៉ាសន្ធរម៉ុក ជាកវីនិពន្ធមួយរូបក្នុងរាជព្រះបាទសម្តេចព្រះ.....។ លោកកើតនៅក្រុងឧដុង្គ ក្នុងគ. ស. ១៨៤៦។ បិតារបស់ លោកធ្វើជាមន្ត្រីក្នុងបរមរាជវាំងក្នុងរាជ្យ.....សម័យនោះជាកលិយុគដែល ប្រទេសយើងពើបប្រទះនឹងសង្គ្រាមជាមួយនឹងប្រទេសជិតខាងជាច្រើនឆ្នាំ ដូច្នេះបិតារបស់លោក។ គ្រួសារត្រូវទ័ពយួនកៀរយកទៅបាត់ ហើយខ្លួនលោកក៏ដល់នូវភាវៈជាកុមារ.....មាតាបិតា តាំងពីអាយុ ១១ឆ្នាំមក។ កុមារម៉ុកក្នុងពេលនោះមាន.....ដោយបានព្រះតេជគុណ ព្រះនាមអន ចៅអធិការវត្តគុកឬសយកទៅរក្សា និងឱ្យរៀនសូត្រក្នុងវត្តនោះរៀងម

ក។ កុមារនេះ..... រៀនសូត្រណាស់ ថ្វីបើពេលនោះគ្រឿងសម្ភារៈសម្រាប់រៀនសូត្រមិនបរិបូណ៌ក៏កុមារម៉ុកនៅតែរកគ្រឿងប្រដាប់រៀនបានដែរ ដោយគាត់យក..... ប្រើជំនួសដីស យកភ្លើងចង្រ្កានដែលដាំចំអិនអាហារ ឬចង្ហាន់ប្រគេនលោកគ្រូធ្វើជាគ្រឿងបំភ្លឺ។ល។ ឯរូបសម្បត្តិរបស់លោកវិញ គេតំណាលថា លោកមានរូបអាក្រក់ ស្បែកមុខសុសដោយស្នាម.....។ តាមអ្នកស្រាវជ្រាវបារាំងថា លោកសន្ធរម៉ុកបានទទួលគោរម្យងារហួតដល់ ឧកញ៉ាចៅហ្វាវាំង។

គ. ចូរផ្គូរផ្គងផ្នែក ក និងផ្នែកខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. ហានន្តរសក្តិ	ក. (កិ) : រៀវលែងជាបព្វជិត សឹកមកជាមនុស្សសាមញ្ញ លែងបួសតទៅទៀត។	១→ .....
២. កលិយុគ	ខ. (ន) : លំដាប់នៃទី មុខងារ ងារ ថ្នាក់ងារ ថ្នាក់សក្តិយស	២→.....
៣. គោរមងារ	គ. (ន) : ឈ្មោះក្រុមរាជការមួយក្រុមក្នុងបរមរាជវាំង មានមុខការជាអ្នកកត់ត្រាប្រាក់ព្រះរាជទ្រព្យផ្សេងៗ ។	៣→ .....
៤. ឈ្លើយ	ឃ. (ន) : កាលសម័យដែលប្រកបដោយទោស: ដោយវិបត្តិផ្សេងៗ ។	៤→ .....
៥. ក្រុមអាល័ក្ស	ង. (ន) : ពាក្យដ៏ឧត្តមបន្ថែមពីលើងារជាពាក្យសរសើរងារ សម្រាប់បើសរសេរចំពោតការចេញសំបុត្រដីកាធំៗ ។	៥→ .....
៦. អប្បលក្ខណ៍	ច. (ន) : រឿងរ៉ាវតាមលំដាប់នៃវង្សត្រកូល ប្រវត្តិដែលឆ្លងពីសង្កាត់មួយមក សង្កាត់មួយ ដំណើរសេចក្តីសំដែងអំពីតំណានវង្សត្រកូល ។	៦→ .....
៧. ពង្សាវតា	ឆ. (គុ) : ដែលប្រាសចាកយសគឺដែលខូចឈ្មោះ៖ ដែលឥតគរាប់ ដែលអាប់មុខ ។	៧→.....
៨. ចាកសិក្ខាបទ	ជ. (កិ. វិ) : ខ្ជឹម ដែលបអើតក្រអឺតឡើង ខ្ពើតឡើងត្រង់កន្ទុយ ។	៨→ .....
	ឈ. (គុ) : ដែលមានអាការៈព្រៃ ។	

ឃ. សំណួរត្រិះរិះ

១. បើយោងទៅតាមស្នាដៃរបស់លោកសន្ធរម៉ុកតើអ្នកទទួលបានតម្លៃអប់រំយ៉ាងណាខ្លះ ?

.....

.....

.....

.....

.....

.....

.....

.....

២. តើបទពិសោធន៍ជីវិតលោកសន្ធរម៉ុកអាចធ្វើជាគំរូសម្រាប់ជីវិតអ្នកបានដែរឬទេ? ព្រោះអ្វី?

.....

.....

.....

.....

.....

.....

.....

៣. ចូរអ្នកបង្ហាញឱ្យឃើញពីខ្លឹមសារនិងទឹកដមនៃស្នាដៃរបស់ការីដែលមានក្នុងឧទាហរណ៍ខាងក្រោម :

ក. ឆ្កែឆ្កួតបោលឆ្កួតកន្ទុយឆ្នឹង ពាំឆ្នឹងមាន់ឆ្កាងទៅស៊ីឆ្កុយ ...

ខ. ពើយអាថិកឱ្យសាច់មួយកាក់ អាចឹកកន្ត្រាក់បានសាច់ខ្វៃ

អារខ្វាច់ហាន់ខាប់សាប់ញាប់ដៃ ពើយលៃឱ្យឆាប់ប្រញាប់ឆាន់ ។

គ. បារាំងបារាំចោរអបលក្ខណ៍ ហ៊ានលើកជើងធាក់អាល័ក្សហ្លួង...។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

ការស្តាប់ ៖ ជីវិតលើឆាក

ក្រឡាហោមគង់ ជាមន្ត្រីខ្មែរស្នេហាជាតិមួយរូប មានទឹកចិត្តក្លាហានមោះមុតហ៊ាន តស៊ូប្រឆាំងការគាបសង្កត់របស់អាណានិគមនិយមបារាំង។ បារាំង ក្តាប់គោលជំហរនិង គំនិតរើបម្រះរបស់លោកបាន ក៏រកមធ្យោបាយចាប់គាត់ដាក់កប៉ាល់យកទៅសម្លាប់ ដោយ សម្ងាត់។

ព្រះទិនករនៅប៉ប្រះមាត់ព្រៃ ពុំទាន់អស្តង្គតនៅឡើយទេ។ អរុណរង្សីនៅភ្លឺច្រាល ចាំងមកលើរាជធានីភ្នំពេញជាទីអវសាន។ ក្រឡាហោមគង់អង្គុយនៅត្រមង់ត្រមោចឯក ឯងលើនាវាមានទឹកមុខក្រៀមក្រំជាពន្លឹក ខំប្រឹងសម្លឹងមើលត្រើយខាងលិច។ ទិដ្ឋភាពដ៏ ស្រស់ឆើតឆាយនៃរាជធានីភ្នំពេញ បានអង្រួនបេះដូងក្រឡាហោមគង់ឱ្យញាប់ញ័ររន្ធត់ ទឹក ភ្នែកហូរសស្រាក់នឹកស្តាយស្រណោះ ទឹកដីអាណិតខ្មែរដែលត្រូវបរទេសគាបសង្កត់។ កប៉ាល់បើកឃ្លាតពីវត្តឧណ្ណាលោម ឆ្ពោះត្រង់ទៅទិសខាងជើង។ ព្រះសុរិយាក៏ស្រឹបបាត់ទៅ មិនយូរប៉ុន្មានស្បៃអន្ធការក៏ចូលមកគ្របលើផែនពសុធាមើលអ្វីលែងឃើញទាំងអស់។ មុខគូរឱ្យសង្វេគពន់ពេក នៅលើកប៉ាល់ក្រឡាហោមគង់ ដៃនិងជើងាប់ច្រវាក់ពីពុំរួច បាន ត្រឹមតែនិយាយតិចៗម្នាក់ឯង ៖ « ឱទឹកដីខ្មែរ ពេលខ្ញុំរលត់សង្ខារ ទៅ តើអ្នកនឹងទៅជាយ៉ាង ណា។ ឪពុកម្តាយបងប្អូនរួមលោហិត ប្រហែលជាមិនបានដឹងផងទេ។ នេះគឺជាការព្យាបាទ របស់ជាតិបរទេស សូមឱ្យកូនខ្មែរស្នេហាជាតិទាំងឡាយខិតខំតស៊ូទាមទារឯករាជ្យឱ្យបាន ជូនមាតុភូមិ »។

ការបាត់បង់វីរជនស្នេហាជាតិរូបនេះ បានធ្វើឱ្យព្រះសង្ឃ បញ្ញវន្ត មហាជន។ល។ មានការសោកស្តាយអាណិតអាសូរក្រៃលែង។ វីរភាពរបស់លោក បានបំផុសទឹកចិត្តកូន ខ្មែរឱ្យក្រោកឈរឡើង ប្រឆាំងនឹងពួកបរទេសឈ្លានពានវាតទីនិយមជាបន្តបន្ទាប់។ ក្រឡាហោមគង់ បានលាចាកលោកនេះមែន ប៉ុន្តែកិត្តិនាមនិងវីរភាពរបស់លោកបានមក សណ្ឋិតជាប់នឹងដួងព្រលឹងកូនខ្មែរជានិរន្តរ៍។

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១. តើចំណងជើងអត្ថបទជីវិតលើនាវា ចង់បង្ហាញពីអ្វី?

ក. ជីវិតមនុស្សនៅក្នុងទីក្រុង ខ. ជីវិតមនុស្សនៅលើអាកាស

គ. ជីវិតរស់នៅក្បែរជាយដែន ឃ. ជីវិតវីរជនស្នេហាជាតិនៅលើកប៉ាល់

២. តើលោកឧកញ៉ាក្រឡាហោមគង់ជាអ្នកណា?

ក. លោកជាហោរាដ៏ល្បីល្បាញ ខ. លោកជាមេទ័ពស្នេហាជាតិខ្មែរ

គ. លោកជាគ្រូពេទ្យ ឃ. លោកជាគ្រូបង្រៀន

៣. តើហេតុអ្វីបានជាលោកឧកញ៉ាក្រឡាហោមគង់ត្រូវគេចងនៅលើកប៉ាល់?

ក. បារាំងចង់សម្លាប់លោក ខ. បារាំងចង់នាំលោកទៅប្រទេសបារាំង

គ. លោកមិនចង់នៅស្រុកខ្មែរ ឃ. លោកចង់កម្សាន្តនៅលើកប៉ាល់

៤. តើមូលហេតុអ្វី បានជាបារាំងចង់សម្លាប់លោកឧកញ៉ាប្រឡាហោមគង់?

ក. ព្រោះលោកឧកញ៉ាក្រឡាហោមគង់ជាខ្លោងបះបោរប្រឆាំងនឹងបារាំង

ខ. ព្រោះបារាំងចង់បានតំណែងជាមេទ័ពរបស់លោកឧកញ៉ាក្រឡាហោមគង់

គ. ព្រោះមានអ្នកបញ្ជាឱ្យបារាំងសម្លាប់លោកឧកញ៉ាក្រឡាហោមគង់

ឃ. ព្រោះប្រជាជនខ្មែរស្អប់លោកឧកញ៉ាក្រឡាហោមគង់

៥. ហេតុអ្វីបានជាលោកឧកញ៉ាក្រឡាហោមគង់មិនចុះចូលនឹងពួកបារាំង?

ក. បារាំងមិនអនុញ្ញាតឱ្យលោកចុះចូល

ខ. មានអ្នករារាំងលោក មិនឱ្យចុះចូលបារាំង

គ. បារាំងមិនផ្តល់ផលប្រយោជន៍ដល់លោក

ឃ. លោកខឹងនឹងបារាំងដែលធ្វើបាបប្រជាជនខ្មែរ

៦. តើបារាំងសម្លាប់លោកឧកញ៉ាក្រឡាហោមគង់ដោយវិធីណា?

ក. បាញ់សម្លាប់ ខ. បោះទម្លាក់ទឹក

គ. កប់ទាំងរស់ ឃ. ចងផ្ដោបបំពង់ផ្សែងកប៉ាល់

៧. តើទិដ្ឋភាពតាមដងទន្លេធ្វើឱ្យក្រឡាហោមគង់មានអារម្មណ៍ដូចម្ដេច?

ក. លោកមានអារម្មណ៍សប្បាយរីករាយ ខ. លោកមានអារម្មណ៍ស្អប់ស្រុកខ្មែរ

គ. លោកមានអារម្មណ៍ស្ដាយស្រណោះ ឃ. លោកមានអារម្មណ៍ភ័យខ្លាច

៨. តាមរយៈអារម្មណ៍ទាំងនោះ ឆ្លុះបញ្ចាំងថាលោកឧកញ៉ាក្រឡាហោមគង់ជាបុគ្គលបែបណា?

ក. លោកជាមន្ត្រីស្នេហាជាតិ ខ. លោកជាមន្ត្រីក្បត់ជាតិ

គ. លោកជាមន្ត្រីកំសាក ឃ.លោកជាមន្ត្រីគិតតែប្រយោជន៍ផ្ទាល់ខ្លួន

៩.តើស្ថានភាពសង្គមខ្មែរនាសម័យនោះមានលក្ខណៈបែបណា?

ក. សង្គមខ្មែរមានសន្តិភាព ខ. សង្គមខ្មែររីកចម្រើន

គ. សង្គមខ្មែរស្ថិតក្នុងគ្រោះថ្នាក់ធម្មជាតិ ឃ. សង្គមខ្មែររងទុក្ខវេទនា

១០. តើចំណុចមួយណាជាតម្លៃអប់រំនៅក្នុងអត្ថបទការស្លាប់ ជីវិតលើនាវា?

ក. អប់រំយើងឱ្យស្រឡាញ់ជាតិមាតុភូមិ

ខ. អប់រំយើងឱ្យមានភក្តីភាពចំពោះមិត្ត

គ. អប់រំយើងឱ្យស្រឡាញ់ការសិក្សា

ឃ. អប់រំយើងឱ្យខិតខំតស៊ូជម្នះឧបសគ្គក្នុងជីវិត

១១. ខាងក្រោមជាមូលហេតុដែលនាំឱ្យលោកឧញ៉ាក្រឡាហោមគង់តស៊ូរើបម្រះពីការត្រួតត្រារបស់បារាំង លើកលែងតែ៖

ក. បារាំងគាបសង្កត់ជិះជាន់លើព្រះមហាក្សត្រ

ខ. បារាំងគាបសង្កត់យកពន្ធលើសលប់ពីប្រជាជន

គ. លោកចង់ទាមទារសិទ្ធសេរីភាពជូនប្រជាពលរដ្ឋ

ឃ. លោកចង់កសាងកេរ្តិ៍ឈ្មោះឱ្យបានល្បីល្បាយដល់អ្នកជំនាន់ក្រោយ

ខ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ រួចបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ ព្រះឥន្ទករ ស្នេហាជាតិ ឥរិយាបថ អភិក្កមណ៍ អរុណរះឡើ

ក្រឡាហោមគង់ ជាមន្ត្រីខ្មែរ..... មួយរូប មានទឹកចិត្តក្លាហានមោះមុតហ៊ាន តស៊ូប្រឆាំងការគាបសង្កត់របស់អាណានិគមនិយមបារាំង។ បារាំងក្តាប់គោលជំហរ និង គំនិតរើបម្រះរបស់លោកបាន ក៏រកមធ្យោបាយចាប់គាត់ដាក់កប៉ាល់យកទៅសម្លាប់ដោយសម្ងាត់។ .....នៅប៉ប្រះមាត់ព្រៃ ពុំទាន់អស្តង្គតនៅឡើយទេ។ .....នៅភ្លឺច្រាល ចាំងមកលើរាជធានីភ្នំពេញជាទីអវសាន។ ក្រឡាហោមគង់អង្គុយនៅត្រមង់ត្រមោចឯក ឯងលើនាវាមានទឹកមុខក្រៀមក្រំជាពន្លឺក ខំប្រឹងសម្លឹងមើលត្រើយខាងលិច។ ទិដ្ឋភាពដ៏ ស្រស់ឆើតឆាយនៃរាជធានីភ្នំពេញ បានអង្រួនបេះដូងក្រឡាហោមគង់ឱ្យញាប់ញ័ររន្ធត់ ទឹកភ្នែកហូរសស្រាក់នឹកស្តាយស្រណោះ ទឹកដីអាណិតខ្មែរដែលត្រូវបរទេសគាបសង្កត់។

ការបាត់បង់វីរជន..... រូបនេះ បានធ្វើឱ្យព្រះសង្ឃ បញ្ញវន្ត មហាជន។ ល។ មានការសោកស្តាយអាណិតអាសូរក្រៃលែង។ .....របស់លោក បានបំផុសទឹកចិត្តកូន ខ្មែរឱ្យក្រោកឈរឡើង ប្រឆាំងនឹងពួកបរទេសឈ្លានពានវាតទីនិយមជាបន្តបន្ទាប់។ ក្រឡាហោមគង់ បានលាចាកលោកនេះមែន ប៉ុន្តែ..... និង ..... របស់លោកបានមក សណ្តែតជាប់នឹងដួងព្រលឹងកូនខ្មែរជានិរន្តរ៍។

គ. ចូរផ្គូរផ្គងផ្នែក ក និងផ្នែកខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. អស្តង្គត	ក. ទីបំផុត ទីបញ្ចប់ ចុងបំផុត។	១→ .....

២. នាវា	ខ. ព្រះអាទិត្យ ។	២→ .....
៣. សង្វៃគ	គ. អ្នកមានប្រាជ្ញា អ្នកយកចិត្តទុកដាក់ប្រើគំនិតត្រិះរិះក្នុងកិច្ចការគ្រប់ជំពូក។	៣→ ....
៤. បញ្ញវន្ត	ឃ. ឯកឯង។	៤→.....
៥. អវសាន	ង. សេចក្តីស្លុតចិត្ត ដំណើរតក់ស្លុត ការរំពឹងឃើញសេចក្តីទុក្ខលំបាក។	៥→.....
៦. ព្រះទិនករ	ច. ធ្លាក់ចុះបាត់ទៅ លិចបាត់ទៅ បាត់ពន្លឺ។	៦→.....
៧. ត្រមង់ត្រមោច	ឆ. លើកទាញ ឬលាត់សម្លៀកឱ្យខើចឡើង។	៧→ ....
	ជ. ទូក សំពៅ កប៉ាល់។	

ឃ. សំណួរត្រិះរិះ

១. ចូរសង្ខេបអត្ថបទឡើងវិញ ជាផែនទីគំនិត។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. ចូររៀបរាប់ឈ្មោះវីរជនស្នេហាជាតិ៥រូប ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងលោកឧកញ៉ាក្រឡាហោមគង់។

.....

.....

.....

.....

.....

.....

៣. តើអត្ថបទនេះផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

🕯 បំណិន ៖ ការសម្ភាសន៍បុគ្គលសំខាន់ក្នុងសហគមន៍

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១. ដូចម្តេចដែលហៅថារបាយការណ៍សម្ភាស?

ក. ជាអត្ថបទសរសេរពីរឿងព្រេង ខ. ជាអត្ថបទសរសេរពីរឿងល្ខោន

គ. ជាអត្ថបទសរសេរពីរឿងប្រលោមលោក ឃ. ជាអត្ថបទសរសេរតាមការសាកសួរ

២. តើសំណេររបាយការណ៍សម្ភាសចែកជាប៉ុន្មានផ្នែកសំខាន់ៗ?

ក. ២ផ្នែក ខ. ៣ផ្នែក

គ. ៤ផ្នែក ឃ.៥ផ្នែក

៣. តើចំណុចមួយណា ដែលស្ថិតនៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍សម្ភាស?

ក. កាលបរិច្ឆេទ ខ. ចំណាប់អារម្មណ៍

គ. ស្ថានភាពគ្រួសារ ឃ. ការថ្លែងអំណរគុណ

៤. តើចំណុចខាងក្រោម មួយណាដែលស្ថិតនៅក្នុងខ្លឹមសាររបាយការណ៍សម្ភាស?

ក. ការសន្និដ្ឋាន ខ. សម្តែងការគួរសម

គ. ស្ថានភាពជីវិត ឃ. ការថ្លែងអំណរគុណ

៥. តើចំណុចខាងក្រោមមួយណា ដែលត្រូវបង្ហាញនៅខាងចុងបំផុតនៃរបាយការណ៍សម្ភាស?

ក. ចំណាប់អារម្មណ៍អ្នកដែលត្រូវសម្ភាស ខ. ការសន្និដ្ឋាន

គ. សារប្រយោជន៍នៃការសម្ភាស ឃ. គោលបំណងនៃការសម្ភាស

ខ. ចូរជ្រើសរើសពាក្យខាងក្រោម រួចបំពេញតាមផ្នែកនីមួយៗ ឱ្យបានត្រឹមត្រូវ

☞ ភួងាទីនិងស្លាដៃ ចំណាប់អារម្មណ៍ កាលបរិច្ឆេទ ទីកន្លែង ស្ថានភាពគ្រួសារ គោលបំណង មុខរបរ ទីកន្លែងកំណើត ការសន្និដ្ឋាន

ផ្តើមរបាយការណ៍	ខ្លឹមសាររបាយការណ៍	បញ្ចប់របាយការណ៍
ឧ.កាលបរិច្ឆេទ		

ឃ. សំណួរត្រិះរិះ

១. ចូរសរសេរគម្រោងសំណេររបាយការណ៍សម្ភាស។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. ចូរប្អូនសរសេររបាយការណ៍សម្ភាសបុគ្គលណាម្នាក់ ដែលប្អូនធ្លាប់បានស្គាល់ ហើយចាត់ថាជាបុគ្គលគំរូ គួរយកតម្រាប់តាម។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

๑๙ មេរៀនទី២ ភាពស្មោះត្រង់ ๑๙

🕯 បំណិនៈ លក្ខណៈសម្គាល់រឿងព្រេងបុរាណខ្មែរ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវ

១. ដូចម្តេចដែលហៅថារឿងព្រេងនិទានបុរាណខ្មែរ?

ក. ជារឿងល្ខោន ខ. ជារឿងប្រលោមលោក

គ. ជារឿងពិត ឃ. ជារឿងប្រឌិត

២. តើរឿងព្រេងនិទានបុរាណខ្មែរ ត្រូវផ្តោតទៅលើអ្វីខ្លះ?

ក. បញ្ហាចោទ និងដំណោះស្រាយ ខ. សង្គមបរិយាកាស និងកាលកំណត់តែង

គ. តួអង្គ និងកាលអាកាស ឃ. អត្ថន័យ និងអត្ថរស

៣. តើលក្ខណៈសម្គាល់មួយណា ដែលស្ថិតនៅក្នុងផ្នែកអត្ថន័យ?

ក. នាដ្យរស ខ. ការប្រើពាក្យពេចន៍

គ. សង្គមបរិយាកាស ឃ. ការផ្តើមរឿង

៤. តើលក្ខណៈសម្គាល់មួយណាដែលស្ថិតនៅក្នុងផ្នែកអត្ថរូប?

ក. ការផ្តើមរឿង ខ. សង្គមរស

គ. តម្លៃអប់រំ ឃ. បញ្ហាចោទ

៥. តើលក្ខណៈសម្គាល់មួយណាដែលស្ថិតនៅក្នុងផ្នែកអត្ថរស?

ក. មូលបញ្ហារឿង ខ. តថរស

គ. ដំណោះស្រាយ ឃ. ដំណើររឿង

៦. តើរឿងព្រេងនិទានបុរាណខ្មែរ មានគោលបំណងអប់រំមនុស្សអំពីអ្វី?

ក. មិនឱ្យលោភលន់ ខ. ឱ្យស្អប់សង្គម

គ. ត្រូវគិតពីប្រយោជន៍ខ្លួនជាធំ ឃ. មិនឱ្យគោរពប្រពៃណី

៧. ក្នុងចំណោមរឿងខាងក្រោម តើរឿងណាខ្លះជារឿងនិទានបុរាណខ្មែរ?

ក. រឿងចចក រឿងកុក និងក្អែក រឿងត្រីចំពុះដាវ

ខ. រឿងមិត្តសានិត រឿងបុរសនិងស្តា រឿងទន្សាយចង់ស៊ីចេក

គ. រឿងអ្នកតាទឹកអ្នកតាភ្នំ រឿងមាយាស្ត្រី រឿងមាយើង

ឃ. រឿងចៅចាក់ស្មុគ រឿងខ្ទុំខុសហើយ រឿងសង្គ្រាមរវាគីង្គក់និងតាព្រហ្ម

៨. តើចម្លើយមួយណា ជានិយមន័យនៃរឿងព្រេងនិទានបុរាណខ្មែរ?

ក. ជារឿងប្រឌិត កើតឡើងជាក់ស្តែងបង្ហាញពីសង្គមខ្មែរសម័យកាលណាមួយ

ខ. ជារឿងប្រឌិត កើតក្នុងសម័យកាលយូរណាស់មកហើយ បង្ហាញពីទំនាស់បន្តិចបន្តួច

គ. ជារឿងប្រឌិត ដែលនិយាយពីប្រវត្តិសាស្ត្រពិតសម័យណាមួយ

ឃ. ជារឿងប្រឌិត ដែលនិយាយពីទំនាស់អ្វីមួយក្នុងសង្គមមានតួអង្គពិតក្នុងសង្គម

ខ. ចូរជ្រើសរើសពាក្យខាងក្រោម រួចបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ ប្រវត្តិសាស្ត្រ អាទ្វាក់អាទ្វិន បញ្ហាវិបត្តិ ត្រីចំពុះដាវ ប្រពៃណីជាតិ ស្រុក ទឹក ក្រុងភ្នំពេញ

រឿងព្រេងនិទានបុរាណខ្មែរជារឿងប្រឌិត ដែលលើកយក..... ទំនាស់នៅក្នុងគ្រួសារ សង្គម ក្នុងសម័យកាលដ៏យូរលង់មកហើយនៃ..... ហើយជារឿងនិទានប្រាប់តៗគ្នាពីមាត់មួយទៅមាត់មួយ ក្លាយជាទីនិយមចូលចិត្ត ជក់អារម្មណ៍ ហើយចេះចាំស្ទាត់គ្រប់គ្នា។

រឿងព្រេងនិទានបុរាណខ្មែរ មានគោលបំណងអប់រំមនុស្ស ឱ្យស្រលាញ់យុត្តិធម៌ ប្រព្រឹត្តអំពើល្អ លះបង់អំពើអាក្រក់ ស្រឡាញ់ចំណេះវិជ្ជា ចេះជួយគ្នា អត់ឱនគ្នា ទៅវិញទៅមក គោរពស្រឡាញ់..... ។ល។ រឿងព្រេងនិទានខ្មែរមានដូចជារឿងចចក រឿង

..... រឿង ..... ។ ចំណែកឯរឿងមួយចំនួនទៀត ដូចជារឿង ..... និង.....។ល។ មិនចាត់ជារឿងព្រេងនិទានបុរាណខ្មែរទេ ព្រោះរឿងទាំងនេះជារឿងបរទេស ដែលត្រូវបានប្រែសម្រួលមកជាភាសាខ្មែរតែប៉ុណ្ណោះ។

គ. ចូរផ្គូផ្គងផ្នែក ក និងផ្នែកខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. សង្គមបរិយាកាស	ក. ទំនាស់ វិបត្តិដែលអ្នកនិពន្ធចោទបំផុសឡើងនៅក្នុងរឿងតាមរយៈវិវាទតួអង្គ និងតួអង្គ។	១ →.....
២. កាលអាកាស	ខ. ទិដ្ឋភាព នៃរឿងដែលអ្នកនិពន្ធបានរៀបរាប់ពីការរស់នៅ ការប្រកបអាជីវកម្ម ជំនឿ ប្រពៃណីទំនៀមទម្លាប់ ការគ្រប់គ្រង និងទំនាក់ទំនងសង្គមក្នុងសម័យកាលណាមួយ។	២ →.....
៣. ចលនារឿង	គ. គំនិតអប់រំមនុស្សទូទៅឱ្យស្រលាញ់យុត្តិធម៌ ប្រព្រឹត្តអំពើល្អ លះបង់អំពើអាក្រក់ ស្រលាញ់វិជ្ជា មិនលោភលន់។ល។	៣ →.....
៤. បញ្ហាចោទ	ឃ. ការបញ្ចប់វិវាទតួអង្គ និងតួអង្គ តៅតាមគោលគំនិត ឬទស្សនៈរបស់អ្នកនិពន្ធ។	៤ →.....
៥. ដំណោះស្រាយ	ង. ទម្រង់ផ្សេងៗនៃអក្សរសិល្ប៍ ដែលស្ថិតនៅក្រោមឥទ្ធិពលនៃលទ្ធិ ឬលោកទស្សនៈណាមួយ។	៥ →.....
៦. តម្លៃអប់រំ	ច. ពេលវេលា ឬទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ។	៦ →.....
	ឆ. ផ្នែកមួយនៃអក្សរសាស្ត្រ ដែលអ្នកនិពន្ធលើកយកបញ្ហាមនុស្ស បញ្ហាសង្គមមកចោទ និងដោះស្រាយដោយប្រើសិល្ប៍វិធី។	

ឃ. សំណួរត្រិះរិះ

១. តើព្រេងកថា មានលក្ខណៈខុសពីទេវកថាយ៉ាងណាខ្លះ?

ក.ព្រេងកថា

.....

.....

.....

ខ.ទេវកថា

.....

.....

.....

២. ចូរបង្ហាញលក្ខណៈសម្គាល់រឿងចចក។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

🕮 អំណានៈ រឿងមាយើង

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទកាព្យរឿងមាយើង ជាប្រភេទរឿងអ្វី?

ក. រឿងព្រេង ខ. រឿងល្ខោន

គ. រឿងបរទេស ឃ. រឿងប្រលោមលោក

២. តើមាយើងជាអ្នកណា?

ក. ជាសេនាព្រះរាជា ខ. ជាបុត្រព្រះរាជា

គ. ជាព្រះបិតុលាព្រះរាជា ឃ. ជាអ្នកទោសរបស់ព្រះរាជា

៣. មូលហេតុអ្វីបានជា ទេវតារក្សាដើមជ្រៃចង់ធ្វើគុតព្រះរាជា?

ក. ច្រណែនព្រះរាជា ខ. ចង់បានទ្រព្យសម្បត្តិ

គ. ខឹងព្រះរាជា ឃ. ចង់បានតំណែងព្រះរាជា

៤. តើទេវតារក្សាដើមជ្រៃ មានគម្រោងធ្វើគុតព្រះរាជាប៉ុន្មានលើក?

ក. ២លើក ខ. ៣លើក

គ. ៤លើក ឃ. ៥លើក

៥. តើទេវតារក្សាដើមជ្រៃចង់ធ្វើគុតព្រះបាទព្រហ្មទត្តលើកទី១ ដោយវិធីណា?

ក. រុញព្រះបាទព្រហ្មទត្តចូលរណ្តៅ ខ. ដាក់ថ្មាំបំពុលព្រះបាទព្រហ្មទត្ត

គ. វាយបំបាក់ស្លាងទ្វារឱ្យសង្កត់លើព្រះរាជា ឃ. កាច់មែកជ្រៃឱ្យសង្កត់លើព្រះរាជា

៦. តើទេវតារក្សាដើមជ្រៃចង់ធ្វើគុតព្រះបាទព្រហ្មទត្តនៅលើកទី២ដោយវិធីណា?

ក. វាយបំបាក់ស្លាងទ្វារឱ្យសង្កត់លើព្រះរាជា ខ. កាច់មែកជ្រៃឱ្យសង្កត់លើព្រះរាជា

គ. ពន្លិចទូកដែលព្រះរាជាជិះ ឃ.កាឡាខ្លួនជាសត្វពស់ឱ្យចឹកព្រះរាជា

៧. តើទេវតារក្សាដើមជ្រៃចង់ធ្វើគុតព្រះបាទព្រហ្មទត្តនៅលើកទី៣ដោយវិធីណា?

ក. សន្តំព្រះរាជាឱ្យធ្វំជារៀងរហូត ខ. កាច់បំបាក់កព្រះរាជា

គ. កាឡាខ្លួនជាសត្វពស់ឱ្យចឹកព្រះរាជា ឃ. រុញព្រះបាទព្រហ្មទត្តចូលរណ្តៅ

៨. តើមាយើងអាចជួយព្រះរាជាឱ្យរួចផុតពីគ្រោះថ្នាក់ដោយរបៀបណា?

ក. មាយើងស្តាប់ឮឧបាយកលទេវតារក្សាដើមជ្រៃពេលជំនុំគ្នា

ខ. មាយើងគម្រាមទេវតារក្សាដើមជ្រៃឱ្យបញ្ឈប់រាល់សកម្មភាពទាំងអស់

គ. មានមនុស្សជួយមាយើងឱ្យយកឈ្នះលើទេវតារក្សាដើមជ្រៃ

ឃ. មាយើងចាប់ព្រះរាជាឃុំក្នុងកន្លែងដែលមានសុវត្ថិភាព

៩. តើក្នុងរឿងមាយើងបង្កប់គំនិតសំខាន់យ៉ាងណា?

ក. ការដឹកនាំ ខ. ការធ្វើជំនួញ

គ. ភាពលោភលន់ ឃ. ភាពស្មោះត្រង់

១០. តើអ្នកយល់ថា តួអង្គមាយើងជាមនុស្សបែបណា?

ក. ខ្ជិលច្រអូស ខ. លោភលន់

គ. កំសាក ឃ. មានភក្តីភាព

១១. តើមូលហេតុអ្វីបានជាមាយើងចេញមុខជួយព្រះរាជាពេលព្រះអង្គមានគ្រោះថ្នាក់?

ក. ពីព្រោះមាយើងជាសេនាដ៏ស្មោះត្រង់របស់ព្រះរាជា

ខ. ពីព្រោះមានតែមាយើងម្នាក់ដែលមានសមត្ថភាពជួយព្រះរាជា

គ. ពីព្រោះភរិយាមាយើងបង្ខំមាយើងឱ្យជួយ

ឃ. ពីព្រោះគ្មានអ្នកណាស្ម័គ្រចិត្តជួយព្រះរាជា

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

- តួអង្គមាយើងជាមនុស្សដែលមានលក្ខណៈសម្បត្តិដូចតទៅ៖

.....

.....

.....

.....

.....

.....

.....

.....

- តួអង្គព្រះបាទព្រហ្មទត្តជាមនុស្សដែលមានលក្ខណៈសម្បត្តិដូចតទៅ៖

.....

.....

.....

.....

.....

.....

.....

- តួអង្គទេវតារក្សាដើមជ្រៃ ជាតួអង្គដែលមានលក្ខណៈសម្បត្តិដូចតទៅ៖

.....

.....

.....

.....

.....

.....

.....

.....

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១.ជវ័ន	ក. (គុ.) ដែលធំចម្បង ជាកំពូលលើគេ ជាម្ចាស់លើគេ។	១→.....
២.ព្រះភូធរវរាជ	ខ. (គុ.) ដែលមានច័យជម្មៈលើអ្នកដែលជាចម្បង។	២→.....
៣.ព្រះថនា	គ. (ន.) អ្នកគ្រប់គ្រងរក្សាផែនដី។	៣→.....
៤.ជៀសជ័យ	ឃ. (ន.) កម្លាំងដែលស្ទុះលឿន។	៤→.....
៥.ឥស្សរ	ង. (ន.) ព្រះរាជាអ្នកទ្រទ្រង់នៅលើផែនដី។	៥→.....
៦.ភូបាល	ច. (ន.) សុដន់ ដោះ។	៦→.....
៧.មរណ៍	ឆ. (ន.) សេះ។	៧→.....
៨.អស្សរ	ជ. (គុ.) ដែលខ្ពង់ខ្ពស់ ប្រសើរថ្លៃថ្លា។	៨→.....
	ឈ. (ន.) សេចក្តីមរណៈ សេចក្តីស្លាប់	

ឃ. សំណួរត្រិះរិះ

១. តើក្នុងរឿងមាយើង មានតម្លៃអប់រំយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

២. ចូរបង្ហាញពីលក្ខណៈសម្គាល់រឿងមាយើង។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

⊶ វេយ្យាករណ៍៖ សញ្ញាដំពីរ (ះ)

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. ដូចម្តេចដែលហៅថាសញ្ញាដំពីរ?

ក. ជាសញ្ញាប្រើជំនួសព្យញ្ជន: ខ. ជាសញ្ញាប្រើជំនួសស្រៈ:

គ. ជាសញ្ញាសម្រាប់បង្ក្រៀញន័យ ឃ. ជាសញ្ញាប្រើសម្រាប់ពង្រីកន័យ

២. តើសញ្ញាដំពីរ មានរូបរាងដូចម្តេច?

ក. (ុំ) ខ. (ៈ)

គ. (ះ) ឃ. (ៈះ)

៣. តើសញ្ញាដំពីរមានមុខងារប៉ុន្មានយ៉ាង?

ក. ៣ យ៉ាង ខ. ៤ យ៉ាង

គ. ៥ យ៉ាង ឃ. ៦ យ៉ាង

៤.តើសញ្ញាដំពីរដែលនៅក្នុងល្បះខាងក្រោមមានមុខងារអ្វី?

ល្បះមានបួនបែប ៖ ល្បះបង្ហាក់ ល្បះបង្ហា ល្បះសំណូរ និងល្បះឧទាន។

ក. ពង្រីកសេចក្តី ខ. សម្រង់សេចក្តី

គ. សម្តីផ្ទាល់ ឃ. សេចក្តីពន្យល់

៥. តើល្បះមួយណាដែលប្រើសញ្ញាដំពីរបង្ហាញពីសម្តីផ្ទាល់?

ក. ខ្ញុំមានបិកពីរដើម៖ ក្រហម និងខៀវ។

ខ. មាតាបិតាមានគុណ៖ លោកជាអ្នកចិញ្ចឹមកូន។

គ. បំរាមនោះមានជាអាទិ៍៖ សិស្សទាំងអស់ត្រូវមករៀន។

ឃ. មាយើងនិយាយ៖ "សូមស្តេចយាងគង់លើខ្នងសេះ"។

៦. តើសញ្ញាដំពីរដែលនៅក្នុងល្បះខាងក្រោម មានមុខងារអ្វី?

នៅទីនេះសម្បុរបក្សាបក្សីហើរឆ្វែលឆ្ងាត់៖មៀម ទីទុយ ខ្លែងស្រាក។

ក. ពង្រីកសេចក្តី ខ. សម្រង់សេចក្តី

គ. សម្តីផ្ទាល់ ឃ.សេចក្តីពន្យល់

៧. តើសញ្ញាដំពីរដែលនៅក្នុងល្បះខាងក្រោម មានមុខងារអ្វី?

អត្តបទនោះសរសេរជាអាទិ៍៖មនុស្សម្នាក់ៗត្រូវរស់នៅដោយថ្លៃថ្នូរ។

ក. សម្រង់សេចក្តី ខ. ពង្រីកសេចក្តី

គ. សម្តីផ្ទាល់ ឃ. សេចក្តីពន្យល់

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ **ពង្រីកសេចក្តី សម្រង់សេចក្តី សម្តីផ្ទាល់ សេចក្តីពន្យល់**

១. .....៖ អត្តបទអាជ្ញរ៖គឺការត្រង់ បានបង្ហាញថា "...ការគិត គឺជាចេតនារបស់អ្នកធ្វើ ដែលនឹងធ្វើឱ្យអ្នកផងយល់ថា សំដីឬ ពាក្យនិយាយ គឺបដិញ្ញាកម្ម ធ្វើឱ្យអ្នកដទៃបានឮ ឬបានឃើញ។

២.....៖ ឪពុកខ្ញុំបានប្រាប់ថា "ការអានសៀវភៅមានសារសំខាន់បំផុត ព្រោះវាអាចនាំឱ្យយើងបានឃើញពិភពលោកបានកាន់តែច្រើនជាងមុន។

៣. .....៖ ព្រហ្មវិហារធម៌មានបួន នោះគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា។

៤. .....៖ ក្នុងនាមជាសិស្សានុសិស្ស ប្អូនៗត្រូវខិតខំរៀនសូត្រ។ ការរៀនសូត្រនឹងធ្វើឱ្យជីវិតមនុស្សបានល្អប្រសើរ មានចំណេះដឹង មានសមត្ថភាព មានការងារល្អ មានសីលធម៌ និងមានសុភមង្គលក្នុងជីវិត។

គ. សំណួរត្រិះរិះ

១. ចូរតែងល្បះដោយប្រើសញ្ញាដំពីរតាមមុខងារទាំង៤ ឱ្យបាន២ល្បះ ក្នុងមួយមុខងារ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ អត្ថន័យ៖ គឺការត្រង់

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអាជ្ជវៈមានន័យដូចម្តេច?

ក. ទាន ខ. បុណ្យ

គ. សីល ឃ. ត្រង់

២. តើសេចក្តីត្រង់របស់មនុស្ស មានប៉ុន្មានប្រការ?

ក. ៣ ប្រការ ខ. ៤ ប្រការ

គ. ៥ ប្រការ ឃ. ៦ ប្រការ

៣. តើយើងត្រូវមើលលើអ្វី បើយើងចង់ដឹងថាមនុស្សណាត្រង់ ឬមិនត្រង់?

ក. រូបរាង ខ. មុខរបរ

គ. ទង្វើ ឃ. ដំណើរ

៤.តើហេតុអ្វីបានជាមនុស្ស ត្រូវប្រកាន់យកសេចក្តីត្រង់?

ក. ដើម្បីបានតំណែងធំ ខ. ដើម្បីយកចិត្តថ្លើមអ្នកដទៃ

គ. ដើម្បីរួចផុតពីការចោទប្រកាន់ ឃ. ដើម្បីទទួលបានសេចក្តីសុខ

៥.តើអត្ថបទនេះមានបំណងអប់រំយើងពីអ្វី?

ក. ឱ្យចេះអត់ឱនគ្នា ខ. ឱ្យខិតខំរៀនសូត្រ

គ. មិនឱ្យសេពសុរា ឃ. ឱ្យប្រកាន់យកសេចក្តីត្រង់

៦. ចេតនារបស់អ្នកធ្វើ ដែលនឹងធ្វើឱ្យអ្នកផងយល់ ហៅថា៖

ក. សម្តី ខ. ការគិត

គ. ទង្វើ ឃ. ព្រឹត្តិកម្ម

៧. ការផ្តល់សារៈសំខាន់ទៅលើពាក្យសម្តីរបស់ខ្លួន គោរពពាក្យនិយាយរបស់ខ្លួនថាជារបស់ខ្ពង់ខ្ពស់ស្មើជីវិត និយាយយ៉ាងណាក៏ធ្វើយ៉ាងនោះ សន្យារឿងអ្វីក៏ធ្វើតាមសន្យានោះ ហៅថា៖

ក. ត្រង់ចំពោះការងារ ខ. ត្រង់ចំពោះនាទី

គ. ត្រង់ចំពោះសេចក្តីល្អ ឃ. ត្រង់ចំពោះវាចា

៨. តើនាទីដែលអ្នកដឹកនាំត្រូវត្រង់ជាមួយមានប៉ុន្មានយ៉ាង?

ក. ២យ៉ាង ខ. ៣យ៉ាង

គ. ៤យ៉ាង ឃ. ៥យ៉ាង

៩. ការមិនលេងល្បិច ការមិនបោកបញ្ឆោតអ្នកដទៃ ធ្វើកិច្ចការអ្វីត្រង់ទៅត្រង់មក មានភក្តីភាពស្មោះត្រង់ ហៅថា៖

ក. ត្រង់ចំពោះនាទី ខ. ត្រង់ចំពោះបុគ្គល

គ. ត្រង់ចំពោះសេចក្តីល្អ ឃ. ត្រង់ចំពោះការងារ

១០. កំពូលនៃសេចក្តីត្រង់ ការរក្សាធម៌ មានយុត្តិធម៌ ត្រឹមត្រូវតាមធម៌ តាមគន្លងធម៌ ប្រកបដោយធម៌ ឬប្រើជាពាក្យអវិជ្ជមាននាំមុខវិញ មានដូចជាមិនស៊ីសំណូក មិនឆបោក មិនអយុត្តិធម៌ មិនលំអៀង ហៅថា៖

ក. ត្រង់ចំពោះនាទី ខ. ត្រង់ចំពោះបុគ្គល

គ. ត្រង់ចំពោះសេចក្តីល្អ ឃ. ត្រង់ចំពោះការងារ

១១. ការបំពេញការងារគ្រប់យ៉ាងរបស់ខ្លួនឱ្យបានល្អ និងឱ្យល្អដល់កម្រិតនៃការងារនោះ ការងារនោះ មិនខ្វក មិនខ្ជោះ មានសុក្រឹតភាព ហៅថា៖

ក. ត្រង់ចំពោះនាទី ខ. ត្រង់ចំពោះបុគ្គល

គ. ត្រង់ចំពោះសេចក្តីល្អ ឃ. ត្រង់ចំពោះការងារ

១២. ការទទួលថានាទី ជារឿងសំខាន់។ បដិបត្តិការងារក្នុងនាទីខ្លួនបានយ៉ាងត្រឹមត្រូវ មិនបៀតបៀននាតីរបស់អ្នកតូច មិនជ្រៀតជ្រែកនាទីរបស់អ្នកតូច ហៅថា៖

ក. ត្រង់ចំពោះនាទី ខ. ត្រង់ចំពោះបុគ្គល

គ. ត្រង់ចំពោះសេចក្តីល្អ ឃ. ត្រង់ចំពោះវាចា

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ ហ្រមដៃ ឆៀចវេរ មជ្ឈិមប្បដិបទា ព្រះពុទ្ធបរមគ្រូ សេចក្តីទុក្ខលំបាក

ការអធិប្បាយ ពីផលប្រយោជន៍របស់ត្រង់ទាំង៥ប្រការខាងលើនេះប្រៀបបាននឹង .....ទាំង៥ ដៃដែលនឹងស្អាតនោះ ព្រោះមានម្រាមគ្រប់ទាំងប្រាំ បើបាត់ម្រាមណាមួយដៃនោះនឹងទៅជាពិការ បើបាត់ម្រាមកាន់តែច្រើន ដៃក៏កាន់តែលែងមានប្រយោជន៍ច្រើនដែរ។

ដូចនេះមនុស្សត្រង់ គឺមនុស្សមិន..... ធ្វើការអ្វីនឹងបានឆាប់សម្រេចមិនខានដូចជាផ្លូវត្រង់ និងផ្លូវវៀចអ៊ីចឹងដែរ គឺផ្លូវត្រង់ទៅដល់គោលដៅឆាប់ជាងផ្លូវវៀច។ ផ្លូវត្រង់ គឺផ្លូវកណ្តាលជា..... មិនងាកឆ្វេង ងាកស្តាំរបស់..... របស់យើង។ ជនដែលដើរតាមផ្លូវត្រង់ ផ្លូវ កណ្តាល គឺជននោះជាអរិយសាវ័ករបស់ព្រះសម្មាសម្ពុទ្ធដ៏ពិត។ អ្នកដឹកនាំដែលត្រង់ គឺពិតជាអ្នក ដឹកនាំដែលកំពុងនាំរាស្ត្រប្រជាដើរលើផ្លូវមជ្ឈិមប្បដិបទា ឆ្ពោះទៅរកការរួចផុតពី..... របស់រាស្ត្រប្រជានិងឆ្ពោះទៅរកសេចក្តីសុខចម្រើនពិតប្រាកដ។

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១.ទសបារមី	ក. (ន.) : សភាវៈទ្រទ្រង់សត្វលោក (មានបាបបុណ្យ សុចរិត ទុច្ចរិត) ។	១→.....
២. ធម្មៈ	ខ. (ន) : អំពើ កិច្ចការ ការប្រព្រឹត្តទៅ ការរស់នៅ ការចិញ្ចឹមជីវិត ។	២→.....
៣. ចេតនា	គ. (ន) : ពេលមានគ្រោះភ័យជិតមកដល់ គួរខ្លាច ។	៣→.....

៤. អាសន្ន	ឃ. (ន) : សេចក្តីពិត ទៀងទាត់ ទៀងត្រង់ ។	៤→.....
៥. ទោសពៃរ៍	ង. (ន) : បារមី១០យ៉ាងចរិយាដ៏លើសលប់ ឬគុណជាតិដ៏ល្អ ដែលគួរបំពេញ ១.ទាន ២.សីល ៣.នេក្ខកម្ម: ការបួស:ការដឹងច្បាស់នូវសេចក្តីពិត ៤. បញ្ញា: ៥.វិរិយ: ការព្យាយាម ៦. ខន្តី : សេចក្តីអត់ធន់ ៧.សច្ច: ការកាន់សំដីពិត មិនវើរុះ ៨. អធិដ្ឋាន:ការអធិដ្ឋានឱ្យឃើញជាក់ស្តែងតាមហេតុពិត ៩.មេត្តា: ការផ្សាយសេចក្តីរាប់អាន ចំពោះសព្វសត្វមិនវើសមុខ ១០. ឧបេក្ខា: ដំណើរតាំងចិត្តដោយស្មោះស្មើ។	៥→.....
៦. ព្រឹត្តិកម្ម	ច. (ន) : ទោសនិងពៀរ ទោសជាពៀរ ។	៦→.....
៧. សច្ច:	ឆ. (ន) : គំនិតដែលនាំឱ្យចិត្តភ្នក ឬផ្តួចផ្តើម ។	៧→.....
	ជ. (ន) : ការកំណត់ពាក្យសំដីឱ្យដឹងគ្នាទៅវិញទៅមក ។	

ឃ. សំណួរត្រិះរិះ

១. ចូរឆ្លុនលើកយកសេចក្តីត្រង់ នៅក្នុងអត្ថបទដកស្រង់រឿងមាយើងមកបង្ហាញ។

.....

.....

.....

.....

.....

.....

.....

.....

.....

២. ហេតុអ្វីបានជាមនុស្សយើង ត្រូវប្រកាន់យកសេចក្តីត្រង់? ចូរពន្យល់។

.....

.....

.....

.....

.....

.....

.....

.....

៣. ចូរប្អូនលើកយកសេចក្តីត្រង់ដែលប្អូនបានប្រកាន់ខ្ជាប់នៅក្នុងជីវិតរស់នៅមកបង្ហាញ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

🕯 មំណិនៈ កាលអាកាស

លំហាត់

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. ទីកន្លែងដែលអ្នកនិពន្ធប្រឌិតឡើងតាមមនោគតិរបស់ខ្លួនដូចជាឋានសួគ៌ ឋាននរក ឋានត្រៃត្រឹង្ស ឬពិភពណាមួយហៅថា៖

ក. កាល ខ. អាកាស

គ. កាលអាកាស ឃ. អាកាសកាល

២. ពេលវេលាដែលដំណើររឿងប្រព្រឹត្តទៅហៅថា៖

ក. កាល ខ. អាកាស

គ. តំបន់ ឃ. កាលកំណត់តែង

៣. តើពាក្យមួយណា ជាពាក្យប្រាប់កាល?

ក. ទីនោះ ខ. ខណៈមួយ

គ. នៅផ្ទះ ឃ. ក្នុងព្រៃ

៤. តើពាក្យមួយណា ជាពាក្យប្រាប់អាកាស?

ក. សម័យថ្ងៃមួយ ខ. ខណៈមួយ

គ. សប្បាយ ឃ. លើភ្នំ

៥. តើពាក្យមួយណាជាពាក្យមិនបង្ហាញពីកាល?

ក. ម្សិលមិញ ខ. ពេលនេះ

គ. ពេលយប់ ឃ. កន្លែងនោះ

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ **កាលអាកាស អនាគត ឋានត្រៃត្រឹង្ស មនោគតិ**

.....ជាពេលវេលានិងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ។ កាល អាចជាពេលវេលាក្នុងអតីតកាល បច្ចុប្បន្នកាល .....ពេលថ្ងៃ ពេលយប់ ឬរដូវកាលណាមួយ ... ។ អាកាស ជាកន្លែងដែលរឿងកើតឡើង។

អាកាសអាចជាកន្លែង ដែលអ្នកនិពន្ធប្រឌិត ឡើងតាម..... របស់ខ្លួនដូចជា ឋានសួគ៌ ឋាននរក..... ឬពិភពណាមួយ។ ជួនកាលជាទីកន្លែងដែលមានពិតនៅទីណាមួយផងដែរ ។

គ. សំណួរត្រិះរិះ

១. ចូរស្រង់កាល អាកាសនៅក្នុងអត្ថបទរឿង សត្វឥន្ទ្រីនិងក្រពើដណ្តើមដំរីគ្នាស៊ី។

មាននិទានមួយថា មានសត្វឥន្ទ្រីមួយនៅកោះកណ្តាលសមុទ្រ ហើយមានក្រពើមួយធ្វើរូងនៅ កោះនោះផង។ សត្វឥន្ទ្រីនោះតែងទៅឆាបដំរីពីត្រើយសមុទ្រយកមកឆីនៅខាងរូងក្រពើនោះជាប្រក្រតី ថ្ងៃមួយក្រពើមើលឃើញឥន្ទ្រីពាំដំរីនិងឆីហើយ ក្រពើនោះគិតគ្នាន់ក្នុងចិត្តថា "អញនឹងដណ្តើមសាច់ដំរីពីឥន្ទ្រីធី លុតឥន្ទ្រីពាំដំរីមកដាក់ដល់ស្ថានដែលធ្លាប់តែបរិភោគរៀងរាល់ថ្ងៃនោះ ក្រពើនោះ៖វារចេញអំពីរូងឡើងទៅរកឥន្ទ្រីហើយសួរថា "ម្នាលឥន្ទ្រី ម្តេចក៏ព្រះស្តែងមកលួចសាច់ដំរីជាអាហារអញ?"។ ឥន្ទ្រីឆ្លើយថា"ដំរីនេះអញឆាបយកមកពីត្រើយសមុទ្រជាប្រាកដ ទើបតមកដល់អម្បាញ់មិញនេះឯង ម្តេចក៏លែងថាអញលួចអាហារព្រះស្តែង?"។ ក្រពើនិងឥន្ទ្រីវិវាទគ្នាប្រាថ្នា ចង់បានសាច់ដំរីទៅវិញទៅមកពុំដាច់ស្រេចឡើយ ទើបនាំគ្នាទៅប្តឹងពោធិសត្វដែលជាតាបសនៅទីនោះ។ ក្រពើនិងឥន្ទ្រីប្តឹងដោយដំណើរទីទៃ។ ក្រពើថា "ខ្ញុំខាំដំរីនឹងឆីនៅខាងរូងលំនៅខ្ញុំ ឥន្ទ្រីនេះមកដណ្តើមសាច់ដំរី និងយកមកឆីជាអាហារ"។ ឥន្ទ្រីថា "ដំរីនេះខ្ញុំឆាបអំពីត្រើយសមុទ្រជាប្រាកដ ទើបតែមកដល់ ខ្ញុំគិតនឹងឆី ស្រាប់តែក្រពើនេះវារឡើងអំពីរូងទៅថាខ្ញុំលួចចំណីអាហារ សូមព្រះអង្គពិចារណាឱ្យខ្ញុំហោង" តាបសមើលដល់ទីកន្លែងដំរី ទើបឃើញតែស្នាមក្រចកឥន្ទ្រី ពុំឃើញចង្កូមក្រពើនោះឡើយ ព្រះអង្គយកក្រចកឥន្ទ្រីមកផ្ទាប់មើលឃើញថាមែន។ តាបស "ឥន្ទ្រី

នេះ យល់ជាមានសាក្សីមែនពិត ឯក្រពើឥតសាក្សីអ្វីឡើយ ទើបកាត់សេចក្តីនោះឱ្យក្រពើចាញ់ឥន្ទ្រី។ តាបសកាត់សេចក្តីដូច្នេះ ហៅសុគតិគមនំហោង"។

.....

.....

.....

.....

.....

.....

.....

.....

🕯 អ្នកនិពន្ធ និងកាលកំណត់តែង

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. កាលបរិច្ឆេទនៃការតាក់តែងរឿងណាមួយហៅថា៖

ក. កាលបរិច្ឆេទ ខ. កាលកំណត់តែង

គ. ការនិពន្ធ ឃ. ការចងក្រងអត្ថបទ

២. រឿងសូជាត និពន្ធដោយ៖

ក. លោកសួន សុរិន្ទ ខ. លោកញ៉ុក ថែម

គ. ក្រឡាហោមគង់ ឃ. លោករីម គីន

៣. តើរឿងមាយើងនិពន្ធនៅឆ្នាំណា?

ក.ឆ្នាំ១៧៣៦ ខ. ឆ្នាំ១៩៦២

គ.ឆ្នាំ១៩៣៨ ឃ. មិនច្បាស់

៤. តើរឿងសូជាតនិពន្ធនៅឆ្នាំណា?

ក.ឆ្នាំ១៨៦៣ ខ. ឆ្នាំ១៩៦៧

គ.ឆ្នាំ១៩៣៨ ឃ. មិនច្បាស់

៥. តើរឿងទីក្រុងភ្នំពេញ និពន្ធនៅឆ្នាំណា?

ក.ឆ្នាំ១៩៣៦ ខ. ឆ្នាំ១៩៤៦

គ.ឆ្នាំ១៩៣៨ ឃ. មិនច្បាស់

៦. រឿងព្រះចន្ទ្រ និពន្ធដោយ៖

ក.សម្តេចព្រះសង្ឃរាជជួនណាត ខ. លោកឧកញ៉ាសន្ធរម៉ុក

គ.មិនមានអ្នកនិពន្ធ ឃ. លោកវីម គីន

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ ផ្លែកវប្បធម៌ អក្សរសិល្ប៍បុរាណ កាលបរិច្ឆេទ ការនិយម គ្មានកាលកំណត់តែង អ្នកនិពន្ធ

ការសិក្សា..... ឬរឿងបុរាណ សំដៅដល់ការសិក្សារឿងព្រេង និងរឿងប្រឌិត ដែលកើតមានឡើងក្នុងសម័យកាលដំបូងនៃប្រវត្តិអក្សរសិល្ប៍បុរាណ។ រឿងបុរាណជាច្រើនមិនថា រឿងបុរាណខ្មែរ ឬបរទេស គ្មានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទច្បាស់លាស់ទេ គឺមានត្រឹមតែការនិទានឬនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ ហើយក្រោយមកក៏មាន.....ចូលចិត្ត និងមានការរៀបចំចងក្រងតាមការនិទានឡើងវិញ ដើម្បីទុកជាឯកសារដូចជា សៀវភៅប្រជុំរឿងព្រេងខ្មែរ ដែលមានចំនួន៩ភាគ ដោយក្រុមពុទ្ធសាសនបណ្ឌិតជាដើម។ ស្នាដៃខ្លះ ជួនកាលមានឈ្មោះអ្នកនិពន្ធដែរ តែ..... ពិតប្រាកដដូចជា ប្រភេទរឿងទសជាតក បញ្ញាសជាតក។ល។

ការសិក្សាអំពីអ្នកនិពន្ធ កាលកំណត់តែងរបស់អ្នកនិពន្ធ អាចឱ្យយើងស្គាល់ឈ្មោះ និងជីវប្រវត្តិ របស់អ្នកនិពន្ធ ដឹងពី..... ក្នុងការតែងនៅពេលណា សម័យកាលណា ហើយដឹងទៀតថារឿង នោះកើតឡើងយ៉ាងដូចម្តេច ប្រព្រឹត្តទៅយ៉ាងណា ហើយមានព្រឹត្តិការណ៍អ្វីកើតឡើងនៅសម័យកាលនោះ ដើម្បីទុកជាមេរៀន ជាបទពិសោធ ឬធ្វើការប្រៀបធៀបគ្នានិងស្នាដៃថ្មីទំនើប ពីលក្ខណៈខុសគ្នា ការវិវត្តទាំង..... សេដ្ឋកិច្ច សង្គមកិច្ចឬផ្នត់គំនិត ជាពិសេសគឺប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា ដែលទាក់ទងនឹងជីវភាពរស់នៅរបស់ប្រទេសមួយចំនួននៃតំបន់ខ្លះ។

គ. សំណួរត្រិះរិះ

១. ហេតុអ្វីបានជាយើងចាំបាច់ត្រូវសិក្សាពីអ្នកនិពន្ធ និងកាលកំណត់តែង?

.....

.....

.....

.....

.....

.....

.....

.....

២. ចូរបង្ហាញកាលកំណត់តែង និងឈ្មោះអ្នកនិពន្ធ នៃរឿងព្រះថោងនាងនាគ រឿងខ្លានិងភេពីរ រឿងមាលាដួងចិត្ត រឿងតេជោយ៉ត និងរឿងធនញ្ជ័យ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

១ ការស្តាប់៖ រឿង អ៊ុយលីសវិលវិញ

កាលពីព្រេងនាយ នាសតវត្សរ៍ឈ្លងគឺ២៩០០ ឆ្នាំមុននេះ មហាសមុទ្រមេឌីទែរ៉ាណេជាសមុទ្រមួយពោរពេញទៅដោយអាថកំបាំង ការផ្សងព្រេង និងភយន្តរាយ។ ដើម្បីឆ្លងពីកោះមួយទៅកោះមួយ នាវាទាំងឡាយដែលចេញបើកបរលើសមុទ្រដ៏ខៀវនេះ មិនហ៊ានចេញចាកឱ្យផុតកន្ទុយភ្នែកពីផ្ទៃដីឡើយ។ គេខ្លាចព្យុះសង្ឃរាណាស់។ គ្មានអ្នកណាម្នាក់ហ៊ានធ្វើដំណើរផ្សងព្រេងឆ្លងពីម្ខាងទៅម្ខាងឡើយ ព្រោះក្នុងចំណោមអ្នកដែលផ្សងព្រេងឆ្លងសមុទ្រមេឌីទែរ៉ាណេពុំដែលមានអ្នកណាម្នាក់ត្រឡប់មកវិញ ដើម្បីនិយាយប្រាប់យើងនូវរឿងរ៉ាវពិតនោះឡើយ។ ហេតុនេះហើយទើបគេតែងសន្និដ្ឋានថា អ្នកផ្សងព្រេងទាំងអស់ដែលឥតត្រឡប់វិលវិញនោះ ប្រហែលជាបានទៅជួបប្រទេសឆើតឆាយអស្ចារ្យណាមួយ ធ្វើឱ្យគេលែងចង់ត្រឡប់មកស្រុកកំណើតវិញ ឬមួយក៏អ្នកទាំងនោះវង្វេងរក ផ្លូវវិលត្រឡប់មកផ្ទះវិញមិនឃើញ។ ខ្វះអ្វីនាវិកនៅស្រុកក្រិកច្រើនរាប់មិនអស់ ដែលឥត ត្រឡប់មកស្រុកកំណើតវិញ។រាល់ហេមន្តរដូវ នៅឈូងសមុទ្រក្រិកគេតែងឃើញទូកក្តោងនាវា សំពៅ រាប់រយ ពាន់ចុះទឹកបណ្តែតខ្លួនដូចពោងពាយរាយពាសពេញផ្ទៃសមុទ្រដ៏ខៀវស្រងាត់។ ទូកក្តោង សំពៅ សំប៉ាន ទាំងប៉ុន្មានសុទ្ធតែបានធ្វើឡើងដោយផ្ទិតផ្ទង់តាំងពីរដូវរងា ត្រៀមខ្លួនឱ្យ ទាន់ពេលវេលានារដូវក្តៅ រង់ចាំចេញដំណើរពេលមេឃស្រឡះ ខ្យល់ជំនោរល្អប្រសើរ។ ក្នុងចំណោមនាវិកទាំងឡាយ មានតាំងពីអ្នកនេសាទ អ្នកជំនួញជួញព្រៃកំណាត់ គ្រឿង ទេស ពាង ក្រឡ ដែលគេដឹកដោះដូរពីប្រទេសស៊ីរី អេហ្ស៊ីប ជាដើម។ បើមើលពីចម្ងាយ ទូកក្តោងទាំងឡាយនេះបណ្តែតបន្តកន្ទុយបណ្តាក់គ្នា ក្រងឹកកងក់ហាក់បីដូចជាសត្វ ចម្លែកផ្សេងៗ កំពុងវារលើផ្ទៃទឹកសមុទ្រមេឌីទែរ៉ាណេ។ រីឯចោរសមុទ្រវិញក៏មិនខ្វះដែរ។ ចោរតែងតែប្លន់ទាំងសំពៅ ទាំងរបស់របរ ទាំងម្ចាស់យកទៅលក់នៅប្រទេសឆ្ងាយៗ ធ្វើជាទាសាទាសីរបស់គេ។ ហេតុនេះហើយបានជាអ្នកនេសាទ អ្នកជំនួញ មិនដែលហ៊ានចេញឆ្ងាយពីតំបន់ដែលខ្លួនធ្លាប់ស្គាល់នោះទេ។

មេឌីទែរ៉ាណេ ជាមហាសមុទ្រមួយពោរពេញទៅដោយអាថកំបាំងរាប់មិនអស់។ ព្រឹត្តិការណ៍ទាំងឡាយចេះតែប្រព្រឹត្តទៅរាប់សតវត្ស ដោយឥតអ្នកណាមួយហ៊ានចាកចេញឆ្ងាយពីផ្លូវដែលខ្លួនធ្លាប់ស្គាល់ឡើយ។ ទើបតែថ្ងៃមួយ មានអ្នកក្លាហានដ៏ឆ្នើមម្នាក់

ឈ្មោះ អ៊ុយលីស បានត្រូវបង្ខំចិត្តដើម្បីភារកិច្ច និងដើម្បីគោរពកិច្ចសន្យារបស់ខ្លួន ចេញ ចាកពីតំបន់ដែលគេធ្លាប់ស្គាល់ ចូលទៅក្នុងតំបន់ដ៏សែនអាថកំបាំងបំផុតនៃសមុទ្រមេឌី ទែ រ៉ាណេ។ ជាការពិតណាស់ ផ្លូវថ្មីឥតប្រណីដល់នាវិកដ៏ឆ្នើមនេះឡើយ។ គ្រោះថ្នាក់និង អាសន្នផ្សេងៗច្រើនរាប់មិនអស់ បានធ្វើឱ្យនាវិកយើងបាត់ដំណឹងសូន្យឈឹងអស់រយៈម្ភៃ ឆ្នាំ។ គ្មានអ្នកណាម្នាក់ហ៊ានសន្និដ្ឋានថា គេអាចនៅរស់ជីវិតនៅឡើយ។ ទាំងម្តាយ ទាំង ឪពុក ទាំងប្រពន្ធ ទាំងកូនប្រុសតែមួយគត់របស់គេក៏នឹកសន្និដ្ឋានថា គេច្បាស់ជាស្លាប់ បាត់ ទៅហើយដែរ។ លើកលែងតែឆ្កែសម្លាញ់របស់គេតែមួយគត់ ដែលសុខចិត្តរង់ចាំ ម្ចាស់រហូត ដល់ចាស់ខ្លួន បាក់ស្លឹកត្រចៀកធ្លាក់ស្មើរអូសដល់ជង្គង់ ក្បាលធ្ងន់សំយុងស្មើរ អូសដី ជើង ទាំងបួនឈរទ្រេតទ្រោតទ្រខ្លួនដ៏ស្វិតស្គមស្គាំងរបស់វាស្មើរលែងរួច សម្លាញ់របស់គេ នៅ តែរង់ចាំម្ចាស់ដោយក្តីសង្ឃឹម។ ក្តីសង្ឃឹមនេះ បានពន្យារពេលវេលាស្លាប់របស់វា។ វាខំ ប្រឹងទ្រ រក្សាដង្ហើមចុងក្រោយរបស់វាទុកទទួលម្ចាស់។ គ្រាន់តែបាន ឃើញមុខម្ចាស់ សម្លាញ់វាភ្លាម ឆ្កែដ៏ភក្តីក៏ដាច់ខ្យល់ស្លាប់ទៅដោយបិទភ្នែកយ៉ាងជិតផ្តិត យកសុភមង្គលដ៏ សែនថ្លៃ លាចាកហ៊ានមនុស្សលោកក្រោមក្តីសោកសង្រេងអស់ម្ភៃឆ្នាំ។ ម្ភៃឆ្នាំចាំម្ចាស់វិល វិញ អ្នកដំណើរជាម្ចាស់ឆ្កែនេះ បានចេញចាកមាតុភូមិខ្លួនដោយមានទាហានជើងទឹក នាវិក ជាច្រើនហែហមទៅជាមួយ។ ប៉ុន្តែពេលត្រឡប់មកដល់ មាតុភូមិវិញ គេនៅសល់តែម្នាក់ឯង គត់ ស្មើរឥតសំពត់រុំលើខ្លួនទៅទៀត។ ប៉ុន្តែរឿងរ៉ាវសម្បូរបែបអស្ចារ្យទាំងឡាយ ដែលគេ និយាយរ៉ាយរ៉ាប់ប្រាប់យើងវិញ គឺពោរពេញទៅដោយអាថកំបាំងដ៏ចម្លែកអស្ចារ្យជាទីបំផុ ត។

(ដកស្រង់ និងកែសម្រួលពីរឿងអ៊ុយលីសវិលវិញ របស់អ្នកនិពន្ធអូមែ)

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងអ៊ុយលីសមានប្រភពមកពីប្រទេសណា?

ក. ប្រទេសឥណ្ឌា ខ. ប្រទេសចិន

គ. ប្រទេសអង់គ្លេស ឃ.ប្រទេសក្រិក

២. តើអ៊ុយលីសជាអ្នកណា?

ក. មេទ័ព ខ. កូនទាហាន

គ. កសិករ ឃ. គ្រូពេទ្យ

៣. តើហេតុអ្វីបានជាអ៊ុយលីសត្រូវទៅទីក្រុងទ្រ័រ?

ក. ដើម្បីប្លន់ទ្រព្យសម្បត្តិ ខ. ដើម្បីដណ្តើមអំណាច

គ. ដើម្បីជួយមនុស្ស ឃ. ដើម្បីកម្សាន្ត

៤. តើក្នុងការវិលត្រឡប់មកមាតុភូមិវិញ អ៊ុយលីសត្រូវឆ្លងកាត់សមុទ្រអ្វី?

ក. មហាសមុទ្រប៉ាស៊ីហ្វិក ខ. មហាសមុទ្រមែឌីទែរ៉ាណេ

គ. មហាសមុទ្រអាត្លង់ទិក ឃ. មហាសមុទ្រឥណ្ឌា

៥. តើអ្នកណាជាអ្នកចាំទទួលផ្លូវអ៊ុយលីសត្រឡប់មកមាតុភូមិវិញ?

ក. ប្រជាជន ខ. ប្រពន្ធ

គ. កូន ឃ. ឆ្កែ

៦. តើចំណុចមួយណានៅក្នុងសាច់រឿងដែលបង្ហាញពីភាពស្មោះត្រង់?

ក. ការឆ្លងកាត់ឧបសគ្គ ខ. ការធ្វើសង្គ្រាម

គ. ការប្រើល្បិចដើម្បីឈ្នះ ឃ. ការគោរពសម្តី

៧. តើអត្ថបទមានតម្លៃអប់រំយ៉ាងណា?

ក្នុងខណៈនោះមានសូរស្បែកជើងលាន់ឮពីខាងក្រោមឡើងមកលើផ្ទះ ព្រមទាំងមានសំឡេង យ៉ាងឆ្មារតូចលាន់រំពងមកពីខាងក្រោយ ចៅចិត្រក៏ចោលភ្នែកក្រឡេកមើលទៅប្រទះនឹងភ្នែកទាំងគូកំពុងតែសំឡឹងចំត្រង់មក ជាដួងភ្នែកប្រកបដោយទឹកដមគួរជាទីចាប់ចិត្តស្នេហា តែមានឫកពាឆ្មើងឆ្មៃបន្តិច មានកិរិយាក្តិកក្តក់ញ៉ែងញ៉ង ល្វាសល្វន់ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ដូចវង់ព្រះចន្ទ្រា សូរសំឡេងស្រួយស្រស់ដូចសូររគាំងប្រាក់ ដំណើរល្វាសល្វន់ដូចផ្កាកុលាប ដែលត្រូវខ្យល់បក់លិចៗនៅកណ្តាលសួនច្បារដូច្នោះ ឱ!ល្អអី ល្អម្ល៉ះ! ន ប្រហែលជាអញ្ចឹយល់សប្តិឃើញទេដឹង?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណានៈ តោថ្ម

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទកំណាព្យ "តោថ្ម" មានប្រភពមកពីណា?

ក. ល្បីកនគរវត្ត
ខ. ច្បាប់ប្រុស
គ. ច្បាប់ស្រី
ឃ. និរាសនគរវត្ត

២. តើកំណាព្យ "តោថ្ម" និពន្ធដោយអ្នកណា?

ក. លោកញ៉ុក ថៃម
ខ. សម្តេចព្រះសង្ឃរាជជួន ណាត
គ. លោកឧកញ៉ាសន្ធរវោហារម៉ុក
ឃ. លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ

៣. តើកំណាព្យ "តោថ្ម" តែងឡើងជាបទអ្វី?

ក. បទពាក្យប្រាំពីរ
ខ. បទព្រហ្មគីតិ
គ. បទពាក្យប្រាំបី
ឃ. បទកាកគតិ

៤. តើមួយណា ជាការព្យមាត្រនៃកំណាព្យតោថ្ម?

ក. ក្នុង១ល្បះមាន ៤ឃ្លា ក្នុងមួយឃ្លាមាន ៨ព្យាង្គ
ខ. ក្នុង១ល្បះមាន ៣ឃ្លា ក្នុងមួយឃ្លាមាន ៦ព្យាង្គ
គ. ក្នុង១ល្បះមាន ៥ឃ្លា មួយឃ្លាមាន ៤ព្យាង្គ
ឃ. ក្នុង១ល្បះមាន ៤ឃ្លា មួយឃ្លាមាន៧ព្យាង្គ

៥. តើមួយណា ជាចំណាប់ចូនឆ្លងល្បះនៃកំណាព្យតោថ្ម?

ក. ព្យ៨ ឃ៤ ល្បះ១ ចូននឹង ព្យ៨ ឃ២ ល្បះ២
ខ. ព្យ៨ ឃ៣ ល្បះ១ ចូននឹង ព្យ៨ ឃ១ ល្បះ២

គ. ព្យ៨ ឃ១ ល្បះ១ ចូននឹង ព្យ៨ ឃ២ ល្បះ២

ឃ. ព្យ៨ ឃ៣ ល្បះ១ ចូននឹង ព្យ៨ ឃ៤ ល្បះ២

៦. តើមួយណាជាចំណាប់ចូនក្នុងល្បះនៃកំណាព្យគោថ្ម?

ក. ព្យ៨ ឃ្ល១ ចូននឹងព្យ៣ ឃ្ល២ ព្យ៨ ឃ្ល២ ចូននឹង ព្យ៨ ឃ្ល៣ ចូននឹង ព្យ៣ ឃ្ល៤

ខ. ព្យ៨ ឃ្ល២ ចូននឹងព្យ៤ ឃ្ល២ ព្យ៨ ឃ្ល២ ចូននឹង ព្យ៨ ឃ្ល៣ ចូននឹង ព្យ៣ ឃ្ល៤

គ. ព្យ៨ ឃ្ល១ ចូននឹងព្យ៥ ឃ្ល២ ព្យ៨ ឃ្ល២ ចូននឹង ព្យ៧ ឃ្ល៣ ចូននឹង ព្យ៣ ឃ្ល៤

ឃ. ព្យ៨ ឃ្ល១ ចូននឹងព្យ៣ ឃ្ល២ ព្យ៨ ឃ្ល២ ចូននឹង ព្យ៨ ឃ្ល៣ ចូននឹង ព្យ៤ ឃ្ល៤

៧. តាមរយៈអត្ថបទ តើអ្នកណាជាអ្នកបំផ្លាញគោថ្ម?

ក. មនុស្សចង្រៃ

ខ. សត្វសាហាវ

គ. ធម្មជាតិ

ឃ. ភាពចាស់អេចរឹល

៨. តើការបំផ្លាញសម្បត្តិវប្បធម៌ ចាត់ទុកថាជាទង្វើបែបណា?

ក. ទង្វើគ្មានមនុស្សធម៌

ខ. ទង្វើប្រកបដោយសីលធម៌

គ. ទង្វើបំផ្លាញជីវិតមនុស្សជាតិ

ឃ. ទង្វើគ្មានការពិចារណា

៩. តើចំណុចត្រង់ណានៃអត្ថបទ ដែលបង្ហាញពីស្មាតីស្នេហាជាតិ?

ក. បង្ហាញពីឧបករណ៍ អាវុធផ្សេងៗ

ខ. ការបង្ហាញពីភាពបាក់បែកនៃគោថ្ម

គ. ការគាំទ្រជនទាំងឡាញដែលសំលៀងកាំបិតលើគោថ្ម

ឃ. ការខឹងសម្បាអ្នកដែលបំផ្លាញគោថ្ម

១០. ហេតុអ្វីបានជាយើង ត្រូវការពារសម្បត្តិវប្បធម៌ជាតិយើង?

ក. ព្រោះសម្បត្តិវប្បធម៌ ជាកេរមរតកដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន

ខ. ព្រោះកាលណាយើងមិនខិតថែរក្សា គ្មានអ្នកថែជំនួសយើងទេ

គ. ព្រោះនៅសាលាបានអប់រំមនុស្សគ្រប់រូបបែបនេះ

ឃ. ព្រោះវាច្បាប់របស់ប្រទេសជាតិយើង

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ **ពិការ តោង្ក តំនិត មរណ៍ ម្ងៀង ការ សំលៀង**

១. អនិច្ចា..... លោកកសាង មើលថាថាងយ៉ាងរស់ស្ទុះប្រែប្រាយ

ឥទ្ធរមកធ្លាយធ្លាក់បាក់ខ្ចាត់ខ្ចាយ ស្តាយអើយស្តាយមិនគួរមក..... ។

២. មានអ្នកព្រៃចង្រៃឥត..... ទៅសំលៀងកាំបិតគ្រឿងប្រហារ

ឱ្យខូចខាតសាច់បង់អាសា មិនស្តាយ..... ស្មាដៃបុរាណសោះ ។

៣. ឱគោអើយគោឈរមិនមើល..... ម្តេចមិនខឹងខាំវា..... ខ្នងគោចុះ

ម្តេចមិនខឹងខាំវាសំលៀងនោះ ឱ្យវាលុះក្តី..... យកវាទៅ ។

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. នាគបាសាណ	ក. (ន.) កាលដ៏យូរលង់ យូរអង្វែង តរៀងទៅ។	១→.....
២.ហ្មាយ	ខ. (ន.) នាគដែលបើកពពារ ឬធំឡើងវិទ្ធ។	២→.....
៣. ចីរកាល	គ. (ន.) សម្គាល់ ចំណាំ កំណត់ដឹង។	៣→.....
៤. ថាវរៈ	ឃ. (ន.) ស្តេចនាគ។	៤→.....
៥. វាសុក្រី	ង. (គុ.) មាំមួន ស្ថិតស្ថេរ មាំទាំ។	៥→.....
៦. ស្ទែង	ច. (កិ.) អាការៈងងឹតមុខជ្រប់ ឬងងឹតមុខខ្លាំងដល់ដួលដេក។	៦→.....
	ឆ. (គុ.)ស្ទើប ស្រៀវសាច់ កោត នឹកអស្ចារ្យក្នុងចិត្ត។	

ឃ.សំណួរត្រិះរិះ

១. ចូរស្រង់ឃ្លា ដែលបង្ហាញពីៈ

ក. ការមិនពេញចិត្តរបស់អ្នកនិពន្ធចំពោះអំពើបំផ្លិចបំផ្លាញ។

ខ. ការស្តាយស្រណោះរបស់អ្នកនិពន្ធចំពោះការខូចខាត។

គ. មោទនភាពរបស់អ្នកនិពន្ធចំពោះសម្បត្តិវប្បធម៌ជាតិ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. ក្នុងនាមអ្នកជាកូនខ្មែរ តើអ្នកមានយោបល់យ៉ាងណាចំពោះអំពើបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ជាតិ?

.....

.....

.....

.....

.....

.....

.....

.....

.....

៣. ចូរបង្ហាញតម្លៃតម្លៃអប់រំនៃកំណាព្យតោថ្ម។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណានៈ ច្បាប់ប្រុស

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើកំណាព្យ "ច្បាប់ប្រុស" មានប្រភពមកពីណា?

ក. ច្បាប់កូនចៅ ខ. ច្បាប់ល្បីកថ្មី

គ. ច្បាប់អប់រំកូនចៅប្រុសស្រី ឃ. ច្បាប់ប្រុស

២. តើកំណាព្យ "ច្បាប់ប្រុស" តែងឡើងជាបទអ្វី?

ក. បទព្រហ្មគីតិ ខ. បទបន្ទោលកាក

គ. បទពាក្យប្រាំពីរ ឃ. បទភុជង្គលីលា

៣. តើកំណាព្យ "ច្បាប់ស្រី" តែងឡើងជាបទអ្វី?

ក. បទព្រហ្មគីតិ ខ. បទបន្ទោលកាក

គ. បទពាក្យប្រាំពីរ ឃ. បទភុជង្គលីលា

៤. តើកំណាព្យច្បាប់ប្រុស និងច្បាប់ស្រីនិពន្ធដោយអ្នកណា?

ក. លោកឧកញ៉ាសន្ធរវោហារម៉ុក ខ. លោកសុត្តន្តប្រីជាឥន្ទ

គ. បណ្ឌិតម៉ឺន ម៉ៃ ឃ. អ្នកព្រះភិរម្យភាសាអ៊ូ

៥. ក្នុងច្បាប់ប្រុសលោកថា ឆ្កួតបីដែលមនុស្សគួរចៀសវាងមាន៖

ក. ឆ្កួតស្រី ឆ្កួតស្រា និងឆ្កួតថ្នាំ

ខ. ឆ្កួតលេងល្បែង ឆ្កួតស្រា និងឆ្កួតថ្នាំ

គ. ឆ្កួតលេងល្បែង ឆ្កួតស្រា និងឆ្កួតនឹងសម្ភារនិយម

ឃ. ឆ្កួតស្រី ឆ្កួតស្រា និងឆ្កួតល្បែង

៦. ចំណាប់ចូនក្នុងវគ្គ របស់បទភុជង្គលីលាគឺ៖

ក. ព្យទី៦ ឃ្លាទី១ ចូននឹងព្យទី៤ ឃ្លាទី២

ខ. ព្យទី៦ ឃ្លាទី១ ចូននឹងព្យទី៤ ឃ្លាទី២ ហើយចូននឹងព្យទី៤ ឃ្លាទី៣

គ. ព្យទី៤ ឃ្លាទី១ ចូននឹងព្យទី៦ ឃ្លាទី២

ឃ. ព្យទី៤ ឃ្លាទី១ ចូននឹងព្យទី៤ ឃ្លាទី២

៧. ចំណាប់ចូនឆ្លងវគ្គ របស់បទភុជង្គលីលាគឺ៖

ក. ព្យទី៤ ឃ្លាទី៣ ល្បះទី១ ចូននឹងព្យទី៦ ឃ្លាទី១ ល្បះទី២

ខ. ព្យទី៦ ឃ្លាទី១ ចូននឹងព្យទី៤ ឃ្លាទី២ ហើយចូននឹងព្យទី៤ ឃ្លាទី៣

គ. ព្យទី៤ ឃ្លាទី១ ល្បះទី១ ចូននឹងព្យទី៦ ឃ្លាទី២ ល្បះទី៣

ឃ. ព្យទី៤ ឃ្លាទី១ ល្បះទី២ ចូននឹងព្យទី៤ ឃ្លាទី២ ល្បះទី៣

៨. បទព្រហ្មគីតិមានចំណាប់ចូនក្នុងវគ្គដូចជា៖

ក. ព្យទី៥ ឃ្លាទី១ ចូននឹងព្យទី៣ ឃ្លាទី២ ព្យទី៦ ឃ្លាទី២ ចូននឹងព្យទី៥ ឃ្លាទី៣

ខ. ព្យទី៤ ឃ្លាទី១ ចូននឹងព្យទី២ ឃ្លាទី២ ចូននឹងព្យទី៥ ឃ្លាទី៣

គ. ព្យទី២ ឃ្លាទី១ ចូននឹងព្យទី៥ ឃ្លាទី២ ព្យទី៦ ឃ្លាទី២ ចូននឹងព្យទី៥ ឃ្លាទី៣

ឃ. ព្យទី៥ ឃ្លាទី១ ចូននឹងព្យទី៦ ឃ្លាទី២ ព្យទី៦ ឃ្លាទី២ ចូននឹងព្យទី៥ ឃ្លាទី៣

៩. បទព្រហ្មគីតិមានចំណាប់ចូនឆ្លងវគ្គដូចជា៖

ក. ព្យទី៦ ឃ្លាទី៤ វគ្គទី១ ចូននឹងព្យទី៥ ឃ្លាទី១ វគ្គទី២

ខ. ព្យទី៦ ឃ្លាទី១ វគ្គទី១ ចូននឹង ព្យទី៦ ឃ្លាទី២ វគ្គទី២

គ.ព្យទី៦ ឃ្លាទី ២ វគ្គទី១ ចូននឹងព្យទី៦ ឃ្លាទី២ វគ្គទី២

ឃ. ព្យទី៦ ឃ្លាទី៤ វគ្គទី១ ចូននឹង ព្យទី៦ ឃ្លាទី២ វគ្គទី២

១០. តើឃ្លាខាងក្រោមមួយណា ជាតម្លៃអប់រំនៃច្បាប់ស្រី?

ក. កុំឆ្លូតនឹងស្រី ស្រា ល្បែង

ខ. កុំនាំភ្លើងក្រៅចូលមកក្នុង កុំនាំភ្លើងក្នុងចេញមកក្រៅ

គ. ត្រូវឧស្សាហ៍ព្យាយាមក្នុងការងារ

ឃ. អ្នកហ៊ានស្បែកជាច អ្នកខ្លាចស្បែកជា

១១. តើអត្ថបទកំណាព្យ "ច្បាប់ប្រុស" ផ្តល់តម្លៃអប់រំយ៉ាងណា?

ក. ត្រូវឧស្សាហ៍ព្យាយាមក្នុងការងារ

ខ. ការសន្សំសំចៃ ជានាទីរបស់នារីម្នាក់ប៉ុណ្ណោះ

គ. ការសេពស្រីស្រាល្បែង ជារឿងល្អ

ឃ. ក្នុងនាមជាប្រុស ធ្វើអ្វីមិនចាំបាច់ប្រាប់ប្រពន្ធ

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ **ដៀល ឆ្គង ដៀវដុំ អប្រិយ រហ៊ុម ដេរ**

បទព្រហ្មគីតិ

អឺអើអញដាច់សាច់	.....ពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យ.....	ស្រដីថាកូនអត់ពូជ ។
ចាស់ទុំមិនប្រដៅ	.....កូនចៅទើបវាខូច
គេថាកូនឥតពូជ	មិនដឹងច្បាប់នឹងចាស់ទុំ ។
គេ..... ដល់ម៉ែឪ	កេរ្តិ៍អាស្រូវស្អុយ.....
គេស្តីដើម.....	ដំនៀលនោះដល់មកចាស់ ។

☞ **អាយ ចរចា សំដី កុំខ្ជះ យស ញាតិ អញ្ជ**

បទកុជង្គលីលា

ហៅកូនស្រីស្ងួនមាសម្តាយ	ក្រណាស់នាង.....	តាមដោយច្បាប់ស្រី។
ក្រមួយមិនបាន.....	ពាក្យទន់តិចនៃ	ឱ្យ..... ចូលចិត្ត។
ក្រមួយមិនចេះរិះគិត	ឃើញញាតិឆ្ងាយជិត	ហៅឡើងឆីស្លា។
ទោះមានមិនមានក្តីណា	ពាក្យផ្អែម.....	ទើបគេស្រឡាញ់។
.....ចិត្តស្មូរកំណាញ់	មិនមានអស់.....	នឹង..... សន្តាន ។
កើត..... របស់ផងបាន	កើតសុខក្សេមក្សាន្ត	ពីព្រោះកូនស្រី ។

ក. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. ច្រលាស់	ក. (គុ.) កំណាញ់ រឹតត្បិតឥតអៀនខ្មាស។	១→.....
២. ទុរយស	ខ. (គុ.) ដោយហេតុពីព្រោះ។	២→.....
៣. ធូ	គ. (គុ.) ដែលមិនស្អាត មិនបរិសុទ្ធ កខ្វក់។	៣→.....
៤. ផ្សា	ឃ. (គុ.) ព្រហើន មើលងាយ ផ្តើន។	៤→.....
៥. ជៀវ	ង. (កិ.) ធ្វើឱ្យសាំង គឺឱ្យបាត់ផ្លាង។	៥→.....
៦. ស្នូរ	ច. (ន.) ឈ្មោះល្បែងស៊ីសងមួយប្រភេទរបស់ចិន។	៦→.....
៧. អសោច៍	ឆ. (គុ.) ចង្រៃ ឧត្បាត។	៧→.....
	ជ. (គុ.) ទ្រហឹង អឺងអាប់ដោយសម្តីមនុស្ស ឬសត្វស្លាបច្រើន។	

ឃ.សំណួរត្រិះរិះ

១. ចូរបកស្រាយកំណាព្យខាងក្រោម៖

លោកហៅថាឆ្កួតបី	មួយឆ្កួតស្រីមួយឆ្កួតស្រា
មួយឆ្កួតល្បែងពាលា	លេងប៉ោធូកំតាត់។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. ចូរបកស្រាយកំណាព្យខាងក្រោម៖

ភ្លើងក្រៅកុំនាំទៅក្នុង ឱ្យឆេះបំផ្លុង រឹងផ្ទុំបង្កាត់។

ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឱ្យឆេះឯក្រៅ។

អុជអាលបណ្តាលឱ្យក្តៅ ដាលដល់កូនចៅ អសោចអប្រិយ។

ឱ្យនាងខំប្រឹងស្មារតី មើលភ្លើងទាំងបី រក្សាឱ្យគង់។

ភ្លើងនោះឱ្យគុណពុំលង់ នឹងឱ្យឧត្តុង្គ ឧត្តមកន្លង។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

៣. ចូរបង្ហាញតម្លៃអប់រំនៃអត្ថបទដកស្រង់កំណាព្យច្បាប់ប្រុស និងច្បាប់ស្រី។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✍ សំណេរៈ ការតែងកំណាព្យ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើដូចម្តេចដែលហៅថា កំណាព្យ?

ក. សិល្បៈសម្រាប់យកទៅសូត្រតែម្យ៉ាង

ខ. សិល្បៈបង្ហាញតែអំពើអសីលធម៌

គ. សិល្បៈបង្ហាញតែរឿងរ៉ាវប្រវត្តិសាស្ត្រ

ឃ. សិល្បៈអន្ទងអារម្មណ៍ ប្រកបដោយរណ្តំ ចង្វាក់ ចួន យ៉ាងពីរោះ

២. តើត្រូវធ្វើយ៉ាងណា ដើម្បីអាចតែងកំណាព្យបានល្អ?

ក. ត្រូវដឹងពីរបៀបសូត្រកំណាព្យ

ខ. ត្រូវស្គាល់ពីប្រភពកំណាព្យ

គ. ត្រូវស្គាល់ឈ្មោះអ្នកនិពន្ធ និងឆ្នាំតែង

ឃ. ត្រូវចាំឱ្យច្បាស់ពីកាព្យមាត្រ និងចំណាប់ចួន

៣. តើមួយណាជាកាព្យមាត្រនៃកំណាព្យបទពាក្យ៨?

ក. ក្នុង១ល្បះមាន ៨ឃ្លា ១ឃ្លាមាន ៨ព្យាង្គ

ខ. ក្នុង១ល្បះមាន ៨ឃ្លា ១ឃ្លាមាន ៤ព្យាង្គ

គ. ក្នុង១ល្បះមាន ៤ឃ្លា ១ឃ្លាមាន ៤ព្យាង្គ

ឃ. ក្នុង១ល្បះមាន ៤ឃ្លា ១ឃ្លាមាន ៨ព្យាង្គ

៤. "អនិច្ចាតោថ្មលោកកសាង　　មើលថាថាងយ៉ាងរស់ស្ទុះប្រៃប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ចាត់ខ្ចាយ　　ស្តាយអើយស្តាយមិនគួរមកពិការ"។
តើកំណាព្យនេះ តែងជាបទអ្វី?

ក. បទពាក្យ៨ ខ. បទពាក្យ៧

គ. បទព្រហ្មគីតិ ឃ. បទកាកគតិ

៥. ចំណាប់ចូនក្នុងវគ្គបទពាក្យ៨គឺ៖

ក. ព្យទី៨ ឃ្លាទី១ ចូននឹងព្យទី៣ ឃ្លាទី៣ ហើយចូននឹងព្យទី៣ឃ្លាទី៤

ខ. ព្យទី៨ ឃ្លាទី១ ចូននឹងព្យទី៣ ឃ្លាទី២ ព្យទី៨ឃ្លាទី២ ចូននឹងព្យទី៣ ឃ្លាទី៣ ហើយចូននឹងព្យទី៣ឃ្លាទី៤

គ. ព្យទី៨ ឃ្លាទី១ ចូននឹងព្យទី៣ ឬទី៥ ឃ្លាទី២ ព្យទី៨ឃ្លាទី២ ចូននឹងព្យទី៨ ឃ្លាទី៣ ហើយចូននឹង ព្យទី៣ ឬទី៥ ឃ្លាទី៤

ឃ. ព្យទី៨ ឃ្លាទី១ ចូននឹងព្យទី៨ ឃ្លាទី២ ព្យទី៣ឃ្លាទី២ ចូននឹងព្យទី៣ ឃ្លាទី៣ ហើយចូននឹងព្យទី៣ឃ្លាទី៤

៦. តើមួយណា ជាចំណាប់ចូនឆ្លងល្បះនៃកំណាព្យបទពាក្យ៨?

ក. ព្យ៨ ឃ៤ ល្បះ១ ចូននឹង ព្យ៨ ឃ២ ល្បះ២

ខ. ព្យ៨ ឃ១ ល្បះ១ ចូននឹង ព្យ៤ ឃ៤ ល្បះ២

គ. ព្យ៨ ឃ២ ល្បះ១ ចូននឹង ព្យ៨ ឃ២ ល្បះ២

ឃ. ព្យ៨ ឃ៣ ល្បះ១ ចូននឹង ព្យ៨ ឃ៣ ល្បះ២

ខ.សំណួរត្រិះរិះ

១. ចូរជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានបទខាងក្រោម ហើយតែងកំណាព្យបទពាក្យ៨ឱ្យបាន៣ល្បះ៖

ក. មិត្តភាព

ខ. មរតកវប្បធម៌ជាតិ

គ.ជំងឺកូវីត១៩

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✿✿ មេរៀនទី៦៖ ការគោរពច្បាប់ ✿✿

📖 សិក្សារឿងមាលាដួងចិត្ត

(ការបង្ហាញអត្ថបទ)

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើចំណងជើង "មាលាដួងចិត្ត" មានន័យសំដៅដល់អ្វី?

ក. ផ្កាដែលក្រៀមស្វិត ខ. ផ្កាដែលគេបានក្រងរួច

គ. នារីដែលគួរឱ្យស្អប់ ឃ. នារីជាទីស្រឡាញ់

២. តើរឿងមាលាដួងចិត្ត ជាស្នាដៃរបស់អ្នកនិពន្ធរូបណា?

ក. លោក នូ ហាច ខ. លោក រីម គីន

គ. លោក ញ៉ុក ថែម ឃ. លោកឧកញ៉ាសន្ធរវោហារម៉ុក

៣. តើរឿងមាលាដួងចិត្ត មានប្រភពមកពីណា?

ក. រឿងរ៉ាវក្នុងសង្គមខ្មែរ ខ. ប្រវត្តិសាស្ត្រសៀម

គ. សម័យកម្ពុជាប្រជាធិបតេយ្យ ឃ. សម័យសង្គមរាស្ត្រនិយម

៤. តើរឿងមាលាដួងចិត្ត ចាត់ជាប្រភេទអត្ថបទអ្វី?

ក. រឿងព្រេង ខ. អត្ថបទប្រវត្តិសាស្ត្រ

គ. រឿងទាក់ទងសាសនា ឃ. រឿងប្រលោមលោក

៥. តើរឿងមាលាដួងចិត្ត បង្កប់សង្គមបរិយាកាសបែបណា?

ក. សង្គមខ្មែរសម័យសក្តិភូមិ ខ. សង្គមខ្មែរសម័យមូលធននិយម

គ. សង្គមខ្មែរសម័យបុព្វកាល ឃ. សង្គមខ្មែរសម័យសង្គ្រាមលោកលើកទី២

ខ.សំណួរត្រិះរិះ

១. ចូរបង្ហាញពីសង្គមបរិយាកាសនៃរឿងមាលាដួងចិត្ត។

.....

.....

.....

.....

.....

.....

.....

២. ហេតុអ្វីបានជាគេថា រឿងមាលាដួងចិត្តជាប្រលោមលោកទំនើប?

.....

.....

.....

.....

.....

.....

.....

.....

📖 សិក្សារឿងមាលាដួងចិត្ត

(សន្ធេបរឿងវគ្គទី១-៦)

លំហាត់

ក. ចូរអ្នកគួសរង្វង់ជុំវិញចម្លើយត្រឹមត្រូវតែមួយគត់

១. តើរឿងមាលាដួងចិត្តមានទាំងអស់ប៉ុន្មានវគ្គ?

ក. ៨វគ្គ ខ. ៩វគ្គ

គ. ១០វគ្គ ឃ. ១១វគ្គ

២. តើមួយណា ជាខ្លឹមសារនៃវគ្គទី១នៃរឿងមាលាដួងចិត្ត?

ក. ទិដ្ឋភាពវិទ្យាល័យព្រះស៊ីសុវត្ថិ

ខ. ការជួបគ្នារវាងទីយាវុធ និងចន្ទមណី

គ. ស្ថានភាពប្រទេសជ្រួលច្របល់ដោយសារសង្គ្រាម

ឃ. ទីយាវុធក្លាយជាមន្ត្រីរាជការនៅខេត្តពោធិសាត់

៣. តើទីយាវុធ និងនាងចន្ទមណីត្រូវជាអ្វីនឹងគ្នា?

ក. គូសង្សារ ខ. ប្តីប្រពន្ធ

គ. បងប្អូន ឃ. ចៅហ្វាយនាយ និងកូនចៅ

៤. តាមរយៈសាច់រឿង តើស្ថានភាពប្រទេសកម្ពុជាមានលក្ខណៈបែបណា ក្នុងពេលផ្ទុះសង្គ្រាមលោកលើកទី២?

ក. ប្រទេសរងការទម្លាក់គ្រាប់បែក ខ. បង្ខំប្រជាជនខ្មែរឱ្យរៀនភាសាជប៉ុន

គ. បិទទំនាក់ទំនងការទូតជាមួយប្រទេសជិតខាង ឃ. សាលារៀនត្រូវបិទ

៥. ហេតុអ្វីបានជានាងចន្ទមណីរំលែកត្រឡប់ទៅប្រទេសសៀមវិញ?

ក. ដោយសារឪពុកនាងមិនចង់ឱ្យនាងទាក់ទងជាមួយតីឃារុងទៀត

ខ. ពីព្រោះប្រទេសខ្មែរ បណ្តេញជាតិសាសន៍សៀមទាំងអស់ឱ្យចេញពីប្រទេស

គ. ដោយសារម្តាយនាងឈឺ ហេតុនេះនាងនិងឪពុកត្រូវត្រឡប់ទៅវិញ

ឃ. ដោយសារនាងឈ្លោះគ្នាជាមួយទីឃារុង មិនចង់ចូបទីឃារុងទៀត

៦. ហេតុអ្វីបានជាទីឃារុងត្រូវទៅប្រទេសវៀតណាម?

ក. ព្រោះទីឃារុងត្រូវបានតែងតាំងជាមេបញ្ជាការកងទ័ពនៅវៀតណាម

ខ. ព្រោះប្រទេសខ្មែរទទួលរងនូវការទម្លាក់គ្រាប់បែក ប្រជាជនទាំងអស់ត្រូវភៀសខ្លួន

គ. ព្រោះទីឃារុងត្រូវបញ្ជូនឱ្យទៅរៀននៅទីនោះជាមួយសិស្សឯទៀត

ឃ. ព្រោះទីឃារុងត្រូវទៅពិនិត្យការងារនៅប្រទេសវៀតណាម តាមបញ្ជាចៅហ្វាយខេត្ត

៧. ក្រោយសង្គ្រាមលោកលើទី២បានបញ្ចប់ តើទីឃារុងប្រកបការងារជាអ្វី?

ក. ទីឃារុងក្លាយជាអ្នកការសែតដ៏ល្បីល្បាញនៅភ្នំពេញ

ខ. ទីឃារុងក្លាយជាមេទ័ព បម្រើការនៅក្នុងជួរពិសេស

គ. ទីឃារុងក្លាយជាបាល័ដ្ឋស្រុក នៅខេត្តពោធិ៍សាត់

ឃ. ទីឃារុងក្លាយជាចៅហ្វាយខេត្ត នៅខេត្តពោធិ៍សាត់

៨. តើថៅកែហុងឈីដេញថ្លៃទទួលធ្វើការងារអ្វី?

ក. ថៅកែហុងឈីដេញថ្លៃទទួលផលិតសម្ភារៈការិយាល័យជូនមន្ត្រីរាជការ

ខ. ថៅកែហុងឈីដេញថ្លៃទទួលធ្វើផ្លូវនៅក្នុងខេត្តពោធិ៍សាត់

គ. ថៅកែហុងឈីដេញថ្លៃទទួលដេរសម្លៀកបំពាក់ជូនមន្ត្រីរាជការ

ឃ. ថៅកែហុងឈីដេញថ្លៃជីកអណ្តូងទឹកសម្រាប់ប្រជាជនប្រើប្រាស់

៩. ហេតុអ្វីបានជាថៅកែហុងឈីយកប្រាក់ឱ្យទីឃារុធ?

ក. ព្រោះហុងឈីជំពាក់ប្រាក់ទីឃារុធ ខ. ព្រោះនោះជាថ្លៃប្រាក់ខែទីឃារុធ

គ. ព្រោះទីឃារុធសុំខ្ចីប្រាក់គាត់ ឃ. ព្រោះថៅកែចង់សូកប៉ាន់ទីឃារុធ

១០. តើចំណុចត្រង់ណា ដែលបង្ហាញថាទីឃារុធជាមន្ត្រីរាជការល្អ?

ក. គិតពីប្រយោជន៍ផ្ទាល់ខ្លួនជាធំ ខ. មានទំនាក់ទំនងល្អជាមួយអ្នកមានលុយ

គ. ប្រឹងប្រែងធ្វើការដើម្បីបានឡើងតំណែង ឃ. មិនទទួលប្រាក់សំណូក

ខ. ចូររៀបរឿងនៃរឿងអាណាឌួចចិត្ត ទៅតាមលំដាប់លំដោយឱ្យបានត្រឹមត្រូវ

☞ ពពកខ្មៅបាំងស្នេហា ស្ថានការណ៍កាន់តែអ័ព្ទអួរឡើង យល់សប្តិគង់ក្លាយជាការពិតមួយដងមួយកាលដែរ ស្រឡាញ់ជាតិបង្ក្រាបស្នេហា សន្តិភាពក្រុងតូក្យូ ភ្នំគូលែនហានបរមសុខជួបភ័ក្ត្រហើយតែមានឧបសគ្គធំរារាំង សេចក្តីលំបាកនៃអ្នករាជការតូច កង្ហារត្រដោកអោទ៍លើចុងអំពិល វិទ្យាល័យគ.ស១៩៣៩ អរុណាស្នេហា

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

គ. ចូរបំពេញឃ្លាពាក្យ "ត្រូវ ឬខុស" នៅក្នុងចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ..... ទីឃារុធជាសិស្សនៃវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលពូកែលើមុខវិជ្ជាសង្គម។

២. ..... នាងចន្ទមណីជាជនជាតិសៀម ដែលបានមកលេងនៅប្រទេសកម្ពុជា ជាមួយលោកទេពកោសល្យជាឪពុក។

២. ..... នាងចន្ទមណី និងលោកទេពកោសល្យ ជាគិញសម្ងាត់ដែលសៀមបញ្ជូនមកយកការណ៍នៅប្រទេសកម្ពុជា។

៣. ..... ទីឃាវុធបានជួយយកអាសារនាងចន្ទមណី និងគ្រួសារឱ្យស្គាល់ទីក្រុងភ្នំពេញ និងតំបន់ទេសចរណ៍នៅកម្ពុជា។

៤. ..... លោកទេពកោលស្សវិចិត្រករ ព្យាយាមបំបែកបំបាក់ទីឃាវុធ និងនាងចន្ទមណី នៅពេលដឹងថាអ្នកទាំងពីរចាប់ចិត្តស្រឡាញ់គ្នា។

៥. ..... ទីឃាវុធ និងចន្ទមណីតែងដើរកម្សាន្តជានិច្ច រហូតធ្វើឱ្យទីឃាវុធភ្លេចការសិក្សា និងគ្រួសារ។

៦..... ទីឃាវុធសោកស្តាយជាខ្លាំងដែលមិនបានជូនដំណើរនាងចន្ទមណីវិលត្រឡប់ទៅប្រទេសសៀមវិញ ព្រោះម្តាយនាងចន្ទមណីទទួលមរណៈភាព។

ឃ. សំណួរត្រិះរិះ

១. តើអ្នកយល់ថា ការដែលទីឃាវុធមិនទទួលសំណូកពីថៅកែហុងឈី ជាការត្រឹមត្រូវឬទេ? ហេតុអ្វី?

.....

.....

.....

.....

.....

.....

.....

.....

.....

២. ចូរវិភាគតួអង្គ ថៅកែហុងឈី និងលោកចៅហ្វាយខេត្ត។

📖 សិក្សារឿងមាណដួងចិត្ត

(សង្ខេបរឿងវគ្គទី៧-១១)

លំហាត់

ក. ចូរអ្នកគូសទង្វង់ជុំវិញចម្លើយត្រឹមត្រូវតែមួយគត់

១. តើមួយណាជាចំណងជើងវគ្គទី៧?

ក. ស្រឡាញ់ជាតិបង្ក្រាបស្នេហា ខ. សន្តិភាពក្រុងតូក្យូ

គ. កង្ហារត្រដោកវោទ៍លើចុងអំពិល ឃ. ស្ថានការណ៍កាន់តែអ័ព្ទអូរឡើង

២. តើលោកចៅហ្វាយខេត្តមានប្រតិកម្មបែបណា នៅពេលទីឃារុធមិនទទួលប្រាក់ពីថៅកែហុងឈី?

ក. លោកចៅហ្វាយខេត្តបានបញ្ឈប់ការងារទីឃារុធ

ខ. លោកចៅហ្វាយខេត្តមិនមានប្រតិកម្មអ្វីទាំងអស់ ព្រោះលោកយល់ស្របនឹងទីឃារុធ

គ. លោកចៅហ្វាយខេត្តបានផ្តល់រង្វាន់ជាច្រើនដល់ទីឃារុធ

ឃ. លោកចៅហ្វាយខេត្តបានស្តីបន្ទោសទីឃារុធ និងផ្លាស់ទីឃារុធឱ្យទៅធ្វើការងារនៅតំបន់ផ្សេង

៣. ហេតុអ្វីបានជាទីឃារុធខឹងស្អប់នឹងនាងចន្ទមណី?

ក. ព្រោះនាងចន្ទមណីមានសង្ឃារថ្មី

ខ. ព្រោះនាងចន្ទមណីបានវាយដំទីឃារុធ

គ. ព្រោះឪពុកនាងចន្ទមណីហាមមិនឱ្យទាក់ទង

ឃ. ព្រោះទីឃារុធគិតថានាងចន្ទមណីជាគិញសំងាត់

៤. ហេតុអ្វីបានទីឃារុធត្រូវរបួស?

ក. ព្រោះទីឃារុធបានទៅធ្វើសង្គ្រាមជាមួយសៀម

ខ. ព្រោះទីឃារុធបានវាយតប់ជាមួយជនពាល

គ. ព្រោះទីឃារុធគ្រោះថ្នាក់ចរាចរណ៍

ឃ. ព្រោះទីឃារុធត្រូវចោរប្លន់នៅកណ្តាលផ្លូវ

៥. តើអ្នកណាជាអ្នកកាត់ខេត្តបាត់ដំបង សៀមរាប ស្វឹងត្រែងទៅឱ្យសៀម?

ក. ជប៉ុន ខ. វៀតណាម

គ. ចិន ឃ. បារាំង

៦. តើទីឃារុធប្រកបការងារអ្វី ក្រោយពេលចប់សង្គ្រាមខ្មែរ សៀម?

ក. អ្នកជំនួញ ខ. មេទ័ព

គ. កសិករ ឃ. ចៅហ្វាយស្រុក

៧. តើនៅពេលដឹងថានាងចន្ទមណីមិនមែនជាគិញសំងាត់ទីឃារុធមានអារម្មណ៍យ៉ាងណា?

ក. ទីឃារុធខកចិត្តយ៉ាងខ្លាំង ខ. ទីឃារុធសប្បាយចិត្តជាខ្លាំង

គ. ទីឃារុធខឹងស្អប់នាងចន្ទមណីលើសដើម ឃ. ទីឃារុធមានអារម្មណ៍ខ្មាសអៀន

៨. តើចំណុចត្រង់ណាដែលបង្ហាញថា ទីឃារុធ និងនាងចន្ទមណីទុកបញ្ហាជាតិធំជាងស្នេហា?

ក. អ្នកទាំងពីរហ៊ានសម្លាប់គូសង្សារដើម្បីជាតិ

ខ. អ្នកទាំងពីរចេញមុខជួយជាតិក្នុងគ្រាអាសន្ន

គ. អ្នកទាំងពីរហ៊ានធ្វើជាគិញសំងាត់ដើម្បីស៊ើបការ

ឃ. អ្នកទាំងពីរបានចូលធ្វើជាទាហានការពារជាតិ

ខ.សំណួរត្រិះរិះ

១. ចូរវិភាគតួអង្គទីឃាវុធ និងនាងចន្ទមណី។

.....

.....

.....

📖 សិក្សារឿងមាណដួងចិត្ត

(វិភាគអត្ថន័យ)

លំហាត់

ក. ចូរឆ្លើយសំនួរខាងក្រោមដោយជ្រើសរើសចម្លើយត្រឹមត្រូវតែមួយគត់

១. ដូចម្តេចដែលហៅថាការវិភាគតួអង្គ?

ក. ជាការវិភាគឱ្យឃើញពីជាតិកំណើតតួអង្គ

ខ. ជាការវិភាគឱ្យឃើញតែចំណុចល្អរបស់តួអង្គ

គ. ជាការវិភាគឱ្យឃើញតែចំណុចអាក្រក់របស់តួអង្គ

ឃ. ជាការវិភាគឱ្យឃើញពីលក្ខណសម្បត្តិតួអង្គ

២. តើទីយាវុធជាមនុស្សបែបណា?

ក. យុវជនអង់អាចក្លាហាន

ខ. ចូលចិត្តការសប្បាយស្រីស្រាល្បែង

គ. កំសាក រត់ចោលស្រុកកំណើត

ឃ. មនុស្សគិតតែប្រយោជន៍ផ្ទាល់ខ្លួន

៣. តើនាងចន្ទមណីជាមនុស្សបែបណា?

ក. មន្ត្រីរាជការល្អ

ខ. មិនហ៊ានទទួលស្គាល់ការពិត

គ. ធ្វេសប្រហែសនឹងការងារ

ឃ. មានភក្តីភាពចំពោះស្នេហា

៤. តើចំណុចមួយណា ជាលក្ខណសម្បត្តិលោកចៅហ្វាយខេត្ត?

ក. មានសន្តានចិត្តទូលាយ

ខ. មានស្មារតីទទួលខុសត្រូវ

គ. មិនគិតប្រយោជន៍ផ្ទាល់ខ្លួន

ឃ. មានចំណេះដឹងខ្ពង់ខ្ពស់

៥. តើចំណុចមួយណាជាលក្ខណសម្បត្តិរបស់ថៅកែហុងឈី?

ក. ជាមនុស្សមិនលក់ឧត្តមគតិខ្លួន ខ. ជាមនុស្សស្អប់ខ្ពើមអំពើពុករលួយ

គ. ជាមន្ត្រីស្គាល់កាល:ទេស: ឃ. ជាមនុស្សអាងអំណាចទឹកប្រាក់

ខ.សំណួរត្រិះរិះ

១. ហេតុអ្វីបានជាគេនិយាយថា រឿងមាលាដួងចិត្តបង្ហាញគំនិតផ្សះផ្សាទំនាស់ជាតិសាសន៍? ចូរពន្យល់ដោយលើកអំណះអំណាងមកបង្ហាញ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. តើរឿងមាលាដួងចិត្តផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

⊶ វេយ្យាករណ៍៖ កាលរបស់កិរិយា អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើល្បះមួយណាដែលប្រើពាក្យជ្រាប់ "អតីតកាល"?

ក. ព្រឹកនេះ អាកាសធាតុប្រែត្រជាក់ជាងធម្មតា។

ខ. យើងទាំងអស់គ្នាកំពុងសិក្សាពីវេយ្យាករណ៍ខ្មែរ។

គ. បច្ចុប្បន្ននេះ បញ្ហាគ្រោះថ្នាក់ចរាចរណ៍ជាបញ្ហាគួរឱ្យបារម្ភបំផុត។

ឃ. យើងបានទៅទស្សនាប្រាសាទអង្គរវត្ត កាលពីសប្តាហ៍មុន។

២. តើល្បះមួយណាដែលប្រើពាក្យជ្រាប់ "បច្ចុប្បន្នកាល"?

ក. ខ្ញុំនឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅខែក្រោយ។

ខ. ខ្ញុំធ្លាប់ជាក្មេងដែលរពឹសបំផុត កាលពីខ្ញុំនៅក្មេង។

គ. ពេលនេះមានភ្លៀងធ្លាក់យ៉ាងខ្លាំងនៅរាជធានីភ្នំពេញ។

ឃ. ឆ្នាំទៅ សិស្សសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ បានទៅចូលរួមទស្សនកិច្ច សិក្សានៅប្រទេសជប៉ុន។

៣. តើល្បះមួយណាដែលប្រើពាក្យជ្រាប់ "អនាគតកាល"?

ក. ម្តាយខ្ញុំបានវេចនំអន្សមជ្រូក កាលពីម្សិលមិញ។

ខ. មុននេះបន្តិចមានក្មេងទំនើងមួយក្រុម ត្រូវបានសមត្ថកិច្ចព័ទ្ធចាប់នៅក្បែរផ្សារ។

គ. គ្រូសារខ្ញុំនឹងទៅលេងខេត្តកោះកុង នាវិស្សមកាលតូចខាងមុខនេះ។

ឃ. សព្វថ្ងៃយើងសង្កេតឃើញថា ការធ្លាក់ចុះសុជីវធម៌ក្នុងសង្គមខ្មែរគួរឱ្យព្រួយបារម្ភ។

៤. តើល្បះមួយណាដែលប្រើជំនួយកិរិយាប្រាប់ "អតីតកាល"?

ក. គាត់បានរស់នៅតំបន់នេះអស់រយៈពេលជាងម្តៃឆ្នាំមកហើយ។

ខ. លោកតានឹងបង្ហាញពួកយើងពីរបៀបលេងឧបករណ៍ភ្លេងខ្មែរ។

គ. លោកគ្រូកំពុងបង្រៀនយើងទាំងអស់គ្នាពីរបៀបសរសេរតែងសេចក្តីពន្យល់។

ឃ. ខែក្រោយ យើងទាំងអស់គ្នានឹងត្រូវចូលរៀនវិញហើយ!

៥. តើពាក្យមួយណា ជាជំនួយកិរិយាប្រាប់ "អនាគតកាល"?

ក. បាន ខ. មិនបាន

គ. កំពុងឬ កំពុងតែ ឃ. នឹង

ខ. ចូរសរសេរពាក្យ "អតីតកាល បច្ចុប្បន្នកាល អនាគតកាល" នៅខាងមុខល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

ឧ. .....អនាគតកាល.. ១. ខ្ញុំនឹងខិតខំរៀនសូត្រដើម្បីអនាគតរបស់ខ្ញុំ។

..... ២. បងស្រីខ្ញុំបានទៅជីកដំឡូងដៃខ្លាកាលពីព្រឹកមិញ។

..... ៣. ច្បាប់ស្តីពីការគោរសិទ្ធអ្នកដទៃត្រូវបានប្រជាជនខ្មែរទាំងប្រុសទាំស្រីយកចិត្តទុកដាក់យ៉ាងខ្លាំង នាពេលបច្ចុប្បន្ននេះ។

..... ៤. រាជរដ្ឋាភិបាលបានចាត់ឱ្យមន្ត្រីគ្រប់លំដាប់ថ្នាក់ យកចិត្តទុកដាក់ចំពោះសុខទុក្ខប្រជារាស្ត្រគ្រប់តំបន់។

..... ៥. ព្រឹកនេះនៅវិទ្យាល័យព្រះស៊ីសុវត្ថិ បានរៀបចំការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

គ.សំណួរត្រិះរិះ

១. ចូរអ្នកប្តូរល្បះខាងក្រោមនេះពីបច្ចុប្បន្នកាល ឱ្យទៅជាល្បះអតីតកាល។

ក. ភ្ញៀវទេសចរកំពុងទៅទស្សនាប្រាសាទអង្គរវត្ត។

ខ. រាជរដ្ឋាភិបាលកំពុងឱ្យប្រជារាស្ត្របណ្តាក់ទុនសម្រាប់ប្រកបមុខរបរកសិកម្ម។

គ. សិស្សានុសិស្សកំពុងសិក្សាភាសាខ្មែរ ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. ចូរអ្នកឆ្លើយនឹងសំណួរខាងក្រោមនេះ ដោយប្រើជំនួយកិរិយា និងពាក្យប្រាប់បច្ចុប្បន្នកាលរបស់កិរិយា។

ក. តើថ្ងៃនេះ អ្នកធ្វើកិច្ចការអ្វីខ្លះក្នុងគ្រួសារអ្នក ?

ខ. តើសព្វថ្ងៃនេះ យើងមានកាតព្វកិច្ចអ្វីខ្លះ ដើម្បីការពារបេតិកភណ្ឌជាតិ ?

គ. តើនៅប្រទេសយើងនាពេលបច្ចុប្បន្ននេះ មានសត្វព្រៃរស់នៅតំបន់ណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

🕮 អំណាន៖ សេចក្តីប្រកាសព័ត៌មាន

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអ្នកយល់ថា ការធ្វើសេចក្តីប្រកាសព័ត៌មានធ្វើឡើងដើម្បីអ្វី?

ក. ដើម្បីប្រមូលព័ត៌មានទាំងឡាយពីមហាជន

ខ. ដើម្បីផ្តល់ព័ត៌មានពិតជាក់លាក់ណាមួយឱ្យមហាជនបានដឹងឮ

គ. ដើម្បីស្វែងរកព័ត៌មានផ្សេងៗនៅក្នុងសង្គមរស់នៅ

ឃ. ដើម្បីតានដានហេតុការណ៍ណាមួយ ទៅតាមដំណើររឿងជាក់ស្តែង

២. តាមរយៈអត្ថបទ តើស្ថានប័នណាជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាននេះ?

ក. ក្រសួងរ៉ែ និងថាមពល ជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាន

ខ. ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាន

គ. ក្រសួងធនធានទឹក និងឧតុនិយម ជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាន

ឃ. ក្រសួងការពារជាតិ ជាអ្នកធ្វើសេចក្តីប្រកាសព័ត៌មាន

៣. តើក្រសួងធនធានទឹកធ្វើសេចក្តីប្រកាសព័ត៌មានពីបញ្ហាអ្វី?

ក. បញ្ហាគ្រោះថ្នាក់ចរាចរណ៍ដៃលើតឡើងនៅខេត្តដែលជាប់បឹងទន្លេសាប

ខ. បញ្ហាគ្រោះរាំងស្ងួតដែលកើតឡើងនៅតំបន់ទំនាបកណ្តាល

គ. បញ្ហាទឹកជំនន់ដែលកំពុងបំផ្លាញផ្ទះ និងដំណាំរបស់ប្រជាជននៅខេត្តបាត់ដំបង

ឃ. បញ្ហាកម្ពុជានឹងរងខ្យល់ឥទ្ធិពលព្យុះនៅតំបន់មាត់សមុទ្រ

៤. តើសេចក្តីប្រកាសព័ត៌មាន ធ្វើឡើងដើម្បីអ្នកណា?

ក. សាធារណៈជនទូទៅដែលរស់នៅតំបន់មាត់សមុទ្រ និងខ្ពង់រាបភាគខាងជើង ល្បសាន

ខ. សាធារណៈជនទូទៅដែលរស់នៅតំបន់វាលទំនាប និងខ្ពង់រាបភាគខាងជើង ល្បសាន

គ. សាធារណៈជនទូទៅដែលរស់នៅតំបន់ទីក្រុង និងខ្ពង់រាបភាគខាងជើង ល្បសាន

ឃ. សាធារណៈជនទូទៅដែលរស់នៅតំបន់មាត់សមុទ្រនិងខ្ពង់រាបភាគខាងត្បូង ល្បសាន

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ **ឥទ្ធិពល ធនធានទឹកនិងឧតុនិយម ប្រុងប្រយ័ត្នខ្ពស់ អាជ្ញាធរដែនដី ធាតុអាកាស**

កម្ពុជារងឥទ្ធិពលព្យុះនៅតំបន់មាត់សមុទ្រ រលកកម្ពស់ ១ទៅ ២ម៉ែត

ខ្ពង់រាបខាងជើងនិងល្បសានភ្លៀងច្រើន

រាជធានីភ្នំពេញ : សេចក្តីជូនដំណឹងរបស់ក្រសួង..... បានឱ្យដឹងថា បន្ទាប់ពីបានធ្វើការសង្កេតតាមដានលើស្ថានភាព.....រួចមកឃើញថា ព្យុះទី២ឈ្មោះកុងស៊ុន(CONSON) ដែលបានកើតឡើងនៅសមុទ្រប៉ាស៊ីហ្វិក កាលពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១០ កន្លង មក បានធ្វើដំណើរឆ្លងកាត់ប្រទេសហ្វីលីពីន មកសមុទ្រចិនខាងត្បូង និងកំពុងបន្តដំណើរកាត់លើកោហាយណាំ ឆ្ពោះទៅភាគខាងត្បូងប្រទេសចិន ។

ព្យុះនេះនឹងមាន..... មកលើព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១០ ពិសេសនៅតំបន់មាត់សមុទ្រ តំបន់ខ្ពង់រាបខាងជើង និងតំបន់ខ្ពង់រាបភាគល្បសាន។ ស្ថានភាពបែបនេះ៖នឹងបង្កឱ្យមានភ្លៀងធ្លាក់ច្រើននិងខ្យល់បក់បោកខ្លាំងនៅតំបន់មាត់សមុទមានខេត្ត កោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត។ ឯរលកសមុទ្រមានកម្ពស់ពី ១ទៅ ២ម៉ែត។

ដោយឡែក ចំពោះខេត្តព្រះវិហារ ខេត្តរតនគិរី ខេត្តមណ្ឌលគីរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែងអាចនឹងមានភ្លៀងធ្លាក់ច្រើន។ សេចក្តីជូនដំណឹងនេះ បានស្នើឱ្យប្រជាពលរដ្ឋដែលរស់នៅតំបន់ខាងលើ ពិសេសប្រជានេសាទតាមតំបន់សមុទ្រ សូមជ្រាបជាព័ត៌មានិងមានការ.....ចំពោះបាតុភូតធម្មជាតិខាងលើនេះ ក្រសួងធនធានទឹកនិងឧតុនិយមបាននិងកំពុង តាមដានស្ថានភាពអាកាសធាតុខាងលើនេះ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែមទៀត ក្នុងករណី ដែលស្ថានភាពរបស់ព្យុះនេះមានការប្រែប្រួល ។

គ.សំណួរត្រិះរិះ

១. ចូរប្អូនបង្ហាញពីទម្រង់នៃសេចក្តីប្រកាសព័ត៌មានតាមគម្រូនៃសេចក្តីប្រកាសព័ត៌មានក្នុងអត្ថបទ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

ᨾᨾ មេរៀនទី៧៖ ការទទួលខុសត្រូវ ᨾᨾ

🕮 បំណិន៖ ការញែកព្យាង្គ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. ដូចម្តេចដែលហៅថាពាក្យពហុព្យាង្គ?

ក. ជាពាក្យដែលមានមួយព្យាង្គ

ខ. ជាពាក្យដែលមានពីរព្យាង្គ

គ. ជាពាក្យដែលមានបីព្យាង្គ

ឃ. ជាពាក្យដែលមានច្រើនព្យាង្គ

២. ដូចម្តេចដែលហៅថាការញែកព្យាង្គ?

ក. ជាការបំបែកព្យាង្គឱ្យដាច់ៗពីគ្នា ដើម្បីងាយស្រួលអាន

ខ. ជាការបំបែកពាក្យដែលមានច្រើនព្យាង្គ មកជាពាក្យដែលមានពីរព្យាង្គ

គ. ជាការផ្គាច់ពាក្យឱ្យដាច់ពីគ្នា

ឃ. ជាការភ្ជាប់ពាក្យដែលមានមួយព្យាង្គ ឱ្យទៅជាពាក្យដែលមានច្រើនព្យាង្គ

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ពាក្យ	ចំនួនព្យាង្គ	ន័យ
ឧ. កនិដ្ឋា	ក:-និត-ថា	ប្អូន ប្អូនតូច ប្អូនពៅ។
ភគវតី	.....	.....
សម្បទា	.....	.....
បរមោវាទ	.....	.....
មគ្គទ្ទេសក៍	.....	.....
អស្តង្គត	.....	.....

គ.សំណួរត្រិះរិះ

១. ចូរស្រង់ពាក្យពហុព្យាង្គពីក្នុងអត្ថបទខាងក្រោមឱ្យបាន៥ពាក្យ រួចធ្វើការញែកព្យាង្គ ដើម្បីអាន ពាក្យទាំងនោះតាមលំនាំក្នុងតារាងខាងលើ ។

នៅគ្រប់កាល:ទេស: ពលរដ្ឋត្រូវរួមសាមគ្គីគ្នាធ្វើការតបស្នងមាតុភូមិរបស់យើង សិស្ស។ និស្សិត បញ្ញវន្ត វិនិពន្ធ សិល្បករ ត្រូវប្រើសមត្ថភាពដែលខ្លួនមាន ផ្សព្វផ្សាយដល់ជនរួមជាតិ នូវភាពថ្កុំថ្កើងនៃទឹកដីតាំងពីយុគសម័យបរមបុរាណ ធម្មជាតិ ទឹកដី វប្បធម៌ ប្រពៃណីដ៏ល្អផូរផង់ សូមឱ្យពលរដ្ឋគ្រប់រូបបង្កើនការយកចិត្តទុកដាក់និងបញ្ចេញអស់សមត្ថភាព ដើម្បីការពារថែរក្សា និងលើកកំពស់ភាពរុងរឿងរបស់ជាតិយើងគ្រប់ពេលវេលា ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ ការទទួលខុសត្រូវរបស់ធនញ៉ុយ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទ ការទទួលខុសត្រូវរបស់ធនញ៉ុយ មានដកស្រង់មកពីណា?

ក. រឿងកុលាបប៉ៃលិន ខ. រឿងមាយើង

គ. រឿងអ៊ុយលីសវិលវិញ ឃ. រឿងធនញ៉ុយ

២. តើរឿងធនញ៉ុយ អាចចាត់ជាអក្សរសិល្ប៍ប្រភេទណា?

ក. អក្សរសិល្ប៍ប្រជាប្រិយ ខ. អក្សរសិល្ប៍ឧបទេស

គ. អក្សរសិល្ប៍បុរាណ ឃ. អក្សរសិល្ប៍បរទេស

៣. តើធនញ៉ុយត្រូវទទួលខុសត្រូវលើកិច្ចការអ្វី?

ក. ការសាងសង់ផ្ទះ ខ. ការរៀបចំធ្វើស្រែចម្ការ

គ. ការបង្រៀនជនជាតិចិន ឃ. ការដោះស្រាយប្រស្នាជាមួយចិន

៤. តើអ្នកប្រាជ្ញចិនសុខចិត្តចុះចាញ់ធនញ៉ុយលើប្រធានបទអ្វី?

ក. ទាយគ្រាប់ឌីឡឹក ខ. អក្សរជើងក្តាម

គ. ធ្វើនំបញ្ចុក ឃ. ធ្វើខ្លែង

៥. តើធនញ៉ុយជាមនុស្សបែបណា?

ក. លង់ខ្លៅ គ្មានបញ្ញា ខ. គេចវេស មិនទទួលខុសត្រូវ

គ. មាន៖ រឹងរូស ឃ. មានទំនួលខុសត្រូវ

៦. តើចំណុចត្រង់ណាដែលបង្ហាញពីទំនាស់នៅក្នុងរឿង?

ក. ស្តេចខ្មែរឱ្យធនញ៉ុយដោះស្រាយប្រស្នា

ខ. ក្មេងៗអានអក្សរតាមធនញ័យណែនាំ

គ. អ្នកប្រាជ្ញចិនមកស្រុកខ្មែរដោះស្រាយប្រស្នា

ឃ. ធនញ័យប្រឡងប្រស្នាជាមួយអ្នកប្រាជ្ញចិន

៧. តើចំណុចត្រង់ណាជាតម្លៃអប់រំនៅក្នុងអត្ថបទ ការទទួលខុសត្រូវរបស់ធនញ័យ?

ក. ត្រូវមានភក្តីភាពចំពោះគូស្វាមីភរិយា ខ. ត្រូវទទួលខុសត្រូវចំពោះភារកិច្ចខ្លួន

គ. ត្រូវគោរពដឹងគុណមាតាបិតា ឃ. ត្រូវខិតខំធ្វើការរកស៊ីទាន់នៅក្មេង

ខ. ចូរបំពេញឃ្លាពាក្យ "ត្រូវ ឬខុស" នៅចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ..... ធនញ័យជាបុត្រព្រះរាជាខ្មែរ ហើយត្រៀមនឹងឡើងគ្រងរាជ្យសម្បត្តិជំនួសព្រះបិតា។

២. ..... ព្រះរាជាខ្មែរ ព្រួយព្រះទ័យព្រោះគ្មានអ្នកមានសមត្ថភាពអាចដោះស្រាយប្រស្នាជាមួយអ្នកប្រាជ្ញចិនបាន។

៣. ..... មន្ត្រីខ្មែរនាំគ្នាស្វះស្វែងរកធនញ័យដែលជាអ្នកប្រាជ្ញខ្មែរ ឱ្យទៅប្រកួតដោះស្រាយប្រស្នាជាមួយអ្នកប្រាជ្ញចិន។

៤. ..... ធនញ័យព្យាយាមរិះរកគ្រប់វិធីដើម្បីយកឈ្នះអ្នកប្រាជ្ញចិន។

៥. ..... ធនញ័យបដិសេដមិនព្រមជួយដោះស្រាយប្រស្នា ពីព្រោះធនញ័យនៅខឹងនឹងព្រះរាជាខ្មែរ ដែលបានរៀបចំផែនការសម្លាប់ខ្លួន។

៦. ..... ចិនមានមហិច្ឆតាចង់បាននគរខ្មែរមកជាចំណុះនគរខ្លួន។

៧. ..... អ្នកប្រាជ្ញចិនសុខចិត្តចាញ់ប្រស្នាបណ្ឌិតជ័យ លើប្រធានបទ អក្សរបុរាណ។

៨. ..... ក្រោយពេលទទួលជ័យជម្នះ ធនញ័យបានប្រមូលយកទ្រព្យសម្បត្តិ និងសំពៅទាំងអស់ដាក់ឃ្លាំង ហើយព្រមានអ្នកប្រាជ្ញចិនថា ថ្ងៃក្រោយបើឮឈ្មោះធនញ័យឱ្យកោតខ្លាច។

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. ប្រស្នា	ក. (ន.)ទឹកចិត្តរបស់ព្រះរាជា។	១→ .....
២. គ្រហស្ថ	ខ. (ន.) លោកធាតុ គឺភ្នំជាកំពែងព័ទ្ធជុំវិញនៃពិភពលោកទាំងមូល។	២→.....
៣. ចៅហ្វាំ	គ. (ន.) ជនអ្នកមានប្រាជ្ញា ជនអ្នកប្រព្រឹត្តល្អ។	៣→.....
៤. អាត្មា	ឃ. (ន.) ពាក្យ ឬសេចក្តីដែលមានអាថិកំបាំង ចំណោទលុះត្រាតែអ្នកមានប្រាជ្ញាទើបដឹង និងអាចដោះស្រាយបាន។	៤→.....
៥. បណ្ឌិត	ង. (កិ.) បានឡើងជាព្រះសព្វញ្ញូពុទ្ធបានដឹងនូវញេយ្យធម៌សព្វគ្រប់។	៥→.....
៦. មហាតលិក	ច. (ន.) អ្នកកាន់ការជំនុំ ត្រួតត្រាលើការងារផ្សេងៗ។	៦→.....
៧. ចក្រវាឡ	ឆ. (កិ.) តាំងភ្នាល់គ្នាដោយក្រយាតំណាង។	៧→.....
៨. ព្រះទ័យ	ជ. (ន.) អ្នកមានគ្រួសារ មានកូនចៅធម្មតា ផ្ទុយពីអ្នកបួស។	៨→.....
៩. អាមាត្រ	ឈ. (ន.) ខ្ញុំ ខ្លួនខ្ញុំ។	៩→ .....
១០. គ្រាស់	ញ. (ន.) មន្ត្រីជិតស្និទនឹងព្រះរាជា។	១០→ ...
	ដ. (ន.) សាស្ត្រា ច្បាប់វិន័យ។	

ឃ.សំណួរត្រិះរិះ

១. ចូរវិភាគតួអង្គធនញ្ជ័យ។

.....

.....

.....

.....

.....

.....

.....

.....

.....

២. តើចំណុចត្រង់ណាដែលបង្ហាញថាធនញ័យជាមនុស្សមានទំនួលខុសត្រូវ។

.....

.....

.....

.....

.....

.....

.....

.....

.....

៣. ចូរបង្ហាញតម្លៃអប់រំ ដែលស្តែងឡើងតាមរយៈអត្ថបទ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

⊶ ខេយ្យាករណ៍៖ គុណនាម

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. ដូចម្តេចដែលហៅថាគុណនាម?

ក. ជាពាក្យប្រើបញ្ជាក់លក្ខណៈឱ្យកិរិយា

ខ. ជាពាក្យប្រើបញ្ជាក់លក្ខណៈឱ្យប្រធាន

គ. ជាពាក្យប្រើបញ្ជាក់លក្ខណៈឱ្យសព្វនាម

ឃ. ជាពាក្យប្រើបញ្ជាក់លក្ខណៈឱ្យនាម

២. តើគុណនាមចែកជាប៉ុន្មានប្រភេទ?

ក. ២ប្រភេទ ខ. ៣ប្រភេទ

គ. ៤ប្រភេទ ឃ. ៥ប្រភេទ

៣. ដូចម្តេចដែលហៅថាគុណនាមមិនច្បាស់?

ក. ជាពាក្យសម្រាប់បង្ហាញព្រឹត្តិការណ៍នានា

ខ. ជាពាក្យសម្រាប់បង្ហាញពីបាតុភូតធម្មជាតិ

គ. ជាពាក្យសម្រាប់បង្ហាញសេចក្តីច្បាស់លាស់

ឃ. ជាពាក្យសម្រាប់បង្ហាញសេចក្តីមិនច្បាស់លាស់

៤. ដូចម្តេចដែលហៅថាគុណនាមសំណូរ?

ក. ជាពាក្យសម្រាប់បង្ហាញពីគុណភាពរបស់នាម

ខ. ជាពាក្យសម្រាប់បង្ហាញសភាពទូទៅរបស់នាម

គ. ជាពាក្យសម្រាប់បញ្ជាក់សួរពីសព្វនាម

ឃ. ជាពាក្យសម្រាប់បញ្ជាក់សួរពីនាមឬកន្សោមនាម

៥. ដូចម្តេចដែលហៅថាគុណនាមចង្អុល?

ក. ជាពាក្យសម្រាប់ឈ្មោះមនុស្ស សត្វ

ខ. ជាពាក្យសម្រាប់ភ្ជាប់ពាក្យមួយទៅមួយទៀត

គ. ជាពាក្យប្រាប់ចង្អុលបង្ហាញទីតាំងណាមួយ

ឃ. ជាពាក្យសម្រាប់ជំនួសគុណនាមដែលនិយាយរួចហើយ

៦. ដូចម្តេចដែលហៅថាគុណនាមចំនួន?

ក. ជាពាក្យប្រើសម្រាប់បញ្ជាក់ពីសព្វនាម

ខ. ជាពាក្យប្រើសម្រាប់រាប់ថ្នាក់ពាក្យ

គ. ជាពាក្យប្រើសម្រាប់បង្ហាញចំនួនពាក្យ

ឃ. ជាពាក្យប្រើសម្រាប់បញ្ជាក់ចំនួន ឬលំដាប់

៧. ដូចម្តេចដែលហៅថាគុណនាមកម្មសិទ្ធិ?

ក. ជាពាក្យប្រើសម្រាប់ប្រាប់កម្មសិទ្ធនាម

ខ. ជាពាក្យប្រើសម្រាប់ប្រាប់កម្មសិទ្ធិថ្នាក់ពាក្យ

គ. ជាពាក្យប្រើសម្រាប់ប្រាប់ម្ចាស់កម្មសិទ្ធិ

ឃ. ជាពាក្យប្រើសម្រាប់បង្ហាញកម្មសិទ្ធិប្រធាន

ខ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. គុណនាមប្រក្រតី	ក. មានពាក្យក្នុង ក្រៅ លើ មុខ ក្រោយ នៃ...។	១→.....
២. គុណនាមចំនួន	ខ. មានពាក្យនេះ នោះ ឯនេះ ឯនោះ...។	២→.....

៣. គុណនាមសំណួរ	គ. មានពាក្យនានា នីមួយៗ ផ្សេងៗ ទាំងឡាយ ....។	៣→.....
៤. គុណនាមមិនច្បាស់	ឃ. មានពាក្យ តូច ខ្ពស់ ទាប រលោង...។	៤→.....
៥. គុណនាមកម្មសិទ្ធិ	ង. មានពាក្យសូន្យ មួយ ពីរ..., ទីមួយ ទីពីរ...។	៥→.....
៦. គុណនាមចង្អុល	ច. មានពាក្យអ្វី អ្វីខ្លះ ណា ណាខ្លះ ប៉ុន្មាន...។	៦→.....
	ឆ. មានពាក្យខ្ញុំ ឯង វា គាត់ នាង យើង ពួកគាត់ ....។	

គ.សំណួរត្រិះរិះ

១. ចូរតែងល្បះដោយប្រើគុណនាមប្រក្រតី២ល្បះ គុណនាមចំនួន២ល្បះ គុណនាមចង្អុល ២ល្បះ គុណនាមសំណួរ២ល្បះ គុណនាមមិនច្បាស់២ល្បះ គុណនាមកម្មសិទ្ធិ២ល្បះ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ ការជក់បារីនាំឱ្យខូចសុខភាព

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទ "ការជក់បារីនាំឱ្យខូចសុខភាព" នេះដកស្រង់ចេញពីណា?

ក. សុខភាពប្រជាជនកម្ពុជា ខ. គ្រឿងញៀននៃកម្ពុជា

គ. ផលប៉ះពាល់នៃគ្រឿងញៀន ឃ. កម្រងឯកសារថ្នាំជក់ ឬសុខភាព

២. តើពលរដ្ឋកម្ពុជាស្លាប់ដោយសារការជក់បារីនៅឆ្នាំ១៩៩៧-២០០៧ មានចំនួនប៉ុន្មាននាក់?

ក. ៧៣ ៥០០នាក់ ខ. ៣៥ ៤០០នាក់

គ. ៦៥ ២០០នាក់ ឃ. ៤៥ ១០០នាក់

៣. តើការជក់បារីផ្តល់ផលប៉ះពាល់អ្វីខ្លះដល់សុខភាព?

ក. មានជំងឺតម្រងនោម ទឹកនោមផ្អែម ខ. មានជំងឺមហារីកសួត ជំងឺបេះដូង

គ. មានជំងឺលើសឈាម ក្រិនថ្លើម ឃ. មានជំងឺពោះវៀន ផ្តាសាយ

៤. តើមួយណា ជាវិធានការជួយកាត់បន្ថយការជក់បារី?

ក. លក់បារីតាមទីសាធារណៈ

ខ. ឃោសនាពីគុណសម្បត្តិនៃបារី

គ. អប់រំកុមារ យុវជនពីរបៀបប្រើប្រាស់បារី

ឃ. អប់រំ ផ្សព្វផ្សាយពីផលប៉ះពាល់នៃការជក់បារី

៥. តើក្នុងរយៈពេលមួយឆ្នាំ បារីបានសម្លាប់មនុស្សចំនួនប៉ុន្មាននាក់?

ក. ៥.៤ លាននាក់ ខ. ៥.៦ លាននាក់

គ. ៥.៧ លាននាក់ ឃ. ៥.៥ លាននាក់

៦. បើគិតក្នុងរយៈពេលមួយឆ្នាំ តើការជក់បារីបណ្តាលឱ្យខាតបង់សេដ្ឋកិច្ចកម្ពុជាចំនួនប៉ុន្មាន?

ក. ៣៦ លានដុល្លា ខ. ៣៧ លានដុល្លា

ខ.៣៨ លានដុល្លា ឃ. ៣៩ លានដុល្លា

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

☞ មហារីកបំពង់ក សុខភាព វិធានការ អត្រាមរណៈ ថ្នាំជក់ ក្រោះថ្នាក់ ទិវាប្រឆាំងនឹងការជក់បារី

អ្នកជក់បារីហាក់ដូចជាមិនសូវគិតគូរពី.....ឡើយ។ តាមការស្រាវជ្រាវបញ្ជាក់ថា .....នៃអ្នកជក់បារីបានកើនឡើងយ៉ាងខ្ពស់ជាង អត្រាមរណៈប្រមាណនៃអ្នកមិនជក់បារី។ ក្នុងចំណោមអ្នកជក់បារីទាំងឡាយ អ្នកស្លាប់ដោយសារការជក់បារីមានចំនួនពាក់កណ្តាល។ នៅក្នុង..... ថ្ងៃទី៣១ ខែឧសភា គ.ស ១៩៩៦ ក្រសួងសុខាភិបាលបានឱ្យដឹងថា អ្នកស្លាប់ដោយសារការជក់បារីនៅចុងសតវត្សទី២០នេះមានចំនួនប្រមាណ៦២លាននាក់ក្នុងប្រទេសកំពុងអភិវឌ្ឍ បណ្តាអ្នកស្លាប់ទាំងនោះបុរសមាន ៥២លាននាក់ និងស្ត្រីមាន១១លាននាក់។ តាមតួលេខថ្មីៗរបស់អង្គការសុខភាពពិភពលោកបានបង្ហាញថា .....បានសម្លាប់មនុស្ស១០០លាននាក់នៅក្នុងសតវត្សទី២០នេះ។ នាពេលបច្ចុប្បន្ននេះថ្នាំជក់សម្លាប់ មនុស្សជាច្រើនលាននាក់ក្នុងមួយឆ្នាំៗ ដោយជំងឺ..... មហារីកសួត ជំងឺបេះដូង ពុកធ្មេញ និងជំងឺផ្សេងជាច្រើនទៀត។

ដូចនេះយើងទាំងអស់គ្នា គួរនាំគ្នាចូលរួមផ្សព្វផ្សាយពី..... ដែលបណ្តាលមកពីការជក់បារី និងរិះរក..... ទប់ស្កាត់ការជក់បារីឱ្យបានទូលំទូលាយ។

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ

១. អត្រាមរណៈប្រមាណ	ក. ថ្ងៃប្រារព្ធពិធីមួយ។	១→.....
២. អភិវឌ្ឍ	ខ. ការតាំងចិត្តឈប់ប្រព្រឹត្ត ឈប់ធ្វើអ្វីមួយ។	២→.....
៣. វិធានការ	គ. ជនទូទៅ។	៣→.....
៤. សាធារណជន	ឃ. ចំនួនអ្នកស្លាប់។	៤→.....
៥. ប្តេជ្ញា	ង. ពាក្យសម្រាប់ញុំាងពាក្យខ្មៅឱ្យប្លែកឡើង។	៥→.....
៦. ទិវា	ច. បានចម្រើនលូតលាស់ ចម្រើនក្រៃលែង។	៦→.....
	ឆ. ចំនួនអ្នកស្លាប់។	

ឃ.សំណួរត្រិះរិះ

១.តើការជក់បារីបានផ្តល់ផលប៉ះពាល់យ៉ាងណាខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គមជាតិ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

២. តើអត្ថបទនេះផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ ការប្រគល់ការងារឱ្យទទួលខុសត្រូវ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើពាក្យទទួលខុសត្រូវមានន័យដូចម្តេច?

ក. ការលាក់បាំងចំណុចខ្សោយរបស់ខ្លួន

ខ. ការទទួលស្គាល់ចំណុចអវិជ្ជមានរបស់ខ្លួន

គ. ការទទួលស្គាល់ចំណុចវិជ្ជមានរបស់ខ្លួន

ឃ. ការទួលស្គាល់ រ៉ាប់រងរាល់សកម្មភាពរបស់ខ្លួន

២. តើអត្ថបទនេះមានប្រភពមកពីណា?

ក. វិធីសាស្ត្រគ្រប់គ្រង និងប្រើមនុស្សឱ្យអស់សមត្ថភាព

ខ. ការអប់រំមនុស្សវ័យជំទង់ នៅក្នុងពិភពលោក

គ. ការបង្រៀនមនុស្សឱ្យស្គាល់ពីការងាររបស់ខ្លួន

ឃ. បទពិសោធបុគ្គលជោគជ័យក្នុងពិភពលោក

៣. តើអត្ថបទនេះនិយាយពីអ្វី?

ក. អ្នកគ្រប់គ្រងទម្លាក់ភារកិច្ចខ្លួនចោលទាំងអស់

ខ. បុគ្គលិករុញច្រានភារកិច្ចខ្លួន ឱ្យទៅអ្នកផ្សេង

គ. បុគ្គលិកបំពេញការងារអស់ពីសមត្ថភាពខ្លួន

ឃ. អ្នកគ្រប់គ្រង ដាក់កំហិតគាបសង្កត់បុគ្គលិកខ្លួន

៤. តើយើងត្រូវធ្វើបែបណា ដើម្បីជំរុញឱ្យមានស្មារតីទទួលខុសត្រូវចំពោះការងារ?

ក. មិនត្រូវយកចិត្តទុកដាក់ចំពោះការងារពេកទេ

ខ. ត្រូវធ្វើការងារតាមថ្នាក់ដឹកនាំបញ្ជាប៉ុណ្ណោះ

គ. មិនត្រូវខ្វល់ខ្វាយពីលទ្ធផលការងារនោះទេ

ឃ. ត្រូវបណ្តុះស្មារតីឱ្យស្រឡាញ់មនសិការវិជ្ជាជីវៈ

៥. តើហេតុអ្វីបានជាអ្នកគ្រប់គ្រងផ្តល់ឱកាសឱ្យបុគ្គលិកវ័យក្មេង មានបទពិសោធតិចទៅគ្រប់គ្រងការងារធំ?

ក. ព្រោះលោកយល់ថាលោកមានជំនឿចិត្តថាការងារអាចសម្រេចបានមិនអាស្រ័យលើអាយុនោះទេ

ខ. ព្រោះលោកជាឪពុកធំបុគ្គលិកនោះ ហេតុនេះចង់ឱ្យបុគ្គលិកវ័យក្មេងនោះបានឡើងឋានៈធំ

គ. ព្រោះលោកបានចាប់ចិត្តស្រឡាញ់បុគ្គលិកវ័យក្មេងនោះតាំងពីថ្ងៃនាងចូលធ្វើការងារដំបូង

ឃ. ព្រោះលោកចង់ចាប់កំហុសបុគ្គលិកនោះ និងរកឱកាសបណ្តេញនាងចេញពីការងារ

៦. នៅពេលដែលអ្នកគ្រប់គ្រងប្រគល់ការងារទៅឱ្យបុគ្គលិកវ័យក្មេងធ្វើ តើនាងមានប្រតិកម្មបែបណា?

ក. បុគ្គលិកនោះសប្បាយចិត្តជាខ្លាំង ព្រោះនាងចង់ធ្វើការងារនោះជាយូរមកហើយ

ខ. បុគ្គលិកនោះមានចិត្តរារែក ព្រោះនាងគិតថាមានបទពិសោធតិច និងមានវ័យក្មេងពេក

គ. បុគ្គលិកនោះខឹងជាខ្លាំង ព្រោះនាងដឹងថាអ្នកគ្រប់គ្រងមានបំណងធ្វើបាបនាង

ឃ. បុគ្គលិកនោះភ័យខ្លាច ព្រោះនាងមិនយល់ពីគោលបំណងរបស់អ្នកគ្រប់គ្រង

៧. តើអ្នកគ្រប់គ្រងប្រគល់ការងារអ្វីទៅឱ្យបុគ្គលិកវ័យក្មេងធ្វើ?

ក. អ្នកគ្រប់គ្រងឱ្យបុគ្គលិកវ័យក្មេងធ្វើជាអ្នកទទួលខុសត្រូវបើកសាខាក្រុមហ៊ុន

ខ. អ្នកគ្រប់គ្រងឱ្យបុគ្គលិកវ័យក្មេងធ្វើជាអ្នកទទួលខុសត្រូវបើកសាខាក្រុមហ៊ុន

គ. អ្នកគ្រប់គ្រងឱ្យបុគ្គលិកវ័យក្មេងធ្វើជាអ្នកទទួលខុសត្រូវបើកសាខាក្រុមហ៊ុន

ឃ. អ្នកគ្រប់គ្រងឱ្យបុគ្គលិកវ័យក្មេងធ្វើជាអ្នកទទួលខុសត្រូវបើកសាខាក្រុមហ៊ុន

៨. តើអ្នកគ្រប់គ្រងធ្វើបែបណា ទើបបុគ្គលិកវ័យក្មេងយល់ព្រមទទួលធ្វើការងារនោះ?

ក. អ្នកគ្រប់គ្រងបានសន្យាថានឹងផ្តល់ប្រាក់រង្វាន់ជាច្រើន បន្ថែមលើប្រាក់ខែឱ្យទៅបុគ្គលិកវ័យក្មេងនោះ នៅពេលការងារបានសម្រេច។

ខ. អ្នកគ្រប់គ្រងបានលើកទឹកចិត្ត និងពន្យល់បុគ្គលិកថាភាពជោគជ័យមិនស្ថិតនៅលើអាយុនោះទេ

គ. អ្នកគ្រប់គ្រងបានគម្រាមបុគ្គលិកថា នឹងបណ្តេញនាងចេញពីការងារប្រសិននាងមិនយល់ព្រមទទួលការងារនោះ។

ឃ. អ្នកគ្រប់គ្រងបានអង្វរនាងឱ្យធ្វើការងារនេះ ពីព្រោះក្រៅពីនាងគាត់មិនទុកចិត្តអ្នកណាទៀតថាអាចធ្វើការងារនេះបានឡើយ។

៥. តើអត្ថបទនេះផ្តល់តម្លៃអប់រំយ៉ាងណា?

ក. ត្រូវគោរពការសម្រេចចិត្តរបស់អ្នកដទៃ

ខ. មិនត្រូវទុកចិត្តមនុស្សនៅក្បែរខ្លួនពេកទេ

គ. ការទទួលខុសត្រូវលើការងារ នាំឱ្យទទួលបានជោគជ័យ

ឃ. ការសម្រេចចិត្តឱ្យបានលឿន នាំឱ្យទទួលបានជោគជ័យ

ខ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. បដិវត្ត	ក. (ន.) សេចក្តីជាក់លាក់ ការយល់ឃើញសឹប់ ការប្រមូលគំនិតសំខាន់ៗ។	១→.....
២. សោមនស្ស	ខ. (ន.) ទីដែលជាឬសគល់ ស្ថានដើម គោលការណ៍សំខាន់។	២→.....
៣. សន្និដ្ឋាន	គ. (ន.) ប្រែប្រួល កែប្រែ ផ្លាស់ប្តូរ។	៣→.....

៤. ឧបសគ្គ	ឃ. (ន.) សេចក្តីសប្បាយចិត្ត សេចក្តីរីករាយ សប្បាយ អំណរ។	៤→.....
៥. មូលដ្ឋាន	ង. (ន.) ជាតិកំណើតដែលមានតម្លៃ ដែលមានសារៈសំខាន់ មានប្រយោជន៍។	៥→.....
	ច. (ន.) ដំណើររារាំង គ្រឿងរារាំងដំណើរ គ្រឿងទើសទាក់។	

គ.សំណួរត្រិះរិះ

១. តើអ្នកយល់ថា ការមានទំនួលខុសត្រូវលើការងារមានអត្ថប្រយោជន៍ដែរឬទេ? ចូរអ្នកលើកហេតុផលមកបង្ហាញ។

.....

.....

.....

.....

.....

.....

.....

២. ក្នុងនាមជាអ្នកដឹកនាំ តើអ្នកត្រូវធ្វើយ៉ាងណាខ្លះដើម្បីជួយឱ្យបុគ្គលិកក្រោមបង្គាប់អភិវឌ្ឍខ្លួន?

.....

.....

.....

.....

.....

.....

.....

១ ការស្តាប់៖ រឿងថាដូ និងភ្លើងឆេះស្រូវ

នៅលើភ្នំប្រទេសជប៉ុន គេសង្កេតឃើញមានផ្ទះដ៏តូចមួយសង់ប្របនឹងចង្កេះភ្នំ។ ក្នុងផ្ទះនោះ មានសមាជិកពីរនាក់រស់នៅគឺ ថាដូ និងជីតារបស់វា។ នៅតាមល្បាក់ភ្នំជុំវិញ ផ្ទះរបស់ថាដូ មានស្រែជាច្រើនកន្លែង ដែលអ្នកភូមិតែងនាំគ្នាធ្វើជារៀងរាល់ឆ្នាំ ហើយ ជីតានិងចៅរមែងចូលរួមជួយដល់ក្រុមកសិករទាំងនោះ មិននឿយណាយឡើយ។ មកដល់ពេលនេះ ថាដូ មានអាយុប្រមាណជាប្រាំឆ្នាំប៉ុណ្ណោះ។ ប៉ុន្តែវាមាន សមត្ថភាពខ្ពស់ក្នុងការពិចារណាទៅលើអត្ថប្រយោជន៍នៃដំណាំស្រូវ សម្រាប់អាយុជីវិត របស់ប្រជាជនជប៉ុន។ ស្របជាមួយនេះ លោកតាបានក្រើនរំឭកជារឿយៗដល់ថាដូ៖ "ស្រូវជាអាហារ ដ៏ចាំបាច់បំផុតសម្រាប់យើងទាំងអស់គ្នា បើសិនជាមានរឿងអ្វីមួយកើត ឡើងចំពោះវា យើងប្រាកដជាដាច់ពោះស្លាប់ជាមិនខាន ពីព្រោះយើងគ្មានអ្វីបរិភោគទេ"។ ថាដូមិនចង់ដាច់ពោះស្លាប់ទេ។ ហេតុនេះហើយបានជាវាត្រេកអរណាស់នៅពេលឃើញ ស្រូវចាប់ផ្តើមទុំ និងឃើញរដូវចម្រូតខិតជិតចូលមកដល់។

ថ្ងៃមួយ នាពេលរសៀលបន្តិច មានហេតុការណ៍មួយកើតឡើង គួរឱ្យតក់ស្លុត។ដំបូងគេឃើញជីតាថាដូឈរខាងក្រោយស្រែងភ្នែកទាំងគូរបស់លោកតាបាញ់ឆ្ពោះ - ទៅសមុទ្រស្រាប់តែទឹកមុខលោកតាឡើងស្លេកស្លាំង។ ជាបន្ទាន់នោះ គាត់ស្រែកយ៉ាង ។ ភ្លាត់សំឡេងទៅកាន់ថាដូ៖ " ចៅឯងរត់ឱ្យលឿន ទៅយកមែក ឈើដែលកំពុងឆេះនោះ មកឱ្យតា! ឆាប់ឡើង! "។ ឮដូច្នោះ ថាដូក៏ប្រញាប់ប្រញាល់រត់សំដៅភ្នក់ភ្លើង ហើយក៏ កាន់មែកឈើមួយមែក ដែលមានរងើកក្រហមច្រាលមកឱ្យជីតាវា។ ភ្លាមនោះ លោកតាក៏ បោះមែកឈើនោះចូលទៅក្នុងស ធ្វើឱ្យស្រូវឆេះឡើងមួយរំពេច។ គាត់បានបញ្ជាថាដូ ឱ្យធ្វើកិច្ចការដដែលនេះទៀត ថាដូនឹកឆ្ងល់នឹងទង្វើរបស់លោកតាយ៉ាងខ្លាំង បោះ ជំហានស្ទើរមិនរួច។ វាយំរួចសួរបញ្ជាក់៖ " លោកតា ! លោកតាកំពុងដុតស្រូវហើយ ណា ! "។ លោកតាគ្រាន់តែងក់ក្បាលតែគ្មានចាប់អារម្មណ៍ចំពោះសម្តីថាដូឡើយ ហើយ នៅតែប្រើថាដូឱ្យដុតស្រូវនៅគ្រប់ជ្រុងស្រែទៅទៀត។

គ្រានោះ ផ្ទៃស្រែដែលធ្លាប់តែឃើញស្រូវក្រហម ក៏ប្រែជាមានពណ៌ខ្មៅគ្រប ដណ្តប់ដោយផ្សែងខ្មួលខ្មាញ់អណ្តែតទៅលើអាកាស។ ទិដ្ឋភាពនេះបានធ្វើឱ្យអ្នកភូមិទាំង ចាស់ទាំងក្មេង នាំគ្នារត់ឡើងមកលើភ្នំ ដើម្បីពន្លត់អគ្គីភ័យជួយស្រោចស្រង់ដល់វត្ថុដ៏មានតម្លៃ

សម្រាប់ទ្រទ្រង់អាយុជីវិតរបស់ពួកគេ។ គ្រាន់តែឡើងមកដល់ស្រែភ្លាម បុរស ម្នាក់មានមាឌមាំ បានសួរទាំងកំហឹងទៅកាន់លោកតារបស់ថាដូ ៖ " ហេតុអ្វីបានជាមាន រឿងនេះកើតឡើង ? តើអ្នកណាជាអ្នកប្រព្រឹត្ត ប្រាប់មក?"។ លោកតាបានឆ្លើយមួយៗ ទៅកាន់បុរសនោះ៖ « ខ្ញុំជាអ្នកប្រព្រឹត្ត"។ បុរសមាឌមាំសួរបន្តទៀត៖ "ហេតុអ្វី? ហេតុអ្វី ?» ។ លោកតាបានចង្អុលទៅសមុទ្រ។ អ្នកស្រុកមើលតាមដៃគាត់ ឃើញរលក ដ៏ធំសម្បើមមួយកំពុងបោះពួយយ៉ាងលឿនស្លេវ សំដៅមករកភូមិអ្នកស្រុក។ ពួកគេឈរទ្រឹងគ្មានកម្រើក ឬ និយាយស្តីអ្វីឡើយ។ ទឹកបានរត់រំលងភូមិនោះ បោកផ្ទប់ចង្កេះភ្នំលាក់យ៉ាងខ្លាំង។ ប្រជាជនមានទឹកមុខតក់ស្លុត និងព្រួយកង្វល់ព្រោះឃើញភូមិរបស់ខ្លួនទាំងមូលនៅក្រោមទឹក។ ទីបំផុតទើបពួកគេយល់ពីមូលហេតុ ដែលនាំឱ្យលោកតាសម្រេចចិត្តដុតស្រូវ។

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើថាដូ និងជីតារស់នៅឯណា?

ក. ជ្រលងភ្នំ នៃប្រទេសជប៉ុន ឃ. នៅក្នុងភូមិមួយជាយក្រុង នៅក្នុងប្រទេសជប៉ុន

គ. នៅលើកំពូលភ្នំមួយ នៃប្រទេសជប៉ុន ខ. នៅទីប្រជុំជនធំមួយក្នុងប្រទេសជប៉ុន

២. តាមរយៈអត្ថបទរឿង តើប្រជាជនជប៉ុនឱ្យតម្លៃទៅលើអ្វី?

ក. ឱ្យតម្លៃលើដំណាំស្រូវ ខ. ឱ្យតម្លៃលើចំណេះដឹង

គ. ឱ្យតម្លៃទៅលើសន្តិភាព ឃ. ឱ្យតម្លៃទៅលើ

៣. តើហេតុអ្វីបានជាជីតាថាដូសម្រេចចិត្តដុតស្រូវ?

៤. តើថាដូមានអាកប្បកិរិយាបែបណា នៅពេលជីតាថាដូឱ្យយកភ្លើងដុតស្រូវ?

ខ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. ប្រប	ក. (ន.) អង្គត់ ឬឧសធ្យូង ដែលឆេះកាត់រង្គំ ឥតអណ្តាតរងឹកភ្លើង។	១→.....

២. ខ្ពស់ខ្មាញ់	ខ. (គុ.) ដែលរត់លឿន ត្រង់ខ្ពស់ ឬឆ្ងាយស្រឡេះ។	២→.....
៣. ទ្រឹង	គ. (និ.) ទៀប ជិត ក្បែរ។	៣→.....
៤. លឿនស្លេវ	ឃ. (គុ.) ដែលខ្មៅចូលធ្លុងគ្នា។	៤→.....
៥. រងើក	ង. (កិ.) ឈប់ស្ងៀម ដំអក់ ក្រាញដោយរឹងត្អឹង។	៥→.....
	ច. (កិ.វិ.) កុះករ តាន់តាប់ ជុំជិត កុញ ត្រៀបត្រា។	

ឃ.សំណួរត្រិះរិះ

១. តើអ្នកយល់ថា ការសម្រេចចិត្តរបស់ជីតាថាដូត្រឹមត្រូវឬទេ? ព្រោះអ្វី?

.....

.....

.....

.....

.....

២. តាមរយៈសកម្មភាពជីតាថាដូ បានបង្ហាញពីចំណុចវិជ្ជមានយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✿✿ មេរៀនទី៨៖ ការប្រឺជាក់ ✿✿

🕯 បំណិន៖ បម្រើបម្រាស់ភាសាក្នុងរឿងល្ខោនបាសាក់

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើគេអាចដឹងពីប្រវត្តិនិងដើមកំណើតសម្រាប់សម្គាល់ល្ខោនខ្មែរតាមរយៈអ្វី?

ក. តាមរយៈការសម្តែងតាមរោងមហោស្រប

ខ. តាមរយៈការចារជាក្បាច់ចម្លាក់លោតតាមជញ្ជាំងប្រាសាទ

គ. តាមរយៈការចងក្រងជាឯកសារ សៀវភៅផ្សេងៗ

ឃ. តាមរយៈពាក្យតំណាលតៗគ្នា

២. តើទ្រង់ទ្រាយនៃសិល្បៈត្រូវបានបង្កើតឡើងនៅសម័យណា?

ក. សម័យមុនអង្គរ ខ. សម័យអង្គរ

គ. សម័យក្រោយអង្គរ ឃ. សម័យអាណានិគមនិយមបារាំង

៣. តើល្ខោនបានចាប់ផ្តើមនៅសម័យណា?

ក. សម័យមុនអង្គរ ខ. សម័យអង្គរ

គ. សម័យក្រោយអង្គរ ឃ. សម័យអាណានិគមនិយមបារាំង

៤. តើប្រភេទនៃល្ខោនត្រូវបានសម្គាល់ទៅលើអ្វី?

ក. តួសម្តែងនិងឆាក ខ. ពិធីនិងពេលវេលាសម្តែង

គ. សាច់រឿងនិងឈុតឆាក ឃ. ភ្លេងនិងអត្ថបទភ្លេង

៥. តើល្ខោនមួយប្រភេទណាដែលបានយកឈ្មោះតាមទីកំណើតរបស់ខ្លួន?

ក. ល្ខោនមហោរី ខ. ល្ខោនគែន

គ. ល្ខោនបាសាក់ ឃ. ល្ខោនខោល

៦. នៅក្នុងល្ខោនបាសាក់តើគេប្រើភាសាអ្វី?

ក. ភាសាសង្ឃស័ព្ទតែមួយគត់ ខ. ភាសារាជស័ព្ទតែមួយគត់

គ. ភាសាសាមញ្ញតែមួយគត់ ឃ. ភាសាមានលក្ខណៈចម្រុះ

៧. តើពាក្យខាងក្រោមនេះ ពាក្យមួយណាជាពាក្យស្តេច(រាជសព្ទ)?

ក. អញ្ជើញ ខ. ស្វាគមន៍

គ. ព្រះទៃន ឃ. ប៉ាក់ឌិន

៨. តើរឿងខាងក្រោមនេះ តើមួយណាជារឿងបែបល្ខោនបាសាក់?

ក. រឿងតេជោយ៉ត ខ. រឿងមាលាដួងចិត្ត

ខ. រឿងកុលាបប៉ៃលិន គ. រឿងផ្កាស្រពោន

ខ. ចូរស្រង់ពាក្យក្នុងអត្ថបទដកស្រង់ខាងក្រោមដាក់ទៅតាមក្រុមពាក្យ

ស្តេចសម្រែ ៖ អ៉ា! ជំទាវស្រែន! ជំទាវស្រែនលែងប្តី! យី ! ជំទាវស្រែនស្អាតណាស់ ។ ឱ ! យើងចង់បានណាស់ ។ (ច្រៀង) ឮឈ្មោះនាង ស្រែន ចាប់ផ្តើម ស្នេហា ចង់បានកនិដ្ឋារូមរក្សមេត្រី ។ អស់អញជាស្តេចត្រូវមានមហេសី (២ដង) រូបស្អាតប្រិមប្រិយដូចទេពកញ្ញា ។ អ៉ា! បើតាមស្តាប់តាមការរៀបរាប់របស់ពួកអាមាត្យ ជំទាវស្រែនប្រាកដជាមានទឹកចិត្តមកលើយើងមិនខាន ហាស! ហាស! ហាស! ។

ឧកញ៉ាពិភា ៖ សូមក្រាបថ្វាយបង្គំព្រះករុណា (ឧកញ៉ាពិភាចូលដល់) ។

ស្តេចសម្រែ ៖ អើ !

ឧកញ៉ាពិភា ៖ តើព្រះអង្គទ្រង់ត្រាស់ហៅទូលបង្គំចូលគាល់នេះ មានកិច្ចការអ្វីទៅក្រាបទូល ?

ស្តេចសម្រែ ៖ អើ ! មានការមួយយ៉ាងសំខាន់ណាស់ លោកឧកញ៉ាពិភា ។

ឧកញ៉ាពិភា ៖ ព្រះករុណាថ្លៃវិសេស ។

ស្តេចសម្រែ ៖ មហាតលិករបស់យើងបានមកទូលថា ជំទាវស្រែនបានឈ្លោះទាស់ទែងនឹងតេជោមាសជាស្វាមីរហូតលះលែងគ្នាហើយចែកទ្រព្យសម្បត្តិគ្នារៀងខ្លួន។ ហាស ! ហាស ! ហា ! ឥឡូវនេះនារីស្រែនមកបើកផ្ទះលក់ត្រីងៀតនិងផ្ទះលក់គ្រឿងអាវុធនៅនឹងទីផ្សារកំពង់ហៅមែនទេ ?

ឧកញ៉ាពិភា ៖ ករុណាថ្លៃវិសេស រឿងពិតដូចជាបន្ទូលព្រះអង្គមែនក្រាបទូល ។

- ពាក្យស្តេច(រាជសព្ទ)៖.....
  .....
  .....។
- ពាក្យឧទាន៖.....
  .....
  .....។
- ពាក្យសាមញ្ញ៖.....
  .....។
- ភាសាបដិរូប(បដិរូបនៃភាសា)៖ .....
  .....
  .....។

គ. ចូរគូសផ្គូរផ្តេចផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. រាជសព្ទ	ក. សម្រាប់មន្ត្រី សេដ្ឋី...	១. →
២. សង្ឃសព្ទ	ខ. សម្រាប់ប្រជាជនធម្មតា	២. →
៣. ពាក្យសាមញ្ញ	គ. សម្រាប់ព្រះសង្ឃ	៣. →
៤. ពាក្យហៅតាមឋានៈ	ឃ. សម្រាប់គ្រូអាចារ្យ	៤. →
	ង. សម្រាប់វណ្ណៈក្សត្រិយ៍	

ឃ.សំណួរត្រិះរិះ

១. តើល្ខោនមានភាពល្បីល្បាញតាមរយៈអ្វី?

.....

.....

២. តើល្ខោនបាសាក់មានកំណើតនៅឯណា?

.....

.....

៣. តើភាសាក្នុងអត្ថបទល្ខោនបាសាក់មានលក្ខណៈដូចម្តេចខ្លះ?

.....

.....

៤. តើពាក្យពេចន៍ដែលបានប្រើក្នុងល្ខោនបាសាក់មានលក្ខណៈដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

🕮 អំណានៈ រឿង តេជោយ៉ុត

លំហាត់

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងតេជោយ៉ុតនិពន្ធដោយអ្នកណា?

ក. លោកឧកញ៉ាសន្ធរវោហារម៉ុក ខ. លោក ទី ជីហួត

គ. លោកញ៉ុក ថែម គ. លោកនូ ហាច

២. តើរឿងតេជោយ៉ុតនិពន្ធនៅឆ្នាំណា?

ក. ឆ្នាំ១៩៦៣ ខ. ឆ្នាំ១៩៧៣

គ. ឆ្នាំ ១៩៨៣ ឃ. ឆ្នាំ ១៩៩៣

៣. តើតួអង្គតេជោមាស ត្រូវជាអ្វីនឹងតេជោយ៉ុត?

ក. តេជោមាសត្រូវជាឪពុកមារបស់តេជោយ៉ុត

ខ. តេជោមាសត្រូវជាគ្រូរបស់តេជោយ៉ុត

គ. តេជោមាសត្រូវជាឪពុកបង្កើតរបស់តេជោយ៉ុត

ឃ. តេជោមាសត្រូវជាសត្រូវរបស់តេជោយ៉ុត

៤. តើហេតុអ្វីបានតេជោមាសត្រូវរបួស?

ក. ដោយសារតេជោយ៉ុតចាក់មួយលំពែង

ខ. ដោយសារធ្លាក់ពីលើខ្នងសេះពេលប្រយុទ្ធ

គ. ដោយសារកងទ័ពស្តេចសម្រែចាក់មួយដាវ

ឃ. ដោយសារស្តេចសម្រែដាល់មួយដៃចំដើមទ្រូង

៥. តើតេជោមាសឱ្យគេហៅភរិយា និងមន្ត្រីទាំងអស់មកជុំគ្នាក្នុងគោលបំណងអ្វី?

ក. ប្រាប់ពីស្ថានភាពជម្ងឺរបស់ខ្លួន

ខ. ប្រាប់ពីបណ្តាំមរតកចុងក្រោយ

គ. ប្រាប់ពីវិធីសាស្ត្រយកឈ្នះស្តេចសម្រែ

ឃ. ប្រាប់ពីល្បិចកលរបស់ជំទាវស្រែន

៦. តាមរយៈអត្ថបទ តើជំទាវស្រែនត្រូវជាអ្វីនឹងតេជោមាស?

ក. ជាប្រពន្ធរបស់សត្រូវ ខ. ជាភរិយា

គ. ជាកូនប្រសារ ឃ. ជាកូនបង្កើត

៧. តាមរយៈអត្ថបទ តើតួអង្គតេជោមាសជាមនុស្សបែបណា?

ក. ជាមនុស្សទន់ខ្សោយ ខ. ជាមនុស្សលូងខ្លៅ

គ. ជាមនុស្សស្នេហាជាតិទឹកដី ឃ. ជាមនុស្សក្បត់ជាតិ

៨. តាមរយៈអត្ថបទ តើតួអង្គតេជោយ៉តជាមនុស្សបែបណា?

ក. ជាមនុស្សលោភលន់នឹងទ្រព្យសម្បត្តិ ខ. ជាមនុស្សលោភលន់នឹងអំណាច

គ. ជាមនុស្សក្បត់ជាតិ ឃ. ជាមនុស្សស្មោះត្រង់ចំពោះជាតិ

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ក្តីសច្ចឹម ទាំងពួង គុណវិជ្ជា ឧបការគុណ សប្បុរសធម៌ ពូជសាសន៍

លោកគ្រូ ! រាល់ទិវារាត្រី ខ្ញុំនឹកមិនភ្លេចទេចំពោះ..... របស់លោកគ្រូ ដែលមានចំពោះខ្ញុំ ។ យ៉ត ខ្ញុំនេះជាកូនជនជាតិភាគតិចកំព្រាឪពុកម្តាយ ដើរសាត់ត្រាត់សែងត្រែងត្រូវអ្នកផង..... គេមើលងាយមើលថោក ហៅថា អាកូនព្នង ។ គេបណ្តេញមិនឱ្យចូលជិតគេ។ ខ្ញុំឈឺចាប់ណាស់ចំពោះការបែងចែកវណ្ណៈនិងប្រកាន់ ..... នេះ ។ ទើបតែពេលបានជួបលោកគ្រូទេ ដែលការឈឺចាប់ទាំងប៉ុន្មាន

បានត្រូវជំនួសវិញដោយ..... យ៉ាងរីករាយ។ លោកគ្រូមិនត្រឹមតែបីបាច់ថែរក្សាយ៉ាងសមរម្យប៉ុណ្ណោះទេ ថែមទាំងបង្ហាត់បង្រៀន..... និងអក្សរសាស្ត្រខ្ញុំ រហូតខ្ញុំកសាងខ្លួនបានប៉ុណ្ណេះ គឺលោកជាគ្រូមាន..... មិនប្រកាន់វណ្ណៈ ... ។

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ
១. ស្តេច	ក. បណ្តាសក្តិសម្រាប់ស្ត្រីជាភរិយាសេនាបតី	១. →
២. តេជោ	ខ. ហាន:កំពូលក្នុងចំណោមមនុស្សទាំងអស់	២. →
៣. ជំទាវ	គ. ហាន:មួយដែលគេគោរពបូជា	៣. →
៤. ឧកញ៉ា	ឃ. ហានន្តរសក្តិនៃមន្ត្រីជាន់ខ្ពស់	៤. →
	ង. គោរមងារតំណាងអ្នកមានអំណាច	

ឃ.សំណួរត្រិះរិះ

១. តើអត្ថបទនេះដកស្រង់ពីរឿងអ្វី? អ្នកនិពន្ធឈ្មោះអ្វី? និពន្ធឡើងនៅថ្ងៃខែឆ្នាំណា?

.....

.....

.....

២. តើចំណុចត្រង់ណានៅក្នុងអត្ថបទ ដែលបង្ហាញឱ្យឃើញពីការជឿជាក់?

.....

.....

.....

.....

៣. ហេតុអ្វីបានជាតេជោមាសធ្វើចុតហ្មាយដើម្បីថ្វាយទៅព្រះជ័យចេស្តា?

.....

.....

.....

.....

៤. តើតេជោយ៉ាតបានប្តេជ្ញាចិត្តដូចម្តេចខ្លះចំពោះភារកិច្ចរបស់ខ្លួន?

.....

.....

.....

.....

.....

.....

៥. តើរឿងតេជោយ៉ាត ផ្តល់តម្លៃអប់រំដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

⊶ វេយ្យាករណ៍៖ ជំនួយកិរិយា និងកិរិយាសព្ទជំនួយ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. ដូចម្តេចដែលហៅថាជំនួយកិរិយាសព្ទ?

ក. ជាពាក្យសម្រាប់បង្ក្រប់ន័យសេចក្តីរបស់កិរិយាសព្ទបង្គោលណាមួយក្នុងល្បះ

ខ. ជាពាក្យប្រើបញ្ជាក់និងបំពេញន័យសេចក្តីឬលក្ខណៈឱ្យប្រធាន

គ. ជាពាក្យប្រើបញ្ជាក់និងបំពេញន័យសេចក្តីឬលក្ខណៈឱ្យសព្វនាម

ឃ. ជាពាក្យប្រើបញ្ជាក់និងបំពេញន័យសេចក្តីឬលក្ខណៈ ឱ្យនាម

២. តើជំនួយកិរិយាចែកជាប៉ុន្មានប្រភេទ?

ក. ២ប្រភេទ ខ. ៣ប្រភេទ

គ. ៤ប្រភេទ ឃ. ៥ប្រភេទ

៣. តើគេប្រើកិរិយាបំពេញដើម្បីអ្វី?

ក. ដើម្បីបំពេញន័យឱ្យប្រធាន

ខ. ដើម្បីបំពេញន័យឱ្យគុណកិរិយា

គ. ដើម្បីប្រាប់ពីលទ្ធផលនៃអំពើ

ឃ. ដើម្បីប្រាប់ពីការគ្រោងទុកមុន

៤. តើគេប្រើកិរិយាសព្ទទិសដៅដើម្បីអ្វី?

ក. ដើម្បីប្រាប់ពីទិសដៅរបស់នាម

ខ. ដើម្បីប្រាប់ពីទិសដៅនៃអំពើ

គ. ដើម្បីប្រាប់ពីទិសដៅរបស់ប្រធាន

ឃ. ដើម្បីប្រាប់ពីកាលអាកាស

៥. តើគេប្រើពាក្យដើមកិរិយាដើម្បីអ្វី?

ក. សម្រាប់សំដែងពីលក្ខណៈរបស់ប្រធាន

ខ. សម្រាប់ភ្ជាប់ពាក្យមួយទៅមួយទៀត

គ. ជាពាក្យប្រាប់ចង្អុលបង្ហាញទីតាំងណាមួយ

ឃ. សម្រាប់សំដែងពីលក្ខណៈរបស់កិរិយាបង្គោល

៦.តើល្បះខាងក្រោមនេះមួយណាជាកិរិយាសព្ទបំពេញ?

ក. ខ្ញុំទើបនឹងមកពីផ្ទះ។

ខ. ប្រទេសជាតិរបស់ខ្ញុំបច្ចុប្បន្នកាន់តែអភិវឌ្ឍទៅមុខ។

គ. កុមារាម្នាក់នេះរត់ដួលរហូត។

ឃ. ក្មេងៗដាក់សៀវភៅចូលទូរសៀវភៅ។

៧. តើល្បះខាងក្រោមនេះមួយណាជាកិរិយាសព្ទទិសដៅ?

ក. ភូមិកំណើតខ្ញុំមានផ្លូវលំខ្វាត់ខ្វែង។

ខ. កង្កែបលោតចូលទៅក្នុងទឹកត្រពាំង។

គ. ព្រឹកនេះខ្ញុំត្រូវធ្វើតេស្តប្រចាំខែ។

ឃ. យប់មិញខ្ញុំគេងមិនលក់សោះ។

៨. តើល្បះខាងក្រោមនេះមួយណាជាពាក្យដើមកិរិយា?

ក. ពួកយើងទើបតែប្រឡងបាក់ឌុបរួច។

ខ. សត្វស្វាវត់ឡើងដើមឈើលឿនណាស់។

គ. ធីតាអានសៀវភៅរាល់យប់។

ឃ. សិស្សានុសិស្សដើរទៅសាលារៀន។

ខ. ចូរបង្ហាញពាក្យដែលជាជំនួយកិរិយានៅក្នុងឃ្លុះខាងក្រោម

១. វាសនាអានសៀវភៅនេះចប់ហើយ។

ពាក្យ.....ជាជំនួយកិរិយា

២. ពិសីបើកទ្វារជូនលោកយាយ។

ពាក្យ.....ជាជំនួយកិរិយា

៣. គាត់បើកឡានទៅកន្លែងធ្វើការ។

ពាក្យ.....ជាជំនួយកិរិយា

៤. ពួកយើងគួរតែប្រឹងប្រែងរៀនសូត្រ។

ពាក្យ.....ជាជំនួយកិរិយា

៥. សុខហេងរកឃើញប្អូនគាត់វិញហើយ។

ពាក្យ.....ជាជំនួយកិរិយា

៦. ស្រីពេជ្រចូលចិត្តច្រៀងណាស់។

ពាក្យ.....ជាជំនួយកិរិយា

៧. ម្តាយខ្ញុំទើបតែមកពីផ្សារ។

ពាក្យ.....ជាជំនួយកិរិយា

៨. ក្មេងៗកំពុងលេងបាល់ទាត់។

ពាក្យ.....ជាជំនួយកិរិយា

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	ផ្នែក ខ	ចម្លើយ

១. កិរិយាបំពេញ	ក. បូណាចូលចិត្តអានសៀវភៅណាស់	១. →
២. កិរិយាទិសដៅ	ខ. អ្នកគ្រូដើរយ៉ាងលឿនទៅកាន់ថ្នាក់រៀន	២. →
៣. កិរិយាខាងដើម	គ. កុសលមកសាលារៀនទាន់ពេលជានិច្ច	៣. →
៤. ពាក្យខាងដើមកិរិយា	ឃ. ក្មេងៗលោតអន្ទាក់	៤. →
	ង. លោកតាខ្ញុំកំពុងស្តាប់ធម៌	

ឃ.សំណួរត្រិះរិះ

១- ដូចម្តេចដែលហៅថាជំនួយកិរិយា?

.....

.....

.....

.....

២- តើជំនួយកិរិយាមានអ្វីខ្លះ? ចូរផ្តល់ឧទាហរណ៍តាមប្រភេទនីមួយៗ។

.....

.....

.....

.....

.....

៣. ចូរតែងល្បះឱ្យបាន៥ល្បះ ដោយប្រើជំនួយកិរិយា ។

១. .....

២. .....

៣. .....

៤. .....

៥. .....

📖 អំណាន៖ ការធ្វើដំណើរទៅបរប៉ៃលិន

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងកុលាបប៉ៃលិននិពន្ធដោយអ្នកនិពន្ធរូបណា?

ក. លោកញ៉ុក ថែម ខ. លោកនូ ហាច

គ. លោកសួន សុរិន្ទ ឃ. ភិក្ខុ ងួន សោម

២. តាមរយៈអត្ថបទ តើអ្នកណាត្រូវធ្វើដំណើរទៅបរប៉ៃលិន?

ក. លោកហ្លួងរតនសម្បត្តិ ខ. លោកគ្រូពេទ្យស្អាត

គ. ចៅចិត្រ ឃ. លោកបាឡាត់ស្រុកសង្កែ

៣. តើហេតុអ្វីបានជាចៅចិត្រត្រូវធ្វើដំណើរទៅបរប៉ៃលិន?

ក. ចៅចិត្ររត់គេចពីម្ចាស់បំណុលដែលខ្លួនបានខ្ចីប្រាក់មកព្យាបាលជំងឺឪពុក

ខ. ចៅចិត្រទៅតាមរកម្តាយនៅទីនោះ តាមការប្រាប់របស់លោកគ្រូពេទ្យស្អាត

គ. ចៅចិត្រទៅតាមរកនាងឃុននារី ព្រោះនាងនារីជាស្ត្រីដែលចៅចិត្រស្រឡាញ់

ឃ. ចៅចិត្រទៅរកការងារធ្វើ ព្រោះចៅចិត្រគ្មានទីពំនាក់ដូចមុន

៤. ហេតុអ្វីបានជាចៅចិត្រស្រក់ទឹកភ្នែកក្នុងពេលកំពុងធ្វើដំណើរទៅបរប៉ៃលិន?

ក. ព្រោះនឹកដល់ផ្ទះសំបែង ខ. ព្រោះនឹកដល់គូសង្សារដែលនៅស្រុក

គ. ព្រោះនឹកដល់ឪពុកដែលទើបស្លាប់ទៅ ឃ. ព្រោះភ័យខ្លាចក្នុងការដំណើរ

៥. តើចៅចិត្រធ្វើដំណើរទៅជួបនរណា?

ក. លោកគ្រូពេទ្យស្អាត ខ. លោកហ្លួងរតនសម្បត្តិ

គ. គូកំណាន់ចិត្ត ឃ. ក្រុមគ្រួសារ

៦. តើលោកហ្លួងរតនជានរណា?

ក. ជាឪពុករបស់ចៅចិត្រ ខ. ជាគ្រូពេទ្យ

គ. ជាចាហ្វាយស្រុក ឃ. ជាអ្នកជំនួញលក់ត្បូង

៧. តើលោកគ្រូពេទ្យស្អាតត្រូវជាអ្វីនឹងលោកហ្លួងរតនសម្បត្តិ?

ក. ត្រូវជាកូន ខ. ត្រូវជាកូនប្រសារ

គ. ត្រូវជាក្មួយ ឃ.ត្រូវជាគ្រូពេទ្យប្រចាំខ្លួន

*៨. តើនាង **នារី** ជានរណា?*

ក. ជាកូនរបស់លោកហ្លួនរតនសម្បត្តិ

ខ. ជាប្រពន្ធរបស់លោកហ្លួងរតនសម្បត្តិ

គ. ជាស្ត្រីមេផ្ទះរបស់លោកហ្លួងរតនសម្បត្តិ

ឃ. ជាប្រពន្ធរបស់ពេទ្យស្អាត

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ចៅ ចិត្រ	**ទេវតា**	**ស្រឡាញ់រាប់អាន**	**ពួកកម្មករ**	**អស់ពីចិត្តពីថ្លើម**	
លោកហ្លួងរតនសម្បត្តិ		**កម្មករ**			

[...] តាំងពីថ្ងៃនោះមក ចៅចិត្រក៏បានធ្វើជា..... ជីករកត្បូងនៅគេហដ្ឋាន របស់..... ទោះបីការនោះជាការធ្ងន់ក៏ដោយ ចៅចិត្រក៏ឥតមានការធុញ ទ្រាន់ តែងតែខំធ្វើការនោះ ដោយខ្មីឃ្មាត..... មិនមាននឹកនាដល់សេចក្តី នឿយហត់ឡើយ ។ ភាសិត១បទថា "ខ្លួនទីពឹងខ្លួន" ដែលជាពាក្យបណ្តាំរបស់បិតាចុង ក្រោយបង្អស់នោះ នៅឮសូរកងរំពងក្នុងត្រចៀករបស់..... ហាក់ដូចជាមាន ..... មកចាំឱ្យបប្រាប់នឹងត្រចៀកជានិច្ច ការខំប្រឹងធ្វើការយ៉ាងម៉ឺងម៉ាត់ឥតមាន ទម្រន់និងអធ្យាស្រ័យល្អរបស់ចៅចិត្រនោះ ជាហេតុធ្វើឱ្យ..... ធ្វើការជងគ្នា

..... ជាច្រើន រហូតដល់ហ្លួងរតនសម្បត្តិ ក៏មានចិត្តមេត្តាក្មេងនោះជាច្រើនដែរ ។

គ.សំណួរត្រិះរិះ

១. ចូរវិភាគតួអង្គ ចៅចិត្រ នាងឃុននារី និងលោកហ្លួងរតនសម្បត្តិ។

.....

.....

.....

.....

.....

២. ចូរបង្ហាញពីកាលអាកាសរបស់អត្ថបទដកស្រង់នេះ។

.....

.....

.....

.....

.....

៣. តើចំណុចត្រង់ណានៃអត្ថបទ ដែលបង្ហាញថាចៅចិត្រជាមនុស្សមានជំនឿជាក់លើខ្លួនឯង?

.....

.....

.....

.....

.....

.....

.....

.....

.....

៤. ចូរបង្ហាញតម្លៃអប់រំដែលស្តែងឡើងតាមរយៈអត្ថបទ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណានៈ ជំនឿជាក់លើខ្លួនឯង

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើ ជំនឿជាក់លើខ្លួនឯង មានន័យដូចម្តេច?

ក. ភាពកោតសរសើរចំពោះខ្លួនឯង

ខ. ការយល់ឃើញថាខ្លួនឯងតែងតែត្រូវជានិច្ច

គ. ភាពនៃសេចក្តីអង់អាចក្លាហាន

ឃ. ការជឿច្បាស់ក្នុងចិត្ត ទុកចិត្តលើខ្លួនឯង

២. តើ ជំនឿជាក់លើខ្លួនឯង កើតចេញពីអ្វី?

ក. ការចេះជួយខ្លួនឯងតាំងពីនៅក្មេង

ខ. ការចាំជួយរបស់ឪពុកម្តាយតាំងពីនៅក្មេង

គ. ការចាំជួយយកអាសារបស់មិត្តភក្តិគ្រប់ពេល

ឃ. ភាពមានទ្រព្យសម្បត្តិសុកស្តម្ភ

៣. មនុស្សដែលមានជំនឿជាក់លើខ្លួនឯងតែងមានគំនិតបែបណា?

ក. មានគំនិតអវិជ្ជមានចំពោះខ្លួនឯង

ខ. មានគំនិតវិជ្ជមានចំពោះខ្លួនឯង

គ. មានអំនួតនិងមិនស្តាប់អ្នកដទៃ

ឃ. តែងយល់ឃើញថាអ្នកដទៃតែងតែខុសជានិច្ច

៤. មនុស្សដែលគ្មានជំនឿជាក់លើខ្លួនឯងតែងតែ

ក. យកឈ្នះរាល់ការលំបាក

ខ. មិនត្រូវការជួយពីអ្នកដទៃ

គ. មានភាពមិនច្បាស់លាស់លើខ្លួនឯង ពឹងលើអ្នកដទៃ

ឃ. ទទួលបានការគោរពស្រឡាញ់

៥. ប្រទេសជាតិមួយដែលសម្បូរដោយមនុស្សមានជំនឿជាក់លើខ្លួនឯង ប្រទេសជាតិនោះនឹងក្លាយជាបែបណា?

ក. ក្លាយជាប្រទេសផ្តាច់ការ

ខ. មានការរីកចម្រើនជឿនលឿន

គ. ចុះទន់ខ្សោយ

ឃ. មានជម្លោះមិនចេះចប់

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ទម្លាប់ ខ្លួនទីពឹងខ្លួន ឧបត្ថម្ភ ជួយខ្លួនឯង ការខ្ចីកហាត់អប់រំ គុណសម្បត្តិមូលដ្ឋាន ជំនឿជាក់លើខ្លួន

មនុស្សដែលនឹងមានជំនឿជាក់លើខ្លួនឯងភាគច្រើនកើតពី..... នៅវ័យក្មេងរបស់អាណាព្យាបាលឬឪពុកម្តាយ។ ក្មេងណាដែលអាណាព្យាបាលព្យាយាមបណ្តាយឱ្យ..... តាំងពីនៅក្មេងលុះធំឡើងច្រើនតែមាន ..... ។ ផ្ទុយទៅវិញក្មេងណាដែលអាណាព្យាបាលច្រើនតែចាំជួយគ្រប់ពេលវេលា លុះគេធំឡើងក៏ច្រើនតែទន់ខ្សោយហើយរមែងរង់ចាំជំនួយពីអ្នកដទៃជារឿយៗ ។

.....ជួយខ្លួនឯងមានសារៈសំខាន់ណាស់សម្រាប់អ្នកដែលប្រាថ្នាចង់បានភាពរីកចម្រើន ឬចង់ក្លាយខ្លួនជាបុគ្គលសំខាន់ ។ មិនមានបុគ្គលសំខាន់ណាម្នាក់ខ្វះគុណសម្បត្តិប្រការនេះឡើយ ព្រោះវាជា..... ដែលចាំបាច់ត្រូវមានសូម្បីតែពុទ្ធភាសិតក៏បានពោលថា .....។

ក្នុងករណីដែលមិនទាន់អាចជួយខ្លួនឯងបាន ក៏មានក្តីសង្ឃឹមថានឹងបានទទួលជំនួយពីអ្នកដទៃដើម្បីនឹងធ្វើឱ្យយើងអាចជួយខ្លួនឯងបាននៅទីបំផុត មិនមែនរង់ចាំតែទទួលការជួយ..... ជារៀងរហូតនោះទេ ។

គ.សំណួរត្រិះរិះ

១. ដូចម្តេចដែលហៅថា ការជឿជាក់?

.....

.....

.....

.....

២. តើមនុស្សដែលមានភាពជឿជាក់លើខ្លួនឯងជាមនុស្សមានលក្ខណៈដូចម្តេច?

.....

.....

.....

.....

.....

៣.តើយើងត្រូវធ្វើដូចម្តេចខ្លះដើម្បីបណ្តុះស្មារតីនិងទម្លាប់ឱ្យមានជំនឿជាក់និងភាពទុកចិត្តបាន?

.....

.....

.....

.....

.....

.....

.....

.....

៤. តើការមានជំនឿជាក់លើខ្លួនឯង ផ្តល់ប្រយោជន៍អ្វីខ្លះសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

៥- តើអត្ថបទខាងលើនេះមានតម្លៃអប់រំដូចម្តេច?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✍ សំណេរ៖ សំណេរសង្ខេបអត្ថបទឲ្យានជាពាក្យរាយ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើ ពាក្យរាយ មានន័យដូចម្តេច?

ក. ពាក្យដែលបញ្ចូលសំឡេងតួអង្គនៅក្នុងនោះ

ខ. ពាក្យដែលមានការសន្ទនាគ្នារវាងតួអង្គក្នុងរឿង

គ. ពាក្យដែលសរសេរជាកថាខណ្ឌតាមការស្តាប់បាន

ឃ. ពាក្យដែលបានការបញ្ចូលសំឡេងភ្លេង

២. តើការសង្ខេបអត្ថបទត្រូវធ្វើដូចម្តេច?

ក. ត្រូវសរសេរពង្រីកគំនិតសំខាន់ៗ

ខ. ត្រូវលើកយកសេចក្តីលំអិតមកសង្ខេប

គ. ត្រូវសរសេរតាមអ្វីស្តាប់បានលើអត្ថបទ

ឃ. ត្រូវសរសេរសង្ខេបឱ្យចំខ្លឹមសារសំខាន់ៗនៃអត្ថបទ

៣. ហេតុអ្វីបានជាយើងត្រូវសង្ខេបអត្ថបទ?

ក. ដើម្បីកុំឱ្យពិបាកស្តាប់ឃ្លេ

ខ. ដើម្បីងាយស្រួលសម្តែង

គ. ដើម្បីងាយស្រួលចងចាំនិងយល់ពីអត្ថបទ

ឃ. ដើម្បីកុំឱ្យអត្ថបទវែងពេក

៤. តើការសង្ខេបអត្ថបទឲ្យានជាពាក្យរាយមានលក្ខណៈបែបណា?

ក. យកអត្ថបទពាក់កណ្តាលមកសរសេរ

ខ. សរសេរដោយសង្ខេបពីអត្ថបទល្ខោនដោយមិនមានលក្ខណៈជាការសម្តែង

គ. យកតែសម្តីតួអង្គឯកមកសរសេរ

ឃ. សរសេរតែចំណុចដែលចូលចិត្ត

គ.សំណួរត្រិះរិះ

១-នៅពេលសង្ខេបអត្ថបទមួយបានត្រឹមត្រូវ តើអ្នកគួរគប្បីធ្វើដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....

២-ចូរប្អូនសរសេរសង្ខេបអត្ថបទដកស្រង់រឿង តេជោយ៉ត (ឆាកទី៨)ឡើងវិញ ជាពាក្យរាយ ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✍ មេរៀនទី៩៖ សេចក្តីថ្លែថ្នូរ ✍
🕯 បំណិន៖ ទំហៀបន័យ និងមេតាផរ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើសំនួនពាក្យ គេប្រើដើម្បី?

ក. ដើម្បីភ្ជាប់ពាក្យមួយទៅពាក្យមួយទៀត

ខ. ដើម្បីបំពេញន័យក្នុងល្បះ

គ. ដើម្បីបង្ហាញន័យប្រៀបធៀបពីអង្គមួយទៅអង្គមួយទៀត

ឃ. ដើម្បីបង្ហាញពីន័យផ្ទុយគ្នានៃពាក្យ

២. តើបំហៀបន័យឬមេតាផរជាអ្វី?

ក. ជាទំហៀបន័យដោយមានចំណងធៀប

ខ. ជាទំហៀបន័យដោយគ្មានចំណងធៀប

គ. ជាទំហៀបន័យដោយមិនផ្តោតលើន័យដូច

ឃ. ជាទំហៀបន័យដោយផ្តោតលើសូរដូច

៣. តើពាក្យមួយណាជា មេតាផរ?

ក. លឿងដូចស្វាយទុំ ខ. ក្រហាមដូចឈាម

គ. ទឹករលក ឃ. នាវាជីវិត

៤. តើពាក្យមួយណាជា មេតាផរ?

ក. ចង្កាព្រៃក ខ. ដូងទេរ

គ. ដុំទឹកកក ឃ. ស្វាយក្បាលដំរី

៥. តើពាក្យមួយណាមិនមែនជា មេតាផរ?

ក. ក្បាលព្រែក ខ. សមុទ្រទុក្ខ

គ. ត្រចៀកកាំ ឃ. ជើងមេឃ

ខ. ចូរបំពេញចន្លោះខាងក្រោមដើម្បីប្រៀបធៀបដោយប្រើមេតាផរ

- ក្បូនជីវិត ៖.....

- ជញ្ជើងស្នេហា ៖.....

- សំណល់ជីវិត ៖.....

- សំបកខ្លួន ៖.....

- ទឹកលុយ ៖.....

គ. ចូរគូសផ្គូរផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. ជើងភ្នំ	ក. ចង្កាធំមានស្នាមភ្លោះឬស្នាមពីរចំណែក	១.→.....
២. មេឃស្រកានាគ	ខ. ជីវិតរសាត់គ្មានទិសដៅ	២.→.....
៣. ចង្កាព្រែក	គ. ផ្នែកខាងក្រោមនៃភ្នំ	៣.→.....
៤. ចកជីវិត	ឃ. ចង្ការបស់ព្រែកឬស្ទឹង	៤.→.....
	ង. មេឃមានដុំពពកធំៗដូចស្រកា	

ឃ.សំណួរត្រិះរិះ

ក. ចូរអ្នកអានអត្ថបទដកស្រង់ខាងក្រោមនេះដើម្បីស្វែងរកសំនួនពាក្យដែលជា មេតាផរ

[...] រទេះភ្លើងបោលលឿនដូចព្យុះ កាត់ព្រៃខ្លុងនិងព្រិច រត់ឆ្លងអូរ ហើយពុះជ្រែកជើងភ្នំ ដោយបញ្ចេញសន្ធឹកខ្ទរំពង ធ្វើឱ្យរញ្ជួយផែនពសុធា។

បើគេសម្លឹងមើលតាមបង្អួចនៃទូររថភ្លើងណាមួយគេនឹងបានឃើញកម្រាលព្រំបៃតងលាតសន្ធឹងដាច់កន្ទុយភ្នែកនារដូវវស្សា ។ [...]

បុប្ផាទាំងនេះហាក់ដូចជាឧបត្ថិកសម្រាប់ជាគ្រឿងលំអនៃសំពត់ព្រំពណ៌បៃតង ដែលលាតសន្ធឹងក្រោមមេឃស្រកានាគនិងក្រោមរស្មីថ្លាត្រចះនៃព្រះសុរិយា។

.....

.....

.....

ខ. ចូរអ្នកជ្រើសរើសសំនួនពាក្យខាងក្រោម ដែលបញ្ជាក់ថា ជា "មេតាផរ"៖

- ភ្នែកភ្នាល់ចាប់ពូក	- ត្រកួនភ្លេចបឹង	- មេឃប្រែពណ៌
- លឿងដូចមាសឆ្អិន	- ម្រាមដៃដូចបន្លាក្រូច	- សមុទ្រទឹកសាប
- អន្លង់ស្នេហ៍	- ជើងល្អ	- វិថីជីវិត
- ជើងជណ្តើរ	- ក្បាលជ្រោយ	- ខ្លាក្រដាស
- ខ្លួនបងដូចជាដំរី	- ដួងចន្ទ	-ក្បាលព្រែក

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ ភាពថ្លៃថ្នូរនៃបុគ្គល

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទកាព្យខាងលើតាក់តែងឡើងដោយកវីបណា?

ក. ព្រះភិក្ខុសោម ខ. ព្រះសង្ឃរាជ ជួន ណាត

គ. លោក នូ ហាច ឃ. ភិរម្យង៉ុយឬក្រមង៉ុយ

២. តើកវីតាក់តែង រស់នៅក្នុងសម័យកាលណា?

ក.សម័យឧដុង្គ ខ. សម័យអាណានិគមនិយមបារាំង

គ. សម័យសង្គមរាស្ត្រនិយម ឃ. សម័យសាធារណរដ្ឋខ្មែរ

៣. តើពាក្យ ភាពថ្លៃថ្នូរ សំដៅលើអ្វី?

ក. សេចក្តីលោភលន់ ខ. សេចក្តីទន់ភ្លន់

គ. សេចក្តីត្រឹមត្រូវ ឃ. សេចក្តីលាក់បាំង

៤. តើពាក្យ ពាក្យសត្យ សំដៅលើអ្វី?

ក. ពាក្យទៀងត្រង់ ខ. ពាក្យកុហក

គ. ពាក្យបញ្ចុះបញ្ចូល ឃ. ពាក្យស្បថស្បែ

៥. តើពាក្យ កត្តញ្ញូ សំដៅលើអ្វី?

ក. ការធ្វើល្អ ខ. ការដឹងគុណ

គ. ការដាក់ទាន ឃ. ការអត់ធ្មត់

៦. តើកំណាព្យខាងលើជាបទអ្វី?

ក. បទកាកគតិ ខ. បទភុជង្គលីលា

គ. បទពំនោល ឃ. បទព្រហ្មគីតិ

៧. តើកំណាព្យខាងលើគេប្រើនៅពេលណា?

ក. ប្រើសម្រាប់បញ្ចប់រឿង ខ. សម្តែងនៅភាពសប្បាយរីករាយ

គ. ពណ៌នាធម្មជាតិ ទីកន្លែង តួអង្គ ឃ. លួងលោមសុំសេចក្តីស្រឡាញ់

៨. តើឃ្លា បើក្រឱ្យមាន សំដៅដល់អ្វី?

ក. បើក្រទ្រព្យត្រូវមានជីវិត ខ. បើក្រទ្រព្យត្រូវមានគំនិតគិតគូរ

គ. បើក្រទ្រព្យត្រូវមានកម្លាំងកាយ ឃ. បើក្រទ្រព្យត្រូវមានផ្ទះសំបែង

៩. តើឃ្លា កុំដេកតែក្រ មានន័យសំដៅដល់អ្វី?

ក. កុំភ័យខ្លាចនឹងភាពក្រ ខ. កុំគេចចេញពីភាពក្រ

គ. កុំបោះបង់ភាពក្រ ឃ. កុំបណ្តោយខ្លួនតាមព្រេងវាសនា

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

កុំចាំគេប្រាប់ កុំដេកតែខ្លៅ កុំដេកតែក្រ កើតមកជាមនុស្ស បើក្រឱ្យមាន កាប់ជីកចូកចាំង រិះរកគំរាប់ រៀនអ្វីឱ្យឆ្ពិន

កុំថ្មមកម្លាំង	.....	កុំថារងាក្តៅ
.....	កុំឱ្យខ្លោចឆៅ	.....
	ក្រក្រៅសណ្តាប់ ។	
បើលួងឱ្យចេះ	រករៀនតម្រិះ	.....
ឥន្ទ្រិយឆ្វេងស្តាំ	.....	រៀនស្តីរៀនស្តាប់
	រៀនមើលឱ្យស្តែង ។	
.....	ទាំងស្រីទាំងប្រុស	មិនមែនចេះឯង

..... វិញ្ញាណចេះក្រែង គិតគ្រប់កន្លែង

.....។

គ.សំណួរត្រិះរិះ

១. តើអត្ថបទកាព្យខាងលើមានន័យដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

២. តើអត្ថបទកាព្យនេះ ក្នុងមួយឈ្នះមានប៉ុន្មានឃ្លា? មួយឃ្លាមានប៉ុន្មានព្យាង្គ? ចូរគូសគំនូសតាងចំណាប់ជូន។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

៣. តើខ្លឹមសារនៃអត្ថបទនេះ ផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

⊶ វេយ្យាករណ៍៖ នាម និងប្រភេទនាម

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. ដូចម្តេចដែលហៅថានាម?

ក. ជាពាក្យសម្រាប់សម្តែងនូវអំពើឬសកម្មភាព

ខ. ជាពាក្យសម្រាប់សម្តែងនូវសភាពឬលក្ខណៈ

គ. ជាថ្នាក់ពាក្យមួយប្រភេទសម្រាប់សម្គាល់ឬបញ្ជាក់ពីមនុស្ស សត្វ វត្ថុ ទីកន្លែង...

ឃ. ជាថ្នាក់ពាក្យសម្រាប់សម្គាល់ឬបញ្ជាក់ពីសកម្មភាពមនុស្ស សត្វ វត្ថុ ទីកន្លែង...

២. តើនាមមានប៉ុន្មានប្រភេទ?

ក. មាន២ប្រភេទ ខ. មាន៣ប្រភេទ

គ. មាន៤ប្រភេទ ឃ. មាន៥ប្រភេទ

៣. តើសាធារណនាមឬនាមសាធារណ៍សម្រាប់សម្គាល់អ្វី?

ក. សម្គាល់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែងទូទៅ មិនចំពោះ

ខ. សម្គាល់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែងប្រាកដ ចំពោះ មិនទូទៅ

គ. សម្គាល់ មនុស្ស សត្វ រុក្ខជាតិ ទីកន្លែងទូទៅ មិនចំពោះ

ឃ. សម្គាល់ពីសភាពលក្ខណៈមនុស្ស សត្វ រុក្ខជាតិ ទីកន្លែងទូទៅ មិនចំពោះ

៤. តើអសាធារណនាមឬនាមអសាធារណ៍សម្រាប់សម្គាល់អ្វី?

ក. សម្គាល់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែងទូទៅ មិនចំពោះ

ខ. សម្គាល់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែងប្រាកដ ចំពោះ មិនទូទៅ

គ. សម្គាល់ មនុស្ស សត្វ រុក្ខជាតិ ទីកន្លែងទូទៅ មិនចំពោះ

ឃ. សម្គាល់ពីសភាពលក្ខណៈមនុស្ស សត្វ រុក្ខជាតិ ទីកន្លែងទូទៅ មិនចំពោះ

៥. តើនាមករណ៍ឬករណនាមសម្រាប់សម្តែងអ្វី?

ក. ភាពមិនចំពោះ ទូទៅ ខ. ភាពទូទៅ មិនចំពោះ

គ. សភាពឬសកម្មភាព ឃ. អ្នកធ្វើអំពើឬអ្នកមានសភាពបែបណាមួយ

៦. តើនាមការក៍ឬការកនាមសម្រាប់សម្តែងអ្វី?

ក. ភាពមិនចំពោះ ទូទៅ ខ. ភាពទូទៅ មិនចំពោះ

គ. សភាពឬសកម្មភាព ឃ. អ្នកធ្វើអំពើឬអ្នកមានសភាពបែបណាមួយ

៧. តើល្អះខាងក្រោមមួយណាជាសាធារណនាម?

ក. ចៅចិត្រធ្វើដំណើរទៅបប៉ៃលិន។

ខ. សេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជាពឹងផ្អែកលើវិស័យកសិកម្ម។

គ. ធីតាអានសៀវភៅភាសាខ្មែរក្នុងបណ្ណាល័យ។

ឃ. សិស្សានុសិស្សរត់ប្រដេញគ្នានៅទីធ្លាខាងមុខសាលារៀន។

៨. តើល្អះខាងក្រោមមួយណាជាអសាធារណនាម?

ក. សុខាទៅលំហែកាយនៅខេត្តសៀមរាប។

ខ. ប្រជាកសិករប្រកបរបរធ្វើស្រែចម្ការ។

គ. សិស្សានុសិស្សអានសៀវភៅក្រោមដើមឈើ។

ឃ. លោកគ្រូអ្នកគ្រូខិតខំប្រឹងប្រែងបង្រៀនសិស្ស។

៩. តើនាមករណ៍ឬករណនាមកើតចេញពីអ្វីខ្លះ?

ក. នាមនិងកិរិយា ខ. កិរិយានិងគុណនាម

គ. នាមនិងគុណនាម ឃ. កិរិយានិងនាម

១០. តើនាមការក៍ឬការកនាមកើតចេញពីអ្វីខ្លះ?

ក. នាម-កិរិយានិងគុណនាម ខ. កិរិយា-គុណកិរិយានិងគុណនាម

គ. នាម-គុណនាមនិងគុណកិរិយា ឃ. កិរិយា-គុណកិរិយានិងនាម

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

គុណនាម	**ករណនាម**	**គុណនាម**	**ការកនាម**
សុខ	.....	ល្អ	.....
ចម្រើន	.....	អាក្រក់	.....
លំបាក	.....	កណ្តាល	.....
ថ្លៃថ្នូរ	.....	តូច	.....
កាច	.....	ខ្សោយ	.....
ខ្ពស់	.....	ក្លាហាន	.....
វែង	.....	ខ្សត់	.....
ក្រាស់	.....	ក្រ	.....

គ. ចូរគូសផ្គងឆ្លើងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

ផ្នែក ក	**ផ្នែក ខ**	**ចម្លើយ**
១. នាមសាធារណ៍	ក. ការគោរពវិន័យនាំមកនូវសេចក្តីថ្លៃថ្នូរ	១. →
២. នាមអសាធារណ៍	ខ. នៅឱ្យស្ងៀម! កុំរពឹសពេក...	២. →
៣. នាមករណ៍	គ.មករាស្រឡាញ់ប្អូនប្រុសរបស់គាត់ណាស់	៣. →
៤. នាមការក៍	ឃ. អ្នកជនបទមិនមែនសុទ្ធតែអ្នកក្រទេ	៤. →
	ង. កសិករចិញ្ចឹមមាន់ដើម្បីធ្វើជាម្ហូបអាហារ	

ឃ.សំណួរត្រិះរិះ

១- ចូរតែងល្បះឱ្យបាន៤ ដោយប្រើ :

- សាធារណនាម ចំនួន ១ ល្បះ

- អសាធារណនាម ចំនួន ១ល្បះ

- នាមករណ៍នាម ឬករណនាមចំនួន ១ឈ្មះ

- នាមការក៍ ឬការកនាម ចំនួន ១ឈ្មះ ។

.....

.....

.....

.....

.....

.....

.....

.....

.....

២- ចូរអ្នកជ្រើសរើសពាក្យខាងក្រោមនេះ ទៅតាមប្រភេទនាមនីមួយៗ:

ពូម៉ន ភ្នំពេញ ក្របី ប្រវែង ស្វា អ្នកក្រុង វាលស្រែ ស្រូវ ការអនុវត្ត ម្រេច សុភាព អ្នកក្រ ឆ្នាំ កម្មករ និយោជិត ថៅកែ សេចក្តីសុខ។

នាមសាធារណ៍	**នាមអសាធារណ៍**	**នាមករណ៍**	**នាមការក៍**
.....	.....	.....	.....
.....	.....	.....	.....
.....	.....	.....	.....
.....	.....	.....	.....

៣- ចូរអ្នកជ្រើសរើសពាក្យជាកិរិយា ជាគុណនាម និងជានាម ដើម្បីបង្កើតឱ្យទៅជាករណនាម និងការកនាម ចំនួន៤ពាក្យ ដាក់ក្នុងតារាងខាងក្រោម៖

កិរិយា	**ករណនាម**	**កិរិយា**	**ការកនាម**
....	....	....	....
គុណនាម	**ករណនាម**	**គុណនាម**	**ការកនាម**
....	....	....	....
នាម	**ករណនាម**	**នាម**	**ការកនាម**
....	....	....	....

🕮 អំណាន៖ ឧត្តមភាពបុគ្គល

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទកាព្យនេះតែងជាបទអ្វី?

ក. បទកាកគតិ ខ. បទភុជង្គលីលា

គ. បទពំនោល ឃ. បទព្រហ្មគីតិ

២. តើអត្ថបទកាព្យខាងលើដកស្រង់ចេញពីសៀវភៅណា?

ក.ក្រមង៉ុយ ខ. ច្បាប់ទូន្មានខ្លួន

គ.ល្បីកអង្គរវត្ត ឃ. ច្បាប់ស្រីអង្គខ្ងង

៣. តើ សេចក្តីថ្លៃថ្នូរ សំដៅដល់អ្វី?

ក. ការប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ ខ. ការមានទ្រព្យសម្បត្តិច្រើន

គ. ការមានយសសក្តិអំណាច ឃ. ការប្រព្រឹត្តអំពើល្មើសច្បាប់

៤. តើ ឧត្តមភាព សំដៅលើអ្វី?

ក. ភាពទន់ខ្សោយ ខ. ភាពរឹងមាំ

គ. ភាពថ្កុំថ្កើងរុងរឿង ឃ. ភាពផ្តាច់ការ

៥. តើបទព្រហ្មគីតិ មួយវគ្គមានប៉ុន្មានឃ្លា?

ក. មាន៣ឃ្លា ខ. មាន៤ឃ្លា

គ. មាន៥ឃ្លា ឃ. មាន៦ឃ្លា

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ខ្សត់គ្មានឃ្លានស៊ូស្លាប់ មានទ្រព្យធនត្បិតទានគេ ខ្លួនខ្សត់ខ្សោយឱ្យបារម្ភ ពាក្យនេះជាឧត្តម គេឱ្យហៅកុំអាលមក

[...]១. គេប្រើកុំអាលទៅ .....

គេឱ្យកុំអាលយក គេសង្ឃកកុំអាលថយ ។

២. ខ្លួនតូចកុំខំពារ ខ្លួនអ្នកជាកុំគិតធ្លោយ

ឱ្យគិតក្រែងក្រក្រោយ .....។

៣. ទំនៀមទំនឹមព្រេង ច្បាប់ថ្លាថ្លែងដោយក្រឹត្យក្រម

..... ចូរបាខំៗត្រងត្រាប់ ។

៤. សង្វាតរកស៊ីចុក ជួលលក់ទិញតាមច្បាប់

..... កុំខុសច្បាប់ព្រះធម្មា ។

៥. មានទ្រព្យត្បិតសំណាង ជាតិមុនសាងទានសីលា

បើកើតជាតិនេះណា .....។[...]

ឃ.សំណួរត្រិះរិះ

១- តើអត្ថបទនេះមានចំណុចណាខ្លះដែលនិយាយទាក់ទងទៅនឹងសេចក្តីថ្លៃថ្នូរ?

.....

.....

.....

.....

.....

.....

.....

.....

២- ចូរបង្ហាញពីតម្លៃអប់រំក្នុងអត្ថបទនេះ?

.....

.....

.....

.....

.....

.....

.....

៣- ចូរប្រាប់រង្វាស់ពាក្យ ចំណាប់ជូន ផ្ញូន រណ្តំ ចង្វាក់ និងបរិយាកាសក្នុងកំណាព្យនេះ?

.....

.....

.....

.....

.....

.....

.....

.....

៤. ចូរពន្យល់ន័យនៃឃ្លានីមួយៗនៃវគ្គខាងក្រោម

ពាក្យក្រកុំអាលប្រាប់ ពាក្យឥតសព្វកុំអាលថ្លែង

ពាក្យពិតកុំអាលចែង ពាក្យពិតស្លែងពុំគួរលាក់។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

๑ ការស្តាប់៖ តម្លៃនៃការសេពគប់

តម្លៃនៃការសេពគប់

(បទពាក្យ ៧)

គប់ពាលវែងរាលទៅរកខុស គប់ប្រាជ្ញាស្រីប្រុសវែងបានត្រូវ
គប់មិត្រអបល័ក្ខណ៍វែងអាស្រូវ ខុសត្រូវមានព្រោះការសេពគប់។
គួរជ្រើសរើសរកជនប្រុសស្រី តើមានធម៌អ្វីជាប្រភព
បើឃើញច្បាស់ហើយសឹមសេពគប់ ឬត្រូវតែឈប់កុំរវល់។
បើតាមឱវាទព្រះសម្ពុទ្ធ វិសុទ្ធទ្រង់ធម៌និមល
គួរដឹងថាបើឃើញបុគ្គល យល់ខុសពុំគួរសេពគប់ឡើយ។
សូវនៅម្នាក់ឯងប្រសើរជាង ត្រូវតែចៀសវាងជនគោះតើយ មិនកាន់
តាមធម៌ជាកោះត្រើយ ព្រងើយដោយយល់ថាខ្លួនត្រូវ។ មក
ពីច្រឡំភ័ន្តគំនិត ភ្លាត់គិតបែរយល់ថាព្រៃថាផ្លូវ
យកធម៌សុចរិតជាសត្រូវ ក្រឡូវតម្កើងឯទុច្ចរិត។
ផ្ទុយទេខុសទេគួរបោះបង់ គួរខំផ្ចិតផ្ចង់កាន់សុចរិត
កុំអាងថាស្រេចតែនឹងចិត្ត គួរអាណិតខ្លួននោះទើបសម។
ព្រោះការសេពគប់នេះសំខាន់ ប្រយ័ត្នកុំភ័ន្តកុំច្រឡំ
គប់ពាលបានពាលមិនបាច់ខំ ដូចគេវាយដំឱ្យសន្លប់។
គប់មិត្តបណ្ឌិតបានបណ្ឌិត គំនិតត្រឹមត្រង់អាចបញ្ចប់
ឧបទ្រពចង្រៃឱ្យរម្ងាប់ សុខសួស្តីអាចកើតមានឯងៗ។
ព្រះសព្វតញ្ញូទ្រង់ត្រាស់ថា ជនណាជាមនុស្សពាលជាក់ស្តែង
ស្រាប់តែភ្ញាក់ខ្លួនថាអញឯង ជាពាលក្រៃលែងទៅហើយតើ។

ជននោះបានឈ្មោះថាបណ្ឌិត ព្រោះភ្ញាក់គំនិតដោយអើពើ
នឹងអាចញ៉ាំងខ្លួនឱ្យបានរើ គំនិតសើរើឱ្យឃ្លាតឆ្ងាយ។
ផ្ទុយគ្នាស្រឡះពីជនពាល ពង្រីកពង្រាលផ្លូវអបាយ
ប្រមុខនៃទុក្ខភយន្តរាយ កម្ចាយសុខសូប៌ឱ្យសាបសូន្យ។
ឥតភ្ញាក់ខ្លួនសោះរឹតតឹត ឥតគិតអាណិតប្រពន្ធកូន
ទោះបីមិត្រភក្តិនិងបងប្អូន ទូន្មានរំឭកក៏លែងកើត។
ជននោះឈ្មោះថាមហាពាល ពេញសិបជាពាលតួឯកឆើត
គួរសាធុជនកុំឈមអើត មិនកើតទេគុណក្លាយជាទោស។
គួរចៀសដូចចៀសផ្លូវអសិល ខ្ចិចខ្ចិលយ៉ាងណាដោយសន្តោស កុំ
ឈ្លោះប្រកាន់ឱ្យរឱិស ក្រែងទោសនឹងមានព្រោះធ្វើគុណ។
អហំជ.ណ ជោតញ្ញាណោ មានក្តីគោរពព្រះមានបុណ្យ
ពេលដែលខ្លួនកាន់តែចាស់ស៊ុន ជីពជន្មគម្រប់ប៉ែតសិបប្រាំ។
ភ្ជុកនឹកដល់ពុទ្ធភាសិត ថារូបយើងពិតជាមិនទ្រាំ
ដល់រយឆ្នាំទេបែកខ្ទេចខ្ទាំ ពុំទ្រាំរស់នៅតាមចងឡើយ។
រូបបាត់សូន្យទៅនាមគង់នៅ ដោយសារចិត្តដៅពុំតោះតើយ
ប្រឹងកសាងកេរ្តិ៍ពុំព្រងើយ ខ្លួនបាត់ទៅហើយកេរ្តិ៍គង់នៅ។
ហេតុនេះអហំរែងខំប្រឹង ទោះខ្លួនចាស់ម្លឹងនៅសៅដៅ
ធ្វើនេះរួចធ្វើនោះទៀតទៅ មិននៅយកស្រួលដោយទម្រន់។
មិនព្រមទម្រើសខ្លួនឱ្យធ្លាប់ តាំងចិត្តមាំខ្ជាប់ដោយគិតគណន៍ឃើញ
ថាករណីទោះស្រាលធ្ងន់ កម្រពេកពន់ក៏ត្រូវប្រឹង។
មានពាក្យភាសិតចែងប្រាប់ថា រូបតែងជរាមិនរឹងប៉ឹង

ប៉ុន្តែរូបកុំដេកសម្លឹង　　រង់ចាំតែពេលអស់ជីវិត។
កិច្ចការខ្លះធ្វើបានដោយកាយ　　ខ្លះវាចានឹងចិត្តគិត
ទោះខ្លួនចាស់ត្រូវប្រឹងប្រព្រឹត្ត　　កុំគិតដេកចាំតែពេលស្លាប់។
ធ្វើទៅស្តីទៅគិតឱ្យសព្វ　　ការអ្វីគួរគាប់ត្រូវកាន់កាប់
ប្រយ័ត្នកុំឱ្យតែខុសច្បាប់　　បើច្បាប់បើកផ្លូវត្រូវប្រឹងធ្វើ។
ប្រយ័ត្នមួយយ៉ាងកុំប៉ះ　　ប្រទះត្រូវចំលើអំពើ
ជាកម្មអកុសលកុំឱ្យធ្វើ　　ព្រោះកាលបើធ្វើវែងបានទុក្ខ។
កុំឃើញត្រឹមតែបច្ចុប្បន្ន　　ប្រយ័ត្នក្រែងកាន់ទៅខាងមុខ
កុំយល់ថាចេះតែបានសុខ　　ស្រណុកស្រណានគ្មានទុក្ខឡើយ។
បានសុខត្រូវនឹកដល់ទុក្ខផង　　គិតឱ្យហ្មត់ហ្មងកុំគោះតើយ
សុខទុក្ខក្រវែងគ្នាឥតស្បើយ　　ណ្តើយត្រឹមប៉ុណ្ណឹងចុះចប់ហោង៕[...]

(ដកស្រង់ចេញពីសៀវភៅកំណាព្យរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត)

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើអត្ថបទខាងលើដកស្រង់ចេញពីណា?

ក. សៀវភៅកំណាព្យរបស់សម្តេចសង្ឃ ជួន ណាត

ខ. សៀវភៅកំណាព្យរបស់ ក្រម ង៉ុយ

គ. អត្ថបទទូន្មានខ្លួនរបស់ ពុទ្ធសាសនបណ្ឌិត្យ

ឃ. អត្ថបទទូន្មានខ្លួនរបស់ ព្រះអង្គឌួង

២. តើអត្ថបទកំណាព្យខាងលើជាបទអ្វី?

ក. បទកាកគតិ ខ. បទព្រហ្មគីតិ

គ. បទពំនោល ឃ. បទពាក្យ៧

៣. តើអត្ថបទកំណាព្យខាងលើមានប៉ុន្មានឃ្លាក្នុងមួយល្អះ?

ក. មាន២ឃ្លា ខ. មាន៣ឃ្លា

គ. មាន៤ឃ្លា ឃ. មាន៥ឃ្លា

៤. តើអត្ថបទកំណាព្យខាងលើមានប៉ុន្មានព្យាង្គក្នុងមួយឃ្លា?

ក. មាន៤ព្យាង្គ ខ. មាន៥ព្យាង្គ

គ. មាន៦ព្យាង្គ ឃ. មាន៧ព្យាង្គ

៥. តើពាក្យ គប់ មានន័យប៉ុន្មានយ៉ាង?

ក. មាន១យ៉ាង ខ. មាន២យ៉ាង

គ. មាន៣យ៉ាង ឃ.មាន៤យ៉ាង

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ការអ្វីគួរគាប់ត្រូវកាន់កាប់ ព្រោះកាលបើធ្វើវែងបានទុក្ខ ខ្លះវាចានឹងចិត្តគិតស្រណុកស្រណានគ្មានទុក្ខឡើយ

កិច្ចការខ្លះធ្វើបានដោយកាយ .....

ទោះខ្លួនចាស់ត្រូវប្រឹងប្រព្រឹត្ត កុំគិតដេកចាំតែពេលស្លាប់។

ធ្វើទៅស្តីទៅគិតឱ្យសព្វ .....

ប្រយ័ត្នកុំឱ្យតែខុសច្បាប់ បើច្បាប់បើកផ្លូវត្រូវប្រឹងធ្វើ។

ប្រយ័ត្នមួយយ៉ាងកុំប៉ះ ប្រទះត្រូវចំលើអំពើ

ជាកម្មអកុសលកុំឱ្យធ្វើ .....។

កុំយើញត្រឹមតែបច្ចុប្បន្ន ប្រយ័ត្នក្រែងកាន់ទៅខាងមុខ

កុំយល់ថាចេះតែបានសុខ .....។

គ.សំណួរត្រិះរិះ

១. ហេតុដូចម្តេចបានជាកវីលើកយកការសេពគប់មកធ្វើការអប់រំដល់អ្នកសិក្សា?

.....

.....

.....

.....

.....

២. តើឱវាទរបស់កវីក្នុងអត្ថបទកាព្យខាងលើនេះ បានផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

៣. តើការសេពគប់មិត្តល្អបានផ្តល់តម្លៃដល់អ្នកយ៉ាងណាខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✍ សំណេរ៖ តែងកំណាព្យបទពាក្យ៨ និងពាក្យ៩

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើបទពាក្យ៨ក្នុងមួយវគ្គមានប៉ុន្មានឃ្លា?

ក. មាន២ឃ្លា ខ. មាន៣ឃ្លា

គ. មាន៤ឃ្លា ឃ. មាន៥ឃ្លា

២. តើបទពាក្យ៩ក្នុងមួយវគ្គមានប៉ុន្មានឃ្លា?

ក. មាន២ឃ្លា ខ. មាន៣ឃ្លា

គ. មាន៤ឃ្លា ឃ. មាន៥ឃ្លា

៣. តើបទពាក្យ៨ ក្នុងមួយឃ្លាៗមានប៉ុន្មានព្យាង្គ?

ក. មាន៥ព្យាង្គ ខ. មាន៧ព្យាង្គ

គ. មាន៨ព្យាង្គ ឃ. មាន៩ព្យាង្គ

៤. តើបទពាក្យ៩ ក្នុងមួយឃ្លាៗមានប៉ុន្មានព្យាង្គ?

ក. មាន៥ព្យាង្គ ខ. មាន៧ព្យាង្គ

គ. មាន៨ព្យាង្គ ឃ. មាន៩ព្យាង្គ

៥. នៅក្នុងចំណាប់ជូនស្លងវគ្គ បទពាក្យ៨ តើព្យាង្គណាជូននឹងព្យាង្គណា?

ក. ព្យាង្គទី៨នៃឃ្លាទី១ ជូននឹងព្យាង្គទី៤នៃឃ្លាទី២

ខ. ព្យាង្គទី៨នៃឃ្លាទី២ ជូននឹងព្យាង្គទី៨នៃឃ្លាទី៣

គ. ព្យាង្គទី៨នៃឃ្លាទី៣ ជូននឹងព្យាង្គទី៤នៃឃ្លាទី៤

ឃ. ព្យាង្គទី៨នៃឃ្លាទី៤ វគ្គទី១ ជូននឹងព្យាង្គទី៨នៃឃ្លាទី២ វគ្គទី២

៦. នៅក្នុងចំណាប់ជួនឆ្លងវគ្គ បទពាក្យ៩ តើព្យាង្គណាជួននឹងព្យាង្គណា?

ក. ព្យាង្គទី៩នៃឃ្លាទី១ ជួននឹងព្យាង្គទី៣ឬទី៦នៃឃ្លាទី២

ខ. ព្យាង្គទី៩នៃឃ្លាទី២ ជួននឹងព្យាង្គទី៩នៃឃ្លាទី៣

គ. ព្យាង្គទី៩នៃឃ្លាទី៤ វគ្គទី១ ជួននឹងព្យាង្គទី៩នៃឃ្លាទី២ វគ្គទី២

ឃ. ព្យាង្គទី៩នៃឃ្លាទី៣ ជួននឹងព្យាង្គទី៣ឬទី៦នៃឃ្លាទី៤

៧. ដើម្បីតែងកំណាព្យបទពាក្យ៨និងបទពាក្យ៩បានត្រឹមត្រូវ ត្រូវពិនិត្យលើ

ក. រង្វាស់កាព្យ ខ. ចំណាប់ជួន

គ. ជួនក្នុងវគ្គនិងជួនឆ្លងវគ្គ ឃ. រង្វាស់កាព្យនិងចំណាប់ជួន

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

- ជួនក្នុងវគ្គ

ព្យាង្គទី..... នៃឃ្លាទី ១ ជួននឹងព្យាង្គទី ..... នៃឃ្លាទី ២

ព្យាង្គទី..... នៃឃ្លាទី ២ ជួននឹងព្យាង្គទី ..... នៃឃ្លាទី ៣

ព្យាង្គទី..... នៃឃ្លាទី ៣ ជួននឹងព្យាង្គទី ..... នៃឃ្លាទី៤

- ជួនឆ្លងវគ្គ

ព្យាង្គទី..... នៃឃ្លាទី ៤ វគ្គទី ១ ជួននឹងព្យាង្គទី ..... នៃឃ្លាទី ២ វគ្គទី ២

- ជួនក្នុងវគ្គ

ព្យាង្គទី..... នៃឃ្លាទី ១ ជួននឹងព្យាង្គទី..... ឬព្យាង្គទី ..... នៃឃ្លាទី ២

ព្យាង្គទី..... នៃឃ្លាទី ២ ជួននឹងព្យាង្គទី .....នៃឃ្លាទី ៣

ព្យាង្គទី..... នៃឃ្លាទី ៣ ជួននិងព្យាង្គទី ..... ឬព្យាង្គទី ..... នៃឃ្លាទី ៤

- ជួនឆ្លងវគ្គ

ព្យាង្គទី..... នៃឃ្លាទី ៤ វគ្គទី ១ ជួននឹងព្យាង្គទី ..... នៃឃ្លាទី ២ វគ្គទី ២ ។

ខ.សំណួរត្រិះរិះ

១. ចូរប្លែនតែងកំណាព្យបទពាក្យ៨ ដែលនិយាយទាក់ទងនឹងភាពថ្លៃថ្នូររបស់សិស្សក្នុងការសិក្សា ចំនួន២ឈ្នះ។

បទពាក្យច្រាំបី

....

....។

....

....។

២. ចូរប្លែនតែងកំណាព្យបទពាក្យ៩ ដែលនិយាយទាក់ទងនឹងភាពថ្លៃថ្នូរក្នុងការសេពគប់មិត្ត ចំនួន២ឈ្នះ។

បទពាក្យច្រាំមួន

....

....។

....

....។

ᨾᨾ មេរៀនទី១០៖ ឧត្តមភាព ᨾᨾ

🕯 បំណិន៖ និទានកថា

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងប្រភេទណាជាព្រេងកថា?

ក. ជារឿងពិតដែលដំណើររឿងទាក់ទងនឹងទំនៀមទម្លាប់ ជំនឿ ប្រវត្តិភូមិស្រុក.....

ខ. ជារឿងប្រឌិតដែលដំណើររឿងទាក់ទងនឹងទំនៀមទម្លាប់ ជំនឿ ប្រវត្តិភូមិស្រុក.....

គ. ជារឿងពិតដែលដំណើររឿងមិនទាក់ទងនឹងទំនៀមទម្លាប់ ជំនឿ ប្រវត្តិភូមិស្រុក.....

ឃ. ជារឿងប្រឌិតដែលដំណើររឿងមិនទាក់ទងនឹងទំនៀមទម្លាប់ ជំនឿ ប្រវត្តិភូមិស្រុក...

២. តើរឿងប្រភេទណាជាទេវកថា?

ក. ជារឿងពិតដែលឆ្លុះបញ្ចាំងពីការយល់ដឹងដំបូងរបស់មនុស្សពីប្រភពកំណើតនៃអាទិទេព ទេវៈ អ្នកតា មនុស្ស សត្វ រុក្ខជាតិ បាតុភូតធម្មជាតិ និងប្រភពពិធីគោរពបូជាផ្សេងៗ

ខ. ជារឿងប្រឌិតដែលឆ្លុះបញ្ចាំងពីការយល់ដឹងដំបូងរបស់មនុស្សពីប្រភពកំណើតនៃអាទិទេព ទេវៈ អ្នកតា មនុស្ស សត្វ រុក្ខជាតិ បាតុភូតធម្មជាតិ និងប្រភពពិធីគោរពបូជាផ្សេងៗ

គ. ជារឿងពិតដែលមិនឆ្លុះបញ្ចាំងពីការយល់ដឹងដំបូងរបស់មនុស្សពីប្រភពកំណើតនៃអាទិទេព ទេវៈ មនុស្ស សត្វ រុក្ខជាតិ បាតុភូតធម្មជាតិ និងប្រភពពិធីគោរពបូជាផ្សេងៗ

ឃ. ជារឿងប្រឌិតដែលមិនឆ្លុះបញ្ចាំងពីការយល់ដឹងដំបូងរបស់មនុស្សពីប្រភពកំណើតនៃអាទិទេព ទេវៈ មនុស្ស សត្វ រុក្ខជាតិ បាតុភូតធម្មជាតិ និងប្រភពពិធីគោរពបូជាផ្សេងៗ

៣. តើរឿងប្រភេទណាជានិទានកថា?

ក. ជារឿងពិតដែលគេនិយាយតៗគ្នា ស្គាល់អ្នកនិពន្ធដើម

ខ. ជារឿងពិតដែលគេនិយាយតៗគ្នា រហូតមិនស្គាល់អ្នកនិពន្ធដើម

គ. ជារឿងប្រឌិតដែលគេនិយាយតៗគ្នា ស្គាល់អ្នកនិពន្ធដើម

ឃ. ជារឿងប្រឌិតដែលគេនិយាយតៗគ្នា រហូតមិនស្គាល់អ្នកនិពន្ធដើម

៤. តើតួអង្គប្រភេទណាមានលក្ខណៈសំគាល់ជាព្រេងកថា?

ក. ជាអមនុស្ស ខ. ជាសត្វឬធម្មជាតិ

គ. ជាមនុស្សធម្មតា ឃ. ជាទេវតា

៥. តើរឿងប្រឌិតប្រភេទណាដែលមានដំណើររឿងទាក់ទងនឹងប្រវត្តិសាស្ត្ររបស់ប្រទេស?

ក. ទេវកថា ខ. ព្រេងកថា

គ. និទានកថា ឃ. ប្រលោមលោក

៦. តើរឿងមួយណាជាប្រភេទរឿងនៅក្នុងទេវកថា?

ក. រឿងអ្នកតាឃ្លាំងមឿង ខ. រឿងតាដុងយាយជ័យ

គ. រឿងប្រាសាទអង្គរវត្ត ឃ. រឿងអ្នកតាទឹកអ្នកតាភ្នំ

៧. តើរឿងមួយណាជាប្រភេទរឿងនៅក្នុងព្រេងកថា?

ក. រឿងកំណើតរន្ទះ ខ. រឿងស្វានិងអណ្តើក

គ. រឿងអ្នកតាឃ្លាំងមឿង ឃ. រឿងមាយើង

៨. តើរឿងមួយណាជាប្រភេទរឿងនៅក្នុងនិទានកថា?

ក. រឿងកំណើតរន្ទះ ខ. រឿងដោះកំណើតសត្វផ្សោត

គ. រឿងអ្នកតាឃ្លាំងមឿង ឃ. រឿងមាយើង

៩. តើនិទានកថាមានលក្ខណៈសំគាល់បែបណា?

ក. បង្ហាញជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសង្គម

ខ. បង្ហាញពីប្រវត្តិភូមិស្រុក តំបន់ ប្រទេស

គ. បង្ហាញពីរឿងរ៉ាវអច្ឆរិយ ទេវតា អមនុស្ស

ឃ. បង្ហាញពីរឿងរ៉ាវស្តីពីដើមកំណើតពិធីផ្សេងៗ

ខ.សំណួរត្រិះរិះ

១. ចូរអានរឿងទាំងពីរខាងក្រោម ហើយប្រាប់ពីប្រភេទរឿងនីមួយៗ ។

២. ចូរបង្ហាញពីលក្ខណៈសំគាល់រឿងមនុស្សលោភ?

រឿង ភ្នំសែនហាន (នៅខេត្តកំពត)

សម័យពីព្រេងនាយក្នុងគ្រាមួយដែលអ្នកស្រុកអំណាត់ណាស់មានមនុស្សច្រើននាក់នាំគ្នាទៅរកស៊ីធ្វើការនៅជើងភ្នំនោះដែលជាភ្នំពុំទាន់មានឈ្មោះថាអីនៅឡើយ ហើយពុំទាន់មានដើមឈើច្រើន ដែរ ។ គេបាននាំគ្នាដាំដំណាំផ្សេងៗជាច្រើន មានចេក ពោត ត្រាវ ដំឡូង ដូង ស្លាជាដើម ។ ក្នុងគ្រានោះមានតាម្នាក់ឈ្មោះ៖ "សែន" បានធ្វើចំការក្នុងទីនោះដែរ ។ ពេលដែលដំណាំកំពុងតែលូតលាស់ល្អល្មមប្រើការបាន ស្រាប់តែមានដំរីស្តមួយចូលមកកាច់ចេក ដកដំណាំនោះស៊ីជារឿយៗ ។ តាសែន គិតថា "បើអញមិនរកមធ្យោបាយដើម្បីកំចាត់ដំរីនេះចេញទេ មុខតែថ្ងៃណាមួយវានឹងស៊ីដំណាំនេះអស់ជាមិនខាន ទើបគាត់ចាប់លំពែងនិងកាំបិតព្រាដេញចាក់កាប់ដំរីស្តនោះដរាបដល់ស្លាប់ ។ ឯជនឯទៀតៗមិនហ៊ានដេញចាក់កាប់ដំរីនោះសោតឡើយ ។ កាលបើតាសែនសម្លាប់ដំរីនោះបានហើយ អ្នកស្រុកភូមិទាំងអស់នាំគ្នាហៅឈ្មោះគាត់ថា " តាសែនក្លាហានៗ " ។

លុះចំណេរតៗមក ទោះបីតាសែនបានធ្វើមរណកាលទៅហើយក្តី ក៏មនុស្សអ្នកស្រុកភូមិនាំគ្នា ហៅភ្នំដែលជាលំនៅតាសែននោះ ភ្នំតាសែនក្លាហាន" ។ លុះយូរៗមកទៀតក៏ហៅខ្លីត្រឹមតែ "ភ្នំសែនហានៗ រហូតមកដល់សព្វថ្ងៃនេះ ។

(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរភាគ ៦)

រឿងមនុស្សលោភ

កាលពីព្រេងនាយមានកុមារីម្នាក់អាយុ ១៤ឆ្នាំម្តាយប្រើឱ្យទៅជីកដំឡូង ។ ក្នុងនោះរៀបចំស្រេចចេញដើរទៅរកដំឡូង ។ ទៅដល់ព្រៃធំមានដំបូកមួយមានរូងជ្រៅ។ កុមារីនោះទៅជីកដំឡូង នៅជើងដំបូកនោះរបូតផ្លែចបជ្រុះធ្លាក់ទៅក្នុងរូង។ នាងនោះមិនដឹងធ្វើដូច

ម្តេចក៏ស្រែកប្រកាស ថា "លោកណាជួយយកផ្លែចបឱ្យខ្ញុំបាន ខ្ញុំនឹងសងគុណលោក" ។ ស្រែកតែប៉ុណ្ណោះមានខ្លាចាស់មួយ ដំបៅក្បាលរុយបែងដង្កូវចុះគគ្រិចចេញមកពីក្នុងព្រៃ ប្រាប់ទៅនាងពោថា "នាង! តាយកឱ្យបានផ្លែចបនោះ តែបើតាយកបាននាងឯងគ្រាន់តែរកចៃឱ្យបានហើយ តាមិនចាំបាច់យកគុណពីចៅ" ។ នាងឮខ្លាថាដូច្នោះ ក៏និយាយថា "ឱ លោកតាអើយ! ឱ្យតែលោកតាជួយយកឱ្យបានចុះ " ។ ខ្លានោះយកផ្លែចបបានពីក្នុងរូងឱ្យទៅនាង ហើយឱ្យនាងនោះរកចៃឱ្យ ។ នាងនោះយកបន្លាមកឆ្កឹះដង្កូវនៅ ដំបៅក្បាលខ្លានោះ ។ ខ្លានោះចេះតែសួរនាងថា នាង ដំបៅតាស្អុយឬក្រអូប ?" ។ តាមពិតដំបៅនោះស្អុយណាស់ ប៉ុន្តែនាងឆ្លើយថា "ក្រអូបណាស់លោកតា ។ ខ្លានោះដើរតែសួរនាងចេះតែថាក្រអូប លុះឆ្កឹះដង្កូវនោះអស់ទៅ ខ្លានោះបាត់ឈឺបាត់រមាស់ ហើយនិយាយប្រាប់នាងនោះថានាង នាងយកជាលមួយមកតានឹងដាក់ដំឡូងឱ្យ នាងនោះយកជាលមួយមកឱ្យខ្លាៗដាក់សុទ្ធតែមាសប្រាក់ពេញជាល ហើយចងមាត់ជាលជាប់ឱ្យទៅនាងនោះ រួចប្រាប់នាងថា នាងនាងយក ជាលនេះទៅផ្ទះហៅបងប្អូនមកជុំ បិទទ្វារឱ្យជិតសឹមបើក ។ នាងនោះលាខ្លាដើរទៅដល់ផ្ទះ ហៅបងប្អូនមកជុំរួចក៏បើកជាលនោះ ។ ដល់បើកទៅបានសុទ្ធតែមាសនិងប្រាក់ចែកគ្នា។ លុះយូរបន្តិចដឹងទៅដល់គ្រួសារមួយទៀត ដែលមានកូនក្រមុំ។ ស្រីនោះបញ្ជាកូនក្រមុំថា "ឯងមើលកូនគេៗទៅជីកដំឡូងបាន មាសប្រាក់យកមកចែកបងប្អូនគេ ឯងឯងវិញទៅជីកដំឡូងបានតែដំឡូងគ្មានបានខ្មោចអ្វីទេ" ។ ក្រោយស្រីនោះឱ្យកូនទៅជីកដំឡូងដូចនាងនោះ លុះទៅបានជួបប្រទះនឹងខ្លាមុននោះ ក៏ធ្វើជាជ្រុះចប ដូចនាងមុនហើយថា "លោកណាយកចបឱ្យខ្ញុំ ខ្ញុំនឹងសងគុណលោក ។ ខ្លានោះឮហើយក៏មកយកឱ្យ រួចឱ្យនាងនោះចាប់ដង្កូវឱ្យ ។ ខ្លាសួរដូចមុនថា នាង ដំបៅតាស្អុយឬក្រអូប?" ។ នាងពោរឆ្លើយថា "ស្អុយណាស់ " ។ ខ្លាឮដូច្នោះ៖ ក៏ប្រាប់ថានាងយកជាលមួយមកតានឹងដាក់មាសប្រាក់ឱ្យនាងយកជាលមួយឱ្យខ្លាៗចាប់សុទ្ធតែពស់វែកដាក់ពេញជាលហើយឱ្យទៅនាងនោះប្រាប់ថា "នាងយកទៅផ្ទះហៅបងប្អូនមកជុំ បិទទ្វារឱ្យជិតសឹមបើក" ។ "នាងនោះទៅដល់ផ្ទះហើយប្រាប់ម្តាយ ម្តាយអរណាស់ឱ្យបងប្អូនមកជុំបិទទ្វារបើកជាលមើល ពស់វែកចេញមកចឹកមនុស្សទាំងនោះស្លាប់អស់ទៅ ។

(ដកស្រង់ពីប្រជុំរឿងព្រេងខ្មែរភាគ ២)

ក. រឿងភ្នំសែនហាន (នៅខេត្តកំពត)

.....

.....

.....

.....

.....

.....

.....

ខ. រឿងមនុស្សលោភ

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណាន៖ រឿង អាខ្វាក់អាខ្វិន

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងអាខ្វាក់អាខ្វិនជារឿងប្រឌិតប្រភេទណា?

ក. ទេវកថា ខ. ព្រេងកថា

គ. និទានកថា ឃ. ប្រលោមលោក

២. ហេតុអ្វីបានជានាយខ្វាក់នាយខ្វិនបបួលគ្នារត់?

ក. គេចពីការងារដែលគេប្រើយ៉ាងលំបាកលំបិន ខ. គេចពីគេតាមសម្លាប់

គ. គេចពីក្រុមគ្រួសារ ឃ. គេចពីការតាមសម្លាប់របស់យក្ស

៣. តាមរយៈហេតុការណ៍ក្នុងរឿងនេះ តើបានឆ្លុះបញ្ចាំងពីអ្វី?

ក. សង្គ្រាមរវាងមនុស្សនិងយក្ស ខ. ជីវភាពរស់នៅក្នុងសង្គម

គ. យក្សស៊ីមនុស្ស ឃ. ភាពអំនួតនាំមកនូវជ័យជម្នះ

៤. តើចំណុចត្រង់ណាក្នុងសាច់រឿងដែលបង្ហាញពីភាពភ្លាហាន?

ក. នាយខ្វាក់ស្រឡាញ់បុត្រីស្តេច ខ. នាយខ្វាក់ហូបច្រើន

គ. នាយខ្វាក់កម្ចាត់យក្ស ឃ. នាយខ្វាក់សម្តីកោងកាច

៥. តើការធ្វើដំណើររបស់នាយខ្វាក់នាយខ្វិនជួបប្រទះនឹងហេតុការណ៍អ្វី?

ក. ជួបស្ត្រីក្រមុំរូបស្រស់ ខ. ជួបខ្មាំងសត្រូវ

គ. ជួបព្រាយបិសាច ឃ. ជួបយក្សកំណាច

៦. តើភាពជោគជ័យរបស់នាយខ្វាក់នាយខ្វិនកើតឡើងដោយសារអ្វី?

ក. ភាពអំនួត ខ. ភាពក្លាយហាន ប្រាជ្ញាវាងវៃ

គ. ការជួយពីអ្នកដទៃ ឃ. ព្រេងសំណាង

៧. ហេតុអ្វីបានជាស្តេចលើកនាងពៅឱ្យធ្វើជាព្រះជាយានាយខ្វាក់?

ក. ដោយសាររូបរាងសង្ហា ខ. ដោយសារមានទ្រព្យធន

គ. ដោយសារមានសេចក្តីក្លាហាន ឃ. ដោយសារមានអំណាចធំ

ឥ.សំណួរត្រិះរិះ

១. តើភាពជោគជ័យរបស់នាយខ្វាក់នាយខ្វិនកើតឡើងដោយសារកត្តាអ្វីខ្លះ?

.....

.....

.....

.....

.....

២. ចូរនិយាយពីគុណសម្បត្តិរបស់នាយខ្វាក់?

.....

.....

.....

.....

.....

.....

.....

៣. តើរឿងនេះមានតម្លៃអប់រំដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....

.....

📖 អំណានៈ រឿងភ្នំប្រុស ភ្នំស្រី

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងភ្នំប្រុសភ្នំស្រីជារឿងប្រឌិតប្រភេទណា?

ក. ទេវកថា ខ. ព្រេងកថា

គ. និទានកថា ឃ. ប្រលោមលោក

២. តើដំណើររឿងនេះចែករួបភាពជាប៉ុន្មានប្លង់?

ក. ៨ប្លង់ ខ. ១០ប្លង់

គ. ១១ប្លង់ ឃ.១២ប្លង់

៣. ហេតុអ្វីបានជាស្រីៗសម័យនោះនាំគ្នាទៅដណ្តឹងប្រុសធ្វើជាប្តី?

ក. ជាច្បាប់ធម្មជាតិ ខ. ការការចង់បានប្តី

គ. ធ្វើតាមព្រះនាងស្តេីអយុធ្យា ឃ. ខ្លាចមិនមានប្តី

៤. ដើម្បីផ្លាស់ប្តូរប្រពៃណីស្រីទៅដណ្តឹងប្រុសតើគេបានប្រើវិធីអ្វី?

ក. មិនព្រមទៅស្តីដណ្តឹង ខ. ភ្នាល់លើកដីធ្វើភ្នំ

ខ. ស្តេចកែប្រែច្បាប់ថ្មី ឃ. ភ្នាល់ធ្វើសឹកសង្គ្រាម

៥. ឧត្តមភាពក្នុងរឿងនេះសំដៅលើអ្វី?

ក. ភាពមានកម្លាំងខ្លាំងខ្លា ខ. ភាពមានអំណាចធំ

គ. សាមគ្គីភាពនិងឆ្លាសវៃ ឃ. ភាពអួតអាងខុសទំនង

៦. តើភាគីខាងស្រីៗ បានប្រើមធ្យោបាយអ្វីដើម្បីយកឈ្នះភាគីខាងប្រុស?

ក. ប្រើកម្លាំងបាយ ខ. រកអ្នកជួយលើកភ្នំ

គ. ធ្វើភ្នំតូចជាង ឃ. ល្បិចបង្ហូតគោមបន្លំជាផ្តាយព្រឹក

ឆ.សំណួរត្រិះរិះ

១. តើគេប្រើវិធីបែបណាដើម្បីផ្លាស់ប្តូរប្រពៃណីស្រីដណ្តឹងប្រុស?

.....

.....

.....

.....

.....

.....

២. ចូរបង្ហាញពីទំនាស់ក្នុងខ្លួន និងក្រៅខ្លួនរបស់តួអង្គនៅក្នុងរឿងនេះ។

.....

.....

.....

.....

.....

.....

.....

៣. ចូរបង្ហាញពីឧត្តមភាពខាងស្រីៗតាមរយៈរឿងភ្នំប្រុសភ្នំស្រី។

.....

.....

.....

.....

.....

៤. តើរឿង ភ្នំប្រុសភ្នំស្រីបានបង្កប់នូវតម្លៃអប់រំដូចម្តេចខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

📖 អំណានៈ រឿងខ្សែកដែលបាត់ទៅ

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿងខាងលើដកស្រង់ចេញពីណា?

ក. អត្ថបទអក្សសិល្ប៍ខ្មែរ

ខ. សៀវភៅរឿងប្រលោមលោក

គ. ទស្សនាវដ្តីកម្ពុជាសុរិយោ

ឃ.សៀវភៅរឿងនិទានក្រសួងអប់រំ ១៩៩៤

២. តើខ្សែកដែលបាត់ជារបស់អ្នកណា?

ក. របស់ព្រះរាជា

ខ. របស់ឈ្មួញអង្គរ

គ. របស់សេដ្ឋីម្នាក់

ឃ. របស់បុរសកំសត់

៣. តើអ្នកណាជាអ្នករើសបានខ្សែកដែលបាត់នោះ?

ក. លោកសេដ្ឋី

ខ. បុរសកំសត់

គ. អ្នកនេសាទត្រី

ឃ. ឈ្មួញអង្គរ

៤. តើបុរសកំសត់ជាតួអង្គដូចម្តេច?

ក. ជាមនុស្សស្មោះត្រង់

ខ. ជាមនុស្សខិលខូច

គ. ជាមនុស្សលោភលន់

ឃ. ជាមនុស្សខ្ជិលច្រអូស

៥. តើតួអង្គសេដ្ឋីជាមនុស្សបែបណា?

ក. ជាមនុស្សស្មោះត្រង់

ខ. ជាមនុស្សសប្បុរសធម៌

គ. ជាមនុស្សលោភលន់

ឃ. ជាមនុស្សប្រកាន់យុត្តិធម៌

៦. តើតួអង្គចៅក្រមមានលក្ខណៈបែបណា?

ក. មានភាពលំអៀង ខ. មានភាពយុត្តិធម៌

គ. មិនអាចទទួលយកបាន ឃ. មិនគួរឱ្យគោរព

៧. ហេតុអ្វីបានជាសេដ្ឋីមិនអាចទទួលបានថង់មាសនិងខ្សែកដែលបានបាត់មកវិញ?

ក. ដោយសារតែនិយាយស្មោះត្រង់ពេក

ខ. ដោយសារតែការចង់បានលោភលន់ ភ្លេចភ្លាលើសចំនួនដែលបានបាត់

គ. ដោយសារចង់ឱ្យថង់មាសនិងខ្សែកនោះទៅបុរសកំសត់

ឃ. ដោយសារមិនចង់ទទួលរបស់ដែលបានបាត់បង់មកវិញ

ខ. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

ក. ពន្យល់ពាក្យ

- ស្តុកស្តម្ភ (...) .....

.....

- គតិបណ្ឌិត (...) .....

.....

- សុចរិត (...) .....

.....

- ទុច្ចរិត (...) .....

.....

គ.សំណួរត្រិះរិះ

១. ហេតុអ្វីបានជាបុរសកម្សត់យកថង់មាសប្រគល់ឱ្យសេដ្ឋីវិញ ?

.....

.....

.....

.....

.....

២. តើសេដ្ឋីសុខចិត្តទទួលយកថង់ប្រាក់ដោយសុខចិត្តដែរឬទេ ? ព្រោះអ្វី ?

.....

.....

.....

.....

.....

៣. តើចៅក្រមកាត់ក្តីយ៉ាងដូចម្តេច ? ព្រោះអ្វី ?

.....

.....

.....

.....

.....

៤. តើទង្វើរបស់តួអង្គបុរសកំសត់បានបង្ហាញអំពីឧត្តមភាពអ្វីខ្លះ ?

.....

.....

.....

.....

.....

.....

៧. ចូរបង្ហាញតម្លៃអប់រំរបស់រឿង ។

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

✍ សំណេរៈ រឿងរូបភាព

<u>លំហាត់</u>

ក. ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវតែមួយគត់

១. តើរឿង ភ្នំប្រុស ភ្នំស្រី ជារឿងបែបណា?

ក. ជារឿងទេវកថា
ខ. ជារឿងល្ខោនបាសាក់
គ. ជារឿងបែបរូបភាព
ឃ. ជារឿងបែបអត្ថបទសុទ្ធ

២. តើរឿងបែបរូបភាពមានលក្ខណៈសំគាល់បែបណា?

ក. មានលក្ខណៈជាអត្ថបទល្ខោន
ខ. ជាសំណេរអត្ថបទសុទ្ធ
គ. មានតែរូបភាពប៉ុណ្ណោះ
ឃ. មានជារូបភាពនិងអក្សរជាមួយគ្នា

៣. តើអត្ថបទរឿង ចចក ដកស្រង់ចេញពីណា?

ក. អត្ថបទអក្សសិល្ប៍បរទេស
ខ. សៀវភៅប្រជុំរឿងព្រេងខ្មែរភាគ១
គ. សៀវភៅរឿងនិទានក្រសួងអប់រំ ១៩៩៤
ឃ. មិនស្គាល់ប្រភព

៤. តើអត្ថបទរឿង ចចក ជារឿងប្រភេទអ្វី?

ក. ទេវកថា
ខ. ព្រេងកថា
គ. និទានកថា
ឃ. ប្រលោមលោក

៥. តើតួអង្គចចក មានលក្ខណៈបែបណា?

ក. ឆ្លាតវាងវៃ
ខ. លូងខ្លៅ
គ. ចេះជួយយកអាសារសត្វដទៃទៀត
ឃ. មិនលោភលន់

៦. តើតួអង្គកំពឹស មានលក្ខណៈបែបណា?

ក.មានប្រាជ្ញា ខ. លង់ខ្លៅ

គ. អាត្មានិយម ឃ. លោភលន់

៧. តើតួអង្គត្រីក្រាញ់ មានលក្ខណៈបែបណា?

ក. ឆ្លាតវាងវៃ ខ. លង់ខ្លៅ

គ. ពូកែតស៊ូ និងហ៊ានលះបង់ ឃ. លោភលន់

៨. តើតួអង្គទន្សាយ តំណាងអ្វី?

ក. តំណាងទេវតា ខ. ចៅក្រម

គ. សត្វអែបអប ឃ. តួអង្គលោភលន់

គ.សំណួរត្រិះរិះ

១. តើរឿងបែបរូបភាពមានលក្ខណៈដូចម្តេចខ្លះ?

.....

.....

.....

.....

២. ដើម្បីតាក់តែងរឿងបែបរូបភាពបានល្អ តើអ្នកតែងត្រូវគិតលើចំណុចអ្វីខ្លះ?

.....

.....

.....

.....

.....

.....

.....

.....

.....

.....

៣. ចូរអានរឿង ចចក រួចតែងរឿងវិញជារឿងបែបរូបភាព។

រឿងចចក

ពីព្រេងនាយមានចចកគ្រោសធំមួយ ដល់ខែរំហើយ វាដើរកត្រពាំងបឹងបួដែលរីងទឹក ដើម្បីចាប់ត្រីស៊ីជាអាហារ ។ លុះទៅដល់ត្រពាំងមួយរីងទឹកអស់នៅតែប្រលង់ឃើញសុទ្ធតែភក់ខ្មៅលាយឡំនិងស្លឹកឈើស្អុយរលួយមាន ត្រី កំពឹស បង្កង ក្តាមជាច្រើន វាលាន់មាត់៖ "ថ្ងៃនេះអញមានលាភធំណាស់ លាភចំលែកជាងសព្វថ្ងៃ"។ ឯកំពឹសមានប្រាជ្ញា ឮដូចនោះ ក៏និយាយលួងលោមចចក ៖ "យើងទាំងអស់គ្នា សុទ្ធតែជាចំណីបងឯងហើយ ប៉ុន្តែខ្លួនឯងប្រឡាក់សុទ្ធតែភក់ បើបងស៊ីទាំងភក់យ៉ាងនេះមិនឆ្ងាញ់ពិសាទេ!" ។ ចចកសួរ "ធ្វើដូចម្តេចនឹងឆ្ងាញ់ពិសា?" ។ កំពឹសឆ្លើយ ៖ បង ឯងត្រូវយកពួកយើងទៅលាងទឹកឱ្យជ្រះស្អាតហើយសឹមស៊ីទើបឆ្ងាញ់ពិសា ចចកសួរទៅកំពឹសទៀត "ធ្វើដូចម្តេចនឹងយកទៅលាងទឹកបាន បើមានគ្នាច្រើនដល់ម្ល៉េះ ?" ។ កំពឹសឆ្លើយ " ខ្ញុំធានា គិតឱ្យបងធ្វើបានស្រួល ប៉ុន្តែត្រូវធ្វើតាមខ្ញុំ" ។ ចចកក៏យល់ព្រមធ្វើតាមកំពឹស ។ កំពឹស ចូរបងចុះមកដេកនៀលក្នុងភក់នេះ យើងទាំងអស់គ្នានឹងខាំតោងរោមបង ហើយបងនាំយើងទៅរកស្ទឹងបឹងបួ ឯណាមានទឹកថ្លាច្រើន បងលាងយើងឱ្យស្អាត ហើយសឹមស៊ីឱ្យឆ្ងាញ់ពិសាតាមចិត្តចុះ ។ លុះទៅដល់បឹងធំមួយ មានទឹកថ្លាឆ្វេងត្រជាក់ស្រឹប ចចកក៏ដើរចុះទៅក្នុងទឹក អស់ កំពឹសក៏លោតចូលទៅក្នុងទឹកបឹង ហើយប្រាប់ចចក ៖ បងទៅជញ្ជូនពួកខ្ញុំឱ្យអស់សិន ចាំមកស៊ីឱ្យឆ្ងាញ់ ពួកខ្ញុំរង់ចាំបងនៅទីនេះ" ។ ចចកក៏ទៅជញ្ជូនត្រី និងកំពឹសលុះត្រាតែអស់ពីត្រពាំងនោះ។ ឯពួកត្រី កំពឹស ក្តាម ឃ្យងដឹង ថាចចកជញ្ជូនមកអស់ហើយ ក៏នាំគ្នាមុជទៅក្នុងទឹកជ្រៅបាត់អស់ ចចកដឹងថាកំពឹសបញ្ឆោតដូចនោះ ខឹងខ្លាំងណាស់ក៏ដើរទៅបបួលអស់សត្វតូចធំ ដំរី រមាសខ្លា ពស់ធំ ពស់តូចពស់ថ្លាន់ ទាំងសត្វ ហើរគ្មានសល់ឡើយមកបាចទឹកបឹងនោះឱ្យរីង និងបានចាប់មច្ឆជាតិទាំងនោះស៊ីឱ្យអស់គេឱ្យពស់ថ្លាន់ធ្វើទំនប់ សត្វឯទៀតនាំគ្នាបាច ។

សត្វក្នុងទឹកបឹងនិងដំណឹងនេះភ័យណាស់ក៏នាំគ្នាគិត ៖ "យើងធ្វើដូចម្តេចដើម្បីឱ្យសត្វទាំងនោះលែងបាចទឹកតទៅទៀត" ត្រីក្រាញ់ក៏ឆ្លើយ ខ្ញុំឮគេថា បងសុភាទន្សាយជាអ្នកមានប្រាជ្ញាចេះដោះស្រាយទុក្ខមនុស្សសត្វផងទាំងឡាយ។ ដូចនេះខ្ញុំទៅពឹងបងសុភាទន្សាយឱ្យមកជួយដោះស្រាយទុក្ខពួកយើង ពួកសត្វក៏យល់ព្រម ហើយត្រីក្រាញ់ក៏ប្រឹងនៀលទៅប្រទ្បាក់ដីស្រមក ទៅរកទន្សាយ ត្រូវថ្ងៃក៏ក្រៀមស្រកាក្រញង់ស្ងិតជាប់នឹងស្បែក ។ ពេលយប់សុភាទន្សាយចេញមករកស៊ីឃើញត្រីក្រាញ់កំពុងនៀលដូចនេះក៏សួរ ៖ បងត្រីក្រាញ់ឯង ទៅណា ?" ។ ត្រីក្រាញ់ឆ្លើយដោយត្រេកអរ បងសុភាទន្សាយអាណិតខ្ញុំ ត្រីទាំងអស់នៅក្នុងបឹង គេប្រើខ្ញុំមកអញ្ជើញបងទៅ ត្បិតឮអស់ទាំងមនុស្សនិយាយថាបងជាអ្នកមានប្រាជ្ញាកោតសេចក្តី ដោះទុក្ខអ្នកដទៃ ។ ឥលូវនេះមានរ៉ូងសត្វដំរី គោ ក្របី រមាស រមាំង ជ្រូក ពស់ធំ ពស់តូច ទាំងសត្វ ហើរ កុក ក្រៀល ចង្កៀលខ្យង ទុង ទោម ក្អែកទឹក ប្រវឹក ស្មោញទាំងប៉ុន្មាន បានបបួលគ្នាមកបាច ទឹកបឹងឱ្យរឹង និងបានចាប់អស់ត្រី អណ្តើក កន្ធាយ ស៊ីជាចំណីអាហារអស់ពីក្នុងបឹងនេះ ។ គេឱ្យពស់ថ្លាន់ ពស់ធំ ពស់តូច ធ្វើជាទំនប់ទប់បឹងនេះឯង ។ សូមបងមេត្តាជួយអស់បងប្អូន ឱ្យរួចផុតពីភ័យនេះម្តង និងបានល្បីកេរ្តិ៍ឈ្មោះតទៅ ។ ពួកយើងនឹងតបស្នងសងគុណ ហើយមិនភ្លេចគុណបងអស់ មួយជីវិត" ។ ទន្សាយឮត្រីក្រាញ់និយាយអង្វរដូចនោះក៏ឆ្លើយ "បងទៅមុនចុះ ហើយប្រាប់បងប្អូនកុំឱ្យភិតភ័យ ចាំខ្ញុំជួយដោះស្រាយឱ្យកុំបារម្ភ" ។ លុះព្រឹកព្រហាមឡើង ទន្សាយក៏ទៅមាត់បឹង ឃើញសត្វទាំងនោះកំពុងតែបាចទឹក ក៏យកស្លឹកឈើដែលដង្កូវស៊ីធ្លុះៗមកធ្វើជាសំបុត្រហើយស្រែកហៅសត្វទាំងនោះឱ្យស្លាប់ខ្លួន" នែ ! បងប្អូនទាំងអស់គ្នា ព្រះឥន្ទ្រលោកនឹងមកកាច់ជើងត្រុំ ប្រមុំជើងអក កាត់ក្បាលចចក ដកភ្លុកដំរីស ។ ពួកសត្វឮថា សំបុត្រព្រះឥន្ទ្រដូចនោះ ភិតភ័យណាស់ផ្អើលបោលជាន់គ្នា ដំរី ក្របី រមាស រមាំង ស្ទុះបោលទៅជាន់លើពស់ថ្លានដែលធ្វើជាទំនប់ដាច់ខ្លួនជាពីរបីកំណាត់ធ្លាយទំនប់លិចទឹកស្លាប់អស់ ។

តាំងពីថ្ងៃនោះមក អស់សត្វទាំងពួងនឹកកោតខ្លាចប្រាជ្ញាទន្សាយ ហើយចាត់ទុកសុភាទន្សាយជាគ្រូបាអាចារ្យទាំងអស់គ្នា ។

(ដកស្រង់និងកែសំរួលពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ ១)

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....



រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ខុសផ្លូវ
កុំភ្លើនភ្លេចមើ កុំប្រែហួសខ្លី យើញ្ញចាស់សក់ស្កូវ
កុំសូវមើលថាយ ។

(ច្បាប់ល្បីកថ្មី ក្រមជុំយ)